ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ក្រោមព្រះនេត្រនៃព្រះពុទ្ធ
- [illegible]

[illegible]

លេខ១១ ខែវិច្ឆិកា ឆ្នាំ២០០០

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ១១ ខែវិច្ឆិកា ឆ្នាំ២០០០

## មាតិកា

◆ សំបុត្រ ៈក្រោមព្រះនេត្រនៃព្រះពុទ្ធ.................................... ១

**ផ្នែកឯកសារ**

◆ទុយ ដេង រាយការណ៍................................................ ២

◆របាយការណ៍សាកសពប្រល័យពូជសាសន៍នៅខេត្តបាត់ដំបង................. ៦

◆លក្ខណៈសម្បត្តិ១០ "ខ" របស់បក្ស.......................................១២

◆សមមិត្ត គង់ ឬ សួង ស៊ីគៀន.......................................១៦

◆ទូរស័ព្ទសម្ងាត់.........................................................១៩

**ផ្នែកប្រវត្តិសាស្ត្រ**

◆សម្លេងពីមន្ទីរស-២១.....................................................២២

◆ការបំផ្លាញមូលដ្ឋានគ្រួសារក្នុងសង្គមខ្មែរ...............................២៦

**ផ្នែកច្បាប់**

◆ច្បាប់យុត្តិសាស្ត្រ.........................................................២៨

◆ដែនសមត្ថកិច្ចសកលនិងបញ្ហារួចទោសនៅកម្ពុជា.......................៣២

◆គំរូមួយនៃភ័ស្តុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់.....................៣៦

**វេទិកាពិភាក្សាជាសាធារណៈ**

◆ទស្សនៈខ្មែរក្រហមចំពោះទឹកដីកម្ពុជាក្រោម............................៤១

◆យុត្តិធម៌នៅកម្ពុជាត្រូវបានពន្យារពេល...................................៤៦

◆ភាពរួចទោសដែលគ្រប់គ្រងដោយអំណាច.................................៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ជនជាតិវៀតណាមស្វែងរកសាច់ញាតិ.....................................៥៤

◆យាយ "ជី"..................................................................៥៥

◆១៧ មេសា ជាដើមទំព័រសករាជនៃការនិរាសព្រាត់ប្រាស.......៥៨

**សិល្បៈខ្មែរក្រហម**

◆យើងខ្ញុំដឹងគុណអង្គការបដិវត្តន៍.................................គ្របក្រោយ












**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**រាក្សិនលេខនេះៈ** អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ប៊ែន ឃៀនិន, ដេវីត ឆេនដល័រ, ហ្វូលីយ៉ូ ហេលជ្រេស, ស៊ីវ ហេឌ័រ, ឈ ស៊ីវ ឡេង **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុឃឹម **និពន្ធនាយករងទី១ៈ** ដាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ, **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

***សំបុត្រៈ***

# ក្រោមព្រះនេត្រនៃព្រះពុទ្ធ

នៅក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ឆ្នាំ២០០០នេះ អតីតក្រុមមេដឹកនាំខ្មែរក្រហមមួយចំនួនរួមមាន អៀង សារី អៀង ធីរិទ្ធ រួមទាំងកូនចៅរបស់ខ្លួនដែលមាន ឡុង ណារិន ជាអាទិ៍បានរួមគំនិតគ្នាទៅកាន់បិណ្ឌនៅវត្តស្វាយពពែនៅក្នុងទីក្រុងភ្នំពេញ ។ វត្តនេះគឺជាកន្លែងដែលអ្នកទាំងបីធ្លាប់ត្រូវបានភ្នែកមហាជនខ្មែរប្រទះឃើញនៅក្នុងពិធីបុណ្យទានមួយ ។ ខ្ញុំគិតក្នុងចិត្តដោយកើតក្តីងឿងឆ្ងល់ថាតើមេដឹកនាំទាំងនេះគិតយ៉ាងដូចម្តេចនៅពេលដែលខ្លួនលើកដៃទាំងពីរប្រណម្យគោរពបួងសួងដល់ព្រះពុទ្ធបដិមានៅក្នុងចំណោមវត្តមាននៃព្រះសង្ឃជាច្រើនអង្គដែលពីមុនមករូបព្រះពុទ្ធបដិមានិងព្រះសង្ឃត្រូវបានក្រុមរបស់ខ្លួនកម្ទេចចោលទាំងស្រុងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥-៧៩ ។

ប្រសិនបើ អៀង សារី ឡុង ណារិន និង អៀង ធីរិទ្ធ ធ្វើការគោរពព្រះពុទ្ធបដិមានិងព្រះសង្ឃបែបនេះ តើទង្វើនេះនឹងអាចធ្វើឲ្យអតីតកាលរបស់អ្នកទាំងបីក្លាយទៅជាមនុស្សថ្មី ហើយខុសប្លែកគ្នាក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនោះដែរឬទេ? តើព្រះពុទ្ធបដិមានិងព្រះសង្ឃអាចជួយរំដោះអ្នកទាំងបីឲ្យរួចចាកផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋព្រៃផ្សៃយង់ឃ្នងទាំងពួងដែលខ្លួននិងកម្មាភិបាលខ្មែរក្រហមដទៃទៀតរួមគំនិតចូលដៃជើងប្រព្រឹត្តមកលើប្រជាជនខ្មែររាប់លាននាក់នោះដែរឬយ៉ាងណា? តើព្រះពុទ្ធបដិមាអាចប្រោសបាបកម្មរបស់ អៀង សារី អៀង ធីរិទ្ធ និង ឡុង ណារិន បានដែរឬទេ? ។ ឥឡូវនេះក្រុមមេដឹកនាំខ្មែរក្រហមទាំងអស់កំពុងតែស្ថិតនៅនិងរួមរស់ជាមួយយើងទាំងអស់គ្នា ហើយអំពើឧក្រិដ្ឋទាំងអម្បាលម៉ានរបស់ក្រុមនេះមកលើប្រជាជនកម្ពុជាក៏កំពុងតែស្ថិតនៅជាមួយយើងដែរ ។ បញ្ហាខ្មែរក្រហមនិងការកាត់ទោសមេដឹកនាំនៃរបបនេះមិនមែនជារឿងអតីតកាលទេ គឺជារឿងបច្ចុប្បន្នកាលដែលចាំបាច់ត្រូវប្រឈមមុខដោះស្រាយ ។

ឡុង ណារិន បានស្រែកប្រកាសថា ខ្លួនបានចូលបម្រើបដិវត្តន៍កាលពីមុនពីព្រោះចង់ធ្វើឲ្យប្រទេសជាតិមានឯករាជ្យនិងអភិវឌ្ឍន៍ ។ ចំណែកឯ អៀង សារី និង អៀង ធីរិទ្ធ ក៏មានទស្សនៈដូចគ្នាដូច្នេះដែរ ។ ខ្ញុំឆ្ងល់ថា តើអ្នកទាំងបីមានបំណងយ៉ាងណានៅពេលនិយាយបែបនេះក្នុងខណៈដែលខ្ញុំធ្វើការប្រៀបធៀបរវាងគោលបំណងរបស់មេដឹកនាំខ្មែរក្រហមដែលបានស្រែកប្រកាសជាមួយនឹងបទពិសោធន៍ផ្ទាល់ក្នុងជីវិតរបស់ខ្ញុំធ្លាប់បានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំបានឃើញផ្ទាល់នឹងភ្នែកនូវបុរសនិងស្ត្រីមួយគូដែលត្រូវបានសម្លាប់ដោយកម្មាភិបាលខ្មែរក្រហមនៅក្នុងពេលប្រជុំមហាជនមួយនៅខាងមុខទីវាលនៃវត្តព្រះនេត្រព្រះក្នុងស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ។ ខ្ញុំបានឃើញប្រជាជនរាប់រយនាក់ដាច់ពោះស្លាប់ដោយសារការបង្អត់អាហារដែលនៅក្នុងចំណោមនោះរួមមានទាំងបងស្រីបង្កើតរបស់ខ្ញុំផង ។ លើសពីនេះទៀតខ្ញុំបានចងក្រងរៀបចំជាឯកសារអំពីមនុស្សរាប់ម៉ឺននាក់ដែលបានស្លាប់បាត់បង់ជីវិតដោយសារការសម្លាប់ ការធ្វើទារុណកម្ម ការធ្វើពលកម្មដោយចាប់បង្ខំ ជំងឺ និងការបង្អត់អាហារក្រោមរបបខ្មែរក្រហម ។

ឡុង ណារិន អៀង សារី និង អៀង ធីរិទ្ធ ប្រកាសថា ខ្លួនមិនជឿទេថាមានមនុស្សជាងមួយលាននាក់បានបាត់បង់ជីវិតក្រោមរបបខ្មែរក្រហម ។ ខ្ញុំឆ្ងល់ថាតើអ្នកទាំងបីធ្លាប់បានទៅមើលគុកសម្ងាត់របស់ខ្លួនឈ្មោះថា “មន្ទីរស-២១” ដែលសព្វថ្ងៃនេះហៅថា“គុកទួលស្លែង” ជាកន្លែងអ្នកទោសជាងមួយម៉ឺននាក់ត្រូវបានឃុំឃាំងធ្វើទារុណកម្មនិងសម្លាប់ចោលនោះដែរឬទេ? អ៊ឹ ប្រុស វ៉ាន់ ណាតដែលជាអ្នកបានរស់រានមានជីវិតពីមន្ទីរស-២១ និងអតីតឆ្មាំនៃគុកនេះចំនួនបួនដប់នាក់ទៀតដែលសព្វថ្ងៃនេះកំពុងរស់នៅក្នុងខេត្តកណ្តាលនិងខេត្តកំពង់ឆ្នាំង គឺពិតជាអាចធ្វើជាសាក្សីឆ្លើយបំភ្លឺចំពោះអ្វីដែលបានកើតឡើងនៅមន្ទីរស-២១នេះយ៉ាងជាក់ច្បាស់ ។

ឡុង ណារិន បានអះអាងថា ខ្លួននិងក្រុមថ្នាក់ដឹកនាំខ្មែរក្រហមពុំជំទាស់នឹងការបង្កើតតុលាការខ្មែរក្រហមទេ ។ ខ្ញុំឆ្ងល់ថាតើក្រុមមេដឹកនាំខ្មែរក្រហមពិតជាបានយល់អំពីអ្វីដែលហៅថាយុត្តិធម៌ដែរឬយ៉ាងណា ។ យុត្តិធម៌នៅក្រោម ***(តទៅទំព័រទី១០)***

# ទុយ ផេង រាយការណ៍អំពីសកម្មភាពប្រឆាំងបក្សកុម្មុយនិស្តកម្ពុជា របស់ខ្លួនជូនអង្គការ

## *ប្រវត្តិនៃការប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជាមុនឆ្នាំ១៩៧០*

ទុយ ផេង ហៅ ផៃ ជាលេខាស្រុកកោះសូទិន តំបន់២២ ភូមិភាគបូព៌ា មានស្រុកកំណើតនៅភូមិកន្ទែងចក សង្កាត់មានស្រុកអូររាំងឳ តំបន់២២ ភូមិភាគបូព៌ា ។ ឪពុកឈ្មោះ ហែម ភិន ម្តាយឈ្មោះ ទុយ យឹម ។ តាមចម្លើយសារភាពរបស់ ទុយ ផេង នៅមន្ទីរ ស-២១ បានឲ្យដឹងថា នៅឆ្នាំ១៩៥៩ ទុយ ផេង បានឃើញកម្មាភិបាលមួយចំនួននាំយកមាគ៌ាបដិវត្តន៍មកផ្សព្វផ្សាយនៅតាមមូលដ្ឋានរបស់ខ្លួន ។ កម្មាភិបាលទាំងនោះគឺ ចាន់ សាមុត ហៅ សោ ភឹម និង តាំង ឡេង ។ ក្រោយពីទទួលបានការផ្សព្វផ្សាយហើយ ទុយ ផេង ក៏បានយល់ដឹងពីសភាពការណ៍បដិវត្តន៍ ។

បន្ទាប់មកទៀត កុល និង ចាន់ សាមុត បានមកអប់រំ ទុយ ផេង ដោយនិយាយថា «បានជាខ្ញុំអប់រំបញ្ចូលមិត្តធ្វើបក្សកុម្មុនិស្តកម្ពុជាមកពីខ្ញុំក្តាប់មិត្តឯងមិនបាន បើខ្ញុំក្តាប់មិត្តឯងបាន ហើយធ្វើការសកម្មដែរនោះទៅធ្វើស្អីជាមួយអាឆ្កួតទ្រឹស្តីនោះ ។ ដូច្នេះបានជាខ្ញុំបញ្ចូលមិត្តឯងជាបក្សជន បក្សឬមិនបក្សវាមិនធម្មតាអីទេ វាស្រេចតែគោលជំហររបស់យើងទេ ដែលយើងមើលឃើញជាប្រចាំ» ។ កុល បានបន្តទៀតថា «ខ្មែរសេរី គឺជាការទ្រទ្រង់មនុស្សនៅលើពិភពលោកដែលមានធាតុសេរី ។ ដូច្នេះហើយម្នាក់ៗបើនិយាយពីធាតុ អ្នកណាក៏សេរីដែរ ។ ហេតុនេះបានជាគេប្រកាសអង្គការខ្មែរសេរីនេះឡើង» ។ កុល បានបន្ថែមថា «បើយើងមិនធ្វើខ្មែរសេរីមិនបានទេពីព្រោះ សឺង ង៉ុកថាញ់ ដែលជាមនុស្សស្នេហាជាតិដែរ ពីមុនមានកាន់ខ្មែរសេរីថាក្បត់ជាតិ ។ ដូច្នេះបញ្ហានេះខ្មៅទៅជាស សទៅជាខ្មៅ ម្យ៉ាងទៀតឆ្នាំ១៩៦៣ ប្រទេសខ្មែរមិនទាន់មានការផ្ទុះអាវុធទេ ដោយឡែកប្រទេសវៀតណាមមានផ្ទុះអាវុធពេញទឹកពេញដី ហើយគេវាយគ្នាសុទ្ធតែអាបេ ។ ទោះជាយើងមានអាវុធក៏វាយមិនកើតព្រោះយើងខ្វះកម្លាំង ។ ហេតុនេះយើងត្រូវរកច្រកដើរទៅកន្លែងណាមួយបុកឯទ័ពខ្មែរសេរីមានការងាយស្រួលទីពឹងបរទេសឲ្យផ្តល់អាវុធ ។ ប្រជាជនលើសកលលោកអ្នកណាក៏សេរីដែរ ។ ប្រជាជនគេនិងប្រជាជនយើង អ្នកណាក៏ចង់ធ្វើដែរ តើមិត្តចង់ធ្វើទេ?» ។ ទុយ ផេង បានឆ្លើយតបវិញថា «ស្រេចតែបងទេ ព្រោះខ្ញុំនៅក្រោមការដឹកនាំរបស់បង» ។

ក្រោយពីបានចូលបម្រើក្នុងចលនាខ្មែរសេរី ទុយ ផេង បានទាក់ទងជាមួយគិញនៅចម្ការកៅស៊ូជប់ដើម្បីធ្វើសកម្មភាព




ខ្មែរសេរីដោយដើរតាមដានខ្មែរក្រហមរហូតដល់ឆ្នាំ១៩៦៦ ។ ទុយ ផេង បានស្គាល់ ទុំ (លេខាតំបន់២២ ភូមិភាគបូព៌ា) ហើយ ទុំ បានឲ្យ ទុយ ផេង ប្តេជ្ញាចិត្តចំពោះទង់សេ.អ៊ី.អា (ទង់ជាតិអាមេរិក) តាមការណែនាំថា «១) យើងខ្ញុំពួកក្រុមសេ.អ៊ី.អា ប្តេជ្ញាដាច់ខាតការពារក្រុមសេ.អ៊ី.អារបស់យើងក៏ដូចជាការពារប្រជាជនឲ្យបានរហូតទាល់តែអស់ជីវិត ។ ២) យើងរក្សាការណ៍

សម្ងាត់ឲ្យបានល្អជូនក្រុមសេ.អ៊ី.អា ។ ៣) ប្តេជ្ញារក្សាសាមគ្គីភាពក្នុងជួរប្រជាជនដែលរត់ដូចគ្នាដើម្បីលាក់ខ្លួនស៊ីរូងផ្ទៃក្នុងនិងដើម្បីឲ្យសម្រេចតាមសំណូមពររបស់ក្រុមយើង» ។

មកដល់ឆ្នាំ១៩៦៩ សកម្មភាពទាក់ទងតាមសំបុត្រពី ទុំ ទៅសាខាផ្សេងៗទៀតនិងមានសកម្មភាពទប់ទល់ជាមួយខ្មែរក្រហមដោយធ្វើការបំផុសប្រជាជននៅតាមមូលដ្ឋាន ។ ផែនការនេះធ្វើដើម្បីឲ្យប្រជាជនស្អប់ខ្ពើមខ្មែរក្រហម ។ រីឯសកម្មភាពកសាង




គ្រួសារកម្មាភិបាលខ្មែរក្រហមនៃមន្ទីរស-២១

កម្លាំងវិញ ទុយ ផេង កសាងបានម្នាក់ទៀតគឺ សំអុល ជាប្រធានមន្ទីរស្រុកអូររាំងឪ(តំបន់២២) ។ វិធីអប់រំបញ្ចូលសេ.អ៊ី.អា ដែល ទុយ ផេង បានធ្វើគឺនិយាយថា «ប្រទេសខ្មែរយើងពិតជាកើតមានសង្គ្រាមទៀត ហើយរដ្ឋអំណាចពិតជាធ្លាក់ទៅលើកណ្តាប់ដៃខ្មែរក្រហម បើកាលណាធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហមយើងស្លាប់ពីព្រោះយើងមិនដែលរស់នៅជាមួយគេ ។ ដូច្នេះយើងត្រូវចេះពិចារណាមើលខ្លួន យើងម្នាក់ៗត្រូវតែចេះគិតគូរនិងត្រិះរិះពិចារណាលើការកសាងប្រទេស លើការរកផ្លូវជឿនលឿនទៅមុខ ។ បើយើងមិនគិតពិចារណាទេសង្គមកម្ពុជាយើងនឹងមានការវិវត្តហើយ ។ បើវិវត្តទៅប្រហែលសង្គមសីហនុ វាធូរធារគ្រាន់បើជាងមុន ។ បើវិវត្តទៅសង្គមខ្មែរក្រហម វាធ្វើបាបយើងឲ្យធ្វើការងារគ្មានឈប់ ហើយរដ្ឋប្រមូលអស់ ។ ហេតុនេះយើងត្រូវគិតគូរឲ្យបានជ្រៅជ្រះលើបញ្ហានេះក្នុងនាមយើងជាប្រជាជនមួយរូប» ។

## សកម្មភាពប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជា នៅក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ដល់មុនរំដោះឆ្នាំ១៩៧៥

ក្រោយរដ្ឋប្រហារភ្លាម ទុយ ផេង បានឃោសនាប្រជាជនដែលខ្លួនទុកចិត្តថា «កុំអាលអរ រដ្ឋប្រហារប៉ុណ្ណឹងនេះដោយសារគុណរបស់ លន់ ណុល ទេ បើខ្មែរក្រហមមិនដឹងឆ្នាំណាទេ ។ ឥឡូវមីងពូចាំមើលសិន កុំអាលជ្រួលច្របល់អីធ្វើយ៉ាងណាទៅឲ្យនឹង» ។ មិនតែប៉ុណ្ណោះ ទុយ ផេង បានបន្ថែមថា «អ្នកណាដែលធ្លាប់ធ្វើបដិវត្តន៍ពីមុនត្រូវដេញចេញ ឧទាហរណ៍ដូចជាបងៗរដ្ឋមន្ត្រីមួយចំនួនម្តងបាត់ឈ្មោះ ម្តងព្រួសូរឈ្មោះ ។ ហេតុនេះមិនដឹងពីណាពីណីទេ ។ រដ្ឋាភិបាលដែលចាត់តាំងឡើងដូចជាគ្មានទិសដៅជាមូលដ្ឋាន ។ ព្រួសូរថារដ្ឋមន្ត្រីនេះ កុង្សីនោះ ហើយបើការងាររបៀបខ្មែរក្រហមវិញ ការចាត់តាំងគឺគ្មានរូបភាពទេ ដូចជាចាត់តាំងរដ្ឋមន្ត្រី ប្រកាសបង្កើតរដ្ឋាភិបាលឃើញមានយកពួកសីហនុមកតែងតាំង មាន ប៉ែន នុត មាន ដួង សំអុល ។ ដូច្នេះបញ្ហានេះយើងក្តាប់មិនបានទេ ហើយតាមមិនទាន់បាតដៃជាខ្នងដៃ ។ ពីមុនសីហនុ ខ្មែរក្រហមថាអត់យកទេ តែឥឡូវថាយកសីហនុមកវិញឲ្យធ្វើជាប្រធានរណសិរ្ស ។ មីងពូបងប្អូនគិតមើលតើរឿងនេះយ៉ាងម៉េច? គឺរឿងទាល់ច្រករបស់ខ្មែរក្រហម» ។ ក្នុងឆ្នាំ១៩៧០ ផែនការដែល ទុំ បានដាក់ចុះមានដូចជា ១) យើងត្រូវក្តាប់ប្រវត្តិរូបសមាសភាពនៅតាមភូមិនីមួយៗដើម្បីយើងមានជំហរកៀរគ មិនមែនចេះតែកៀរគទេ ចៀសវាងកុំឲ្យបែកការណ៍ ។ ២) កសាងកម្លាំងប្រយុទ្ធជាប់ខាតដើម្បីឲ្យបានសម្រេចទៅតាមសំណូមពររបស់យើង ហើយកុំធ្វើព្រងើយកន្តើយពីព្រោះសភាពការណ៍បដិវត្តន៍កាន់តែជិតមកដល់

ហើយ ដូច្នេះយើងត្រូវប្រយុទ្ធឲ្យខ្លាំងក្លាដោយយកការងារបដិវត្តន៍ធ្វើជារនាំងបាំង ។ ៣) មុននឹងកសាងកម្លាំងបញ្ចូលត្រូវរាយការណ៍ឲ្យថ្នាក់លើ(ទុំ)ដឹងមុនដើម្បីពិនិត្យប្រវត្តិរូបឲ្យបានច្បាស់លាស់» ។

នៅឆ្នាំ១៩៧១ ទុយ ដេង បានលាក់ទុកអាវុធចំនួន១០០ ដើមតាមការណែនាំរបស់ ទុំ ដើម្បីត្រៀមក្បត់បដិវត្តន៍ពេលដែលមានសភាពការណ៍អ្វីកើតឡើង ។ សភាពការណ៍នៅក្នុងប្រទេសធ្វើឲ្យប្រជាជនអត់បាយអត់ទឹក ហើយយួនក៏បានចូលមកឆានៅក្នុងទឹកដីកម្ពុជាដែរ ។ ទុយ ដេង បានអប់រំប្រជាជនថា «រឿងនេះមិនមែនមកពី លន់ ណុល មិនមែនមកពីអាមេរិកទេ គឺមកពីខ្មែរក្រហមទើបបានមានយួនចូលមកឈ្លានពានទឹកដីយើង ហើយខ្មែរក្រហមនេះហើយដែលនាំសង្គ្រាមមក ។ ដូច្នេះបញ្ហាអត់ស្រូវអត់អង្ករក៏មកតែពីខ្មែរក្រហមដែរ ។ យើងត្រូវតស៊ូខ្លះទៅដើម្បីវាយរំលំពួកនេះ» ។

នៅឆ្នាំ១៩៧២ ទុយ ដេង បានផ្លាស់ទៅនៅស្រុកស្រីសន្ធរតាមការចាត់តាំងរបស់ ទុំ ដើម្បីបង្កើតជាសន្តិសម័ន្ធវាយសមរភូមិក្រោយនិងបង្អាក់សមរភូមិមុខ ។ ចំពោះសភាពការណ៍ស្រុកទេសពេលនោះ ភូមិណាក៏មានឮសូរអាវុធផ្ទុះទាំងយប់ទាំងថ្ងៃដែរ ហើយមានចោរលួចនៅតាមភូមិទៀតផង ។ ក្នុងការឃោសនា ទុយ ដេង បានអប់រំថា «កុំឃើញបដិវត្តន៍ប៉ុណ្ណឹងថាឈ្នះ វាមិនឈ្នះទេថ្ងៃក្រោយរដ្ឋអំណាចបានទៅលើដៃអ្នកដទៃ ។ ជោគជ័យនេះដោយសារតែពួក លន់ ណុល ទេ» ។

នៅឆ្នាំ១៩៧៣ ទុំ បានហៅ ទុយ ដេង និងបក្សពួកមកប្រជុំនៅមន្ទីរព្រែកចង្ក្រាន ឃុំល្វេ ស្រុកស៊ីធរកណ្តាល ខេត្តកំពង់ចាម ។ ខ្លឹមសារប្រជុំ ទុំ បានលើកឡើងថា «នៅវៀតណាមនិងនៅលាវគេបានចរចាគ្នា ហើយវៀតណាមគេធ្លាប់ធ្វើសង្គ្រាមជាមួយអាមេរិករាប់ឆ្នាំមកហើយ ។ ចំពោះយើងវិញ យើងអត់មានការពិសោធន៍ក្នុងការធ្វើសង្គ្រាមជាមួយអាមេរិកទេ ហើយអាវុធក៏មានការខ្វះខាតទៀត ។ ប៉ុន្តែអង្គការនៅតែដាច់ខាតៗ (មិនព្រមចរចា) ។ បើគ្មានអាវុធគ្រាប់រំសេវទៅឯណារួច ដាច់ខាតៗ ស្លាប់តែកូនប្រជាជន ស្លាប់យុទ្ធជននិងកម្មាភិបាលអស់ ។ ដូច្នេះតាមខ្ញុំពិនិត្យមើលវាមិនឈ្នះទេ ព្រោះទំហំសង្គ្រាម អាវុធគ្រាប់រំសេវតិចតួច ហើយប្រទេសយើងតូចទៀត ។ យើងកុំដាច់ខាតពេក បើដាច់ខាតពេកស្លាប់ប្រជាជនអស់ហើយ មិនស្លាប់យើងទេ ដូច្នេះដើម្បីទប់ទល់នឹងផែនការដាច់ខាតនិងផែនការចេះតែវាយប្រថុយប្រថានយើងត្រូវរៀបចំកម្មវិធីកុំឲ្យអង្គការចេះតែដាច់ខាត» ។

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៣ ក្រុមសេ.អ៊ី.អា មានផែនការដើម្បីប្រឆាំងនឹងបដិវត្តន៍ដោយទាមទារឲ្យអង្គការទៅចរចាជាមួយវៀតណាមនៅទីក្រុងប៉ារីស ហើយលើកពាក្យស្លោកថា «សូមឲ្យអង្គការចរចាជាមួយវៀតណាមឈប់ច្បាំងតទៅទៀត បើកាលណាច្បាំងគ្នាទៀតស្លាប់ប្រជាជនអស់ហើយ» ពេលនោះ ទុយ ដេង បានសរសេរសំបុត្រហៅគ្រប់ប្រធានៗឃុំចំនួន១៤ នាក់មកប្រជុំដើម្បីផ្សព្វផ្សាយអំពីផែនការរបស់ ទុំ ជំរុញឲ្យអង្គការចរចា ។ ប៉ុន្តែផែនការធ្វើបាតុកម្មទាមទារឲ្យអង្គការចរចាត្រូវបរាជ័យដោយសារមហាជនដែលល្អជាមួយបដិវត្តន៍បានជួយទប់ទល់ ។

នៅឆ្នាំ១៩៧៤សកម្មភាពប្រជាជនក៏កាន់តែមានការរំដើបរំជួលចំពោះផែនការសន្តិសម័ន្ធ ។ ចំណែកសកម្មភាពរបស់បដិវត្តន៍ក៏មានសន្ទុះខ្លាំងដែរ ។ ក្នុងពេលជាមួយគ្នានោះ ទុយ ដេង បានខិតខំអប់រំប្រជាជនជាទូទៅឲ្យប្រឆាំងនឹងចលនាបដិវត្តន៍ខ្មែរក្រហមដោយឲ្យប្រជាជនកុំខ្វាយខ្វល់ពីសមរភូមិមុខធ្វើយ៉ាងណាគិតតែពីរកស៊ីនិងឲ្យកូនចៅទៅធ្វើស្រែចំការបានហើយ ។

លុះមកដល់ឆ្នាំ១៩៧៥ ទុយ ដេង បានឆ្កឹះឆ្កៀលបំបែកបំបាក់សាមគ្គីភាពរវាងកងទ័ពនិងរដ្ឋអំណាចរវាងរដ្ឋអំណាចនិងកងទ័ព ហើយធ្វើឲ្យប្រជាជនស្អប់កងទ័ពនិងធ្វើយ៉ាងណាដើម្បីរារាំងដល់ផែនការបដិវត្តន៍ ។ ជាក់ស្តែង ទុយ ដេង បានណែនាំប្រជាជនថា«កុំឲ្យកូនចៅទៅស្លាប់នៅសមរភូមិមុខព្រោះស្លាប់តែកូនចៅយើងទេមិនមែនស្លាប់កូនចៅអង្គការទេ» ។

## សកម្មភាពក្រោយរំដោះឆ្នាំ១៩៧៥រហូតដល់ពេលត្រូវចាប់ខ្លួន

ពេលដែល ទុយ ដេង បានទទួលភារកិច្ចពីអង្គការឲ្យជម្លៀសប្រជាជន ទុយ ដេង បានឃោសនាប្រាប់ប្រជាជនថា «ជម្លៀសគ្នាបែកកូនបែកចៅ ស្លាប់តាមផ្លូវដូចសត្វធាតុ គ្មានអណិត

អាសូរដល់មនុស្សដូចគ្នា ។ ធ្វើយ៉ាងនេះស្លាប់មនុស្សអស់ហើយ ប្រជាជនបែកប្តីសី កូនចៅ ម៉ែឪ ដើរស្លាប់តាមព្រៃមិនស្គាល់ផ្ទះសម្បែងមិនដឹងបាយទឹកឯណាទេ ។ អួតថាអាណិតប្រជាជន តែជម្លៀសប្រជាជនមកឲ្យស្លាប់ ។ មើលទៅកន្លែងណាក៏ឃើញប្រជាជនជម្លៀសមិនដឹងទៅណាមកណា គ្មានទិសដៅ គ្មានការទទួលខុសត្រូវ» ។ ផែនការប្រជុំនៅស្រុកពញាក្រែក តំបន់២១ ដើម្បីផ្តួលរំលំបដិវត្តន៍ខ្មែរក្រហមបានប្រកាសឲ្យស្គាល់កម្លាំងតាមភូមិភាគដែលត្រូវទាក់ទងគ្នានៅពេលប្រយុទ្ធ ។ ផែនការនេះត្រូវគ្រោងអនុវត្តនៅខែកក្កដាបើមិនសម្រេចត្រូវធ្វើនៅខែកញ្ញា ឆ្នាំ១៩៧៥ ។ ប៉ុន្តែផែនការទាំងពីរលើកនេះមិនបានសម្រេចទេ ដោយសារមានភាពរកេតរកូតក្នុងការរៀបចំកម្លាំងមិនបានល្អ ។

នៅឆ្នាំ១៩៧៦ក្រុមសេ.អ៊ី.អាបាននាំគ្នាប្រជុំម្តងទៀតនៅស្រុកត្បូងឃ្មុំដែលសមាសភាពចូលរួមមានចំនួន២៣នាក់ ។ ផែនការប្រជុំបានលើកឡើងថា «យើងវាយពីស្វាយរៀងមកអ្នកលឿងដែលមានកងពលលេខ៣ដឹកនាំដោយ ហាក់ ស ចំរើន និង សូ ដោយរួមផ្សំកងទ័ពតំបន់២៤ដឹកនាំដោយ ឈូក វាយតាមផ្លូវជាតិលេខ១បុកចូលមកភ្នំពេញតែម្តង ។ មួយផ្នែកទៀត ឈាន និង ស៊ុន ជាមេបញ្ជាការរួមវាយពីផ្លូវជាតិលេខ៧ឆ្ពោះមកផ្លូវលេខ១៥ ហើយវាយបុកចូលតំបន់២២ដើម្បីដណ្តើមយកអរិយក្សត្រនិងស្វាយជ្រុំតែម្តង ។ កម្លាំងកាំភ្លើងធំខ្លះរួមផ្សំកម្លាំងពីខាងត្បូងមួយកងពលផង ។ កម្លាំងនៅជ្រោយចង្វាមានមួយវរសេនាធំដឹកនាំដោយ ស៊ីម និង នួន ដោយវាយបុកចូលមកភ្នំពេញតែម្តង ។ នៅភូមិភាគឧត្តរដឹកនាំដោយ ស្រេង ទទួលខុសត្រូវនាំទ័ពពីរកងពលឡើងតាមព្រែកក្តាមមកចាប់ដៃជាមួយកម្លាំងផ្សេងៗទៀតនៅភ្នំពេញ ។ ផែនការវាយប្រហារនេះត្រូវធ្វើនៅថ្ងៃបុណ្យខួបថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦» ។


ម៉ម ណៃ ហៅ ចាន់

ប៉ុន្តែផែនការនេះត្រូវបរាជ័យទាំងស្រុងដោយអង្គការក្តាប់បាននិងចាប់កម្លាំងក្បត់បានមួយចំនួន ។ ទោះជាយ៉ាងនេះក្តី ចលនាដែលនៅសេសសល់មានចំនួន៨កងធំៗដែលមាន ឈាន ជាអ្នកទទួលខុសត្រូវរួមនៅតំបន់២២នៅតែព្យាយាមរកវិធីផ្តួលរំលំរដ្ឋអំណាចបដិវត្តន៍តទៅទៀត ។

ចូលមកដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ ទុយ ផេង ត្រូវបាន ឈាន ហៅទៅណែនាំថា «យើងកុំអស់សង្ឃឹមផែនការរបស់យើង ចាំមើលយើងវាយនៅឆ្នាំ១៩៧៧ គឺវាយមួយព្រឹបឲ្យឈ្នះតែម្តង វាយលើកនេះយកជើងទឹកធ្វើជាមូលដ្ឋានដោយបញ្ជាពីខាងជើងទឹកនៅជ្រោយចង្វាដែលមាន ទុំ និង ស៊ីម ជាអ្នកទទួលខុសត្រូវ ។ ហើយរបៀបវាយពិសេសដោយគ្រាប់បែកដៃព្រោះប្រើកម្លាំងតិច ។ ធ្វើផែនការឆ្នាំនេះមិនឲ្យបរាជ័យទេ ហើយវាយយកជ័យជម្នះទាំងស្រុងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៧» ។ ការប្រជុំដាក់ផែនការលើកនេះមិនបានចូលរួមទាំងអស់គ្នាទេ គឺគ្រាន់តែមានតំណាងមកប្រជុំប៉ុណ្ណោះ ។ ប៉ុន្តែផែនការលើកនេះក៏នៅតែមិនបានសម្រេច ហើយ ទុយ ផេង ត្រូវបានអង្គការចាប់ខ្លួនពេលកំពុងធ្វើសកម្មភាព ។

យោងតាមឯកសារចម្លើយសារភាពលេខៈJ៨៥២ របស់ ទុយ ផេង នេះអាចកត់សម្គាល់បានថា ទុយ ផេង ហៅ ដៃ (លេខាស្រុកកោះសូទិននៅភូមិភាគបូព៌ា) ឆ្លើយសារភាពពីសកម្មភាពក្បត់របស់ខ្លួនជូនអង្គការដូចបានសង្ខេបខាងលើ ។ ឯកសារនេះសរសេរដោយអក្សរអង្គុលីលេខ ចប់នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៧ ចំនួន៥៨ទំព័រ ។ ក្រោមការសួរចម្លើយដោយក្រុម «ក» គឺសមមិត្ត ឈិន និងសមមិត្ត វ៉ុន នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៧ ។ ទាក់ទិននឹងអ្នកដែលចូលរួមធ្វើសកម្មភាពក្បត់មានចំនួន៨៦នាក់ដែលសុទ្ធតែមានគូសចំណាំទាំងអស់ ។ ចំណុចសំខាន់នៃឯកសារនេះគឺមានស្នាមមេដៃរបស់សាមីជនសារភាពអមដោយហត្ថលេខារបស់អ្នកសួរចម្លើយទាំងពីរនាក់នោះ ។ ក្រោយពីឯកសារនេះចងក្រងរួចក៏បានបញ្ជូនទៅថ្នាក់លើៗទៀត ។ នៅលើឯកសារនេះមានចំណារថា «១) ជូនបងពិនិត្យ ២) ជាប់ឈ្មោះសមមិត្ត ឈាន ទ.២២ (ទទួលខុសត្រូវតំបន់២២) បច្ចុប្បន្នៗ ៣) ឈ្មោះឯទៀតដកទៅ១១-១១-៧៧» «ជូនបូព៌ាតាមស.ម(សមមិត្ត) ចាន់ ១២-១១-៧៧ ២ច្បាប់» ។

**ឡុង សុភារិទ្ធ**

# រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តបាត់ដំបង



ការចុះធ្វើផែនទីរណ្តៅសាកសពនៅខេត្តបាត់ដំបងក្នុងឆ្នាំ ១៩៩៧ប្រព្រឹត្តទៅក្នុងស្រុកចំនួន៣ គឺស្រុកមោងឫស្សី ស្រុកឯកភ្នំនិងស្រុកបាណន់ ។ ការចុះស្រាវជ្រាវនេះប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣០ ខែមេសារហូតដល់ថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៩៧ ។

## ស្រុកមោងឫស្សី

### ១) វត្តតាលាស់ចាស់:

ជាទីតាំងសន្តិសុខ ទីតាំងសម្លាប់ និងជាទីតាំងតម្កល់អដ្ឋិធាតុជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិវត្តចាស់ ឃុំតាលាស់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដែលមានចម្ងាយ១១គីឡូម៉ែត្រពីសាលាស្រុកមោងឫស្សី ភាគខាងកើត ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក (Global Positioning System) បង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែស្របប១២°៤៨'៤៤៩៨"និងខ្សែបណ្តោយ១០៣°២៣'១៣០៤" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ២០៦០១/២/៣និងលេខឯកសារ R០៥០២០៣A ។ ទីតាំងនេះត្រូវបានចុះទៅដល់នៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៩៧ វេលាម៉ោង ១១:០០នាទីព្រឹក ។

តាមការសម្ភាសន៍លោក ហ៊ុយ គ្រឹម បានឲ្យដឹងថា សម័យប៉ុល ពត លោករស់នៅភូមិរាមគណៈ ឃុំរាមគណៈ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ប្រភេទជនរងគ្រោះភាគច្រើនគឺអ្នកជម្លៀសចេញពីទីក្រុង គ្រួសារអ្នកមាន នាយទុន មន្ត្រីរាជការស៊ីវិល អ្នកខុសសីលធម៌ អ្នកដើរលួចស៊ីផ្តេសផ្តាស ។ល។ មួយចំនួនទៀត គឺក្មេងៗដែលត្រូវចាប់ខ្លួនមកជាមួយឪពុកម្តាយដែលមានកំហុស ។ ទីនោះខ្មែរក្រហមសម្លាប់តែពួកមន្ត្រីធំៗ សាស្ត្រាចារ្យ បញ្ញវ័ន្ត វេជ្ជបណ្ឌិត គ្មានទាហានទេ។ ខ្មែរក្រហមយកកុដិលោកធ្វើជាកន្លែងរស់នៅនិងយកព្រះវិហារធ្វើជាមន្ទីរសន្តិសុខនិងគុក ហើយប្រជាជនត្រូវបាននាំយកទៅសម្លាប់ចោលនៅតាមជាយរបងជុំវិញវត្តក្បែរៗព្រះវិហារចម្ងាយប្រហែល៥០ម៉ែត្រ ។ នៅជុំវិញវត្ត តាមរបងនិងក្បែរព្រះវិហារមានសុទ្ធតែរណ្តៅដែលបច្ចុប្បន្ននៅមិនទាន់លប់អស់នៅឡើយទេ ។ ក្រោយឆ្នាំ១៩៧៩ លោក ហ៊ុយ គ្រឹម មកមើលប្រជាជនគាស់កកាយរកមាស ពីររណ្តៅទំហំ៤ម៉ែត្របួនជ្រុង រណ្តៅតូចៗជាច្រើននិងរណ្តៅទ្រវែងដូចប្រឡាយក៏មាន អាចថារាប់រយរណ្តៅ ។

ការសម្លាប់នៅទីនោះចាប់ពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៧៨ ដូច្នេះរយៈពេលនៃការសម្លាប់៣ឆ្នាំ ។ បើតាមការឃើញឆ្អឹងនិងតាមរយៈសាក្សីអាចសន្និដ្ឋានថា ជនរងគ្រោះស្លាប់នៅទីនោះមានចំនួនប្រហែលពី៥០០នាក់ទៅ៦០០នាក់ ។ ការស្មាននោះមិនទាន់សុក្រឹតទេព្រោះការសម្លាប់ក្នុងរយៈពេល៣ឆ្នាំ ចំនួនអាចលើសពីនេះទៅទៀត ។ ភស្តុតាងនៅទីនោះគឺឆ្អឹងរបស់ជនរងគ្រោះត្រូវបានលោកអាចារ្យវត្ត ព្រះសង្ឃ និងមន្ត្រីឃុំ រៀបចំតម្កល់លើស្តូបតូចមួយសង់ខ្ពស់ពីដីសម្រាប់ធ្វើបុណ្យចងកំហឹងថ្ងៃទី២០ ខែឧសភា ដែលនឹងប្រារព្ធឡើងជារៀងរាល់ឆ្នាំ ។

### ២) វត្តជ្រៃ:

ជាទីតាំងតម្កល់អដ្ឋិធាតុជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិជ្រៃ ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដែលមានចម្ងាយ៣គីឡូម៉ែត្រពីសាលាស្រុក ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក បង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែស្រប១២°៤៦'៥០៥១" និងខ្សែបណ្តោយ១០៣°២៨'២០៤៥" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ២០៦០៤និងលេខឯកសារ

R០៥០២០៤A ។ ទីតាំងនេះត្រូវបានចុះទៅដល់នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៩៧ វេលាម៉ោង១១ៈ២៥នាទីព្រឹក ។

លោក ហ៊ុយ ក្រឹម បានឲ្យដឹងថានៅវត្តជ្រៃមានមន្ទីរពេទ្យខ្មែរក្រហមមួយក៏ជាកន្លែងសម្លាប់ដែរព្រោះគ្មានថ្នាំសង្កូវអ៊ីទេ ស៊ីរ៉ូមចាក់គឺទឹកដូងដូង វះកាត់ស្រស់ៗគ្មានថ្នាំសន្លប់ ហើយថែមទាំងបង្អត់អាហារចំពោះអ្នកជំងឺដែលត្រូវបានកម្មាភិបាលខ្មែរក្រហមចោទប្រកាន់ថាពុតត្បុត ពុតទន្សាយ ហើយយកទៅសម្លាប់ចោលដោយយកលេសថា“ទុកមិនចំណេញដកចេញក៏មិនខាត” ។ អដ្ឋិធាតុគាស់ពីរណ្តៅជុំវិញបរិវេណវត្តមានចំនួនប្រហែលពី១០០ទៅ២០០នាក់យកមកតម្កល់ទុកនៅខ្ទមដ៏ចាស់ទ្រុឌទ្រោម ប៉ុន្តែបាត់បង់អស់ខ្លះទៅហើយ ។

### ៣) វត្តធម្មយុត្តិៈ

ជាទីតាំងគុកនិងទីតាំងសម្លាប់ជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិវៀមឃុន ឃុំគារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង មានចម្ងាយ១គីឡូម៉ែត្រពីសាលាស្រុក ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកបង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែស្រប១២º ៤៦'២១០៦"និងខ្សែបណ្តោយ១០៣º២៧'១៨៥៩" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ២០៦០៥/៦និងលេខឯកសារ R០៥០២០៤B ។ ទីតាំងនេះត្រូវបានចុះទៅដល់នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៩៧ វេលាម៉ោង១១នាទីព្រឹក ។

លោក ហ៊ុយ ក្រឹម បានបញ្ជាក់ថា ក្នុងសម័យ ប៉ុល ពត គាត់រស់នៅក្បែរវត្តនោះ ហើយបានមកចូលក្នុងវត្តឃើញជាក់ស្តែងនូវសកម្មភាពរបស់ពួកខ្មែរក្រហមកំពុងឆាថ្លើមមនុស្សស៊ីជាអាហារ ។ ខ្មែរក្រហមបានហៅគាត់ឲ្យបរិភោគថ្លើមមនុស្សដែរ តែគាត់ប្រកែក ។ គុកធ្វើជារបៀបរោងដែលមានទទឹង១៥ម៉ែត្របណ្តោយ៦០ម៉ែត្រ ។ ជនរងគ្រោះដែលជាប់ទីនោះត្រូវបានដាក់ខ្នោះជើងជាជួរៗដែលពួកខ្មែរក្រហមបានប្រមូលមកពីគ្រប់សហករណ៍នានាទូទាំងឃុំនិងស្រុក ។ ជនរងគ្រោះទាំងនេះត្រូវបានយកទៅសួរចម្លើយលើព្រះវិហាររួចយកទៅសម្លាប់ចោលនៅខាងមុខព្រះវិហារតែម្តង ។ ប្រភេទជនរងគ្រោះនៅទីនោះត្រូវបានចម្រាញ់យកពីគ្រួសារអ្នកមាន នាយទុន ប្រពន្ធអ្នកធំ សិស្សត្រឹមចាប់ពីថ្នាក់អនុវិទ្យាល័យឡើងទៅ បញ្ញាជន មន្ត្រីធំៗនិងអ្នកខុសសីលធម៌ ហើយក៏មានក្មេងៗត្រូវបានសម្លាប់ដែរព្រោះតែខុសឆ្គងបន្តិចបន្តួចក្នុងការលួចស៊ីផ្តេសផ្តាសដើម្បីចម្អែតក្រពះ ។ ការសម្លាប់នៅវត្តធម្មយុត្តិប្រព្រឹត្តទៅជារៀងរាល់ថ្ងៃចាប់ពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៧៨ ។ ប៉ុន្តែការសម្លាប់យ៉ាងខ្លាំងក្លាបំផុតក្រោយពេលដែលខ្មែរក្រហមបានបង្កើតគុកហើយក្នុងខែ១១និងខែ១២ ឆ្នាំ១៩៧៨ ។ កន្លែងសម្លាប់ដ៏ធំមួយស្ថិតនៅ



ព្រះវិហារវត្តគាលាស់ចាស់

វត្តធម្មយុត្តិ ភូមិរាមគណៈ ឃុំគារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង បច្ចុប្បន្នហៅថាវត្តបុប្ផាវតី ដែលមានចម្ងាយពីសាលាស្រុកមោងឫស្សី ១គីឡូម៉ែត្រ ។ ចំណែកឯទីតាំងគុក (ព្រះវិហារនិងរោង)ក៏ជាទីតាំងសម្លាប់ដែរ ។ ទីនោះមានរណ្ដៅជាច្រើននៅជាយរបងវត្តខាងមុខព្រះវិហារផ្នែកខាងស្ដាំដៃនៃព្រះវិហារមានរណ្ដៅធំៗបួនម៉ែត្របួនជ្រុងជម្រៅប្រហែល១ម៉ែត្រកន្លះទៅ២ម៉ែត្រ ។ ផ្ទាល់ភ្នែកពេលដែលខ្មែរក្រហមវាយសម្លាប់មនុស្សម្ដងៗដោយបណ្ដើរចុះពីលើព្រះវិហារម្ដងមួយៗ អ្នកសម្លាប់ចាំតែសម្លាប់ ។ នៅកន្លែងសម្លាប់មានរណ្ដៅធំទំហំ២០ម៉ែត្របួនជ្រុង ទាល់តែសម្លាប់ពេញរណ្ដៅទើបកប់ម្ដង ឈាមហូរពាសពេញដី ។ ពេលសម្លាប់រួចខ្មែរក្រហមបានយកពូថៅពុះទ្រូងជនរងគ្រោះបារយកថ្លើមដាក់ធុង រួចយកទៅឆាស៊ីគួរឲ្យខ្លោចផ្សារណាស់ ។



វត្តជ្រៃ(អតីតគុកខ្មែរក្រហម)

លោក ហាក់ សុផល អតីតកងចល័តពួកខ្មែរក្រហម បានមកនៅជុំវិញក្បែរវត្តនោះនៅឆ្នាំ១៩៧៥(អាចចេញចូលបានក្នុងវត្ត) ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៦មក ឈ្លបខ្មែរក្រហមនៅទីនោះហាមប្រជាជនមិនឲ្យចូលក្នុងវត្តទៀតឡើយ ។ មានថ្ងៃមួយពួកសន្តិសុខបានខ្ចីចបកាប់ពីកងចល័ត ពេលគាត់ទៅយកចបកាប់មកវិញគាត់បានឃើញពួកខ្មែរក្រហមទាំងនោះកំពុងតែឆាថ្លើមមនុស្សស៊ី ហើយឃើញមានហាលប្រមាត់មនុស្សជាច្រើនមានប្រហែលពី៥០ទៅ៦០ប្រមាត់ ។ គាត់បានឃើញចំពោះជនរងគ្រោះស្ត្រីភេទត្រូវពួកខ្មែរក្រហមសម្រាតនលគកហើយពួកខ្មែរក្រហមសើចលេងហ៊ោកញ្ជ្រៀវសប្បាយគិលៗ ។ ប៉ុន្តែក្រោយមកខ្មែរក្រហមក៏លែងឲ្យលោក សុផល នៅជុំវិញកងចល័តនៅក្បែរវត្តនោះទៀត ។

លោក សុផល បានសន្និដ្ឋានថា ចំពោះរណ្ដៅធំៗក្នុង១រណ្ដៅមានសាកសពពី៦០ទៅ១០០នាក់ ឯរណ្ដៅតូចៗដែលមានជនរងគ្រោះពី២ទៅ៣នាក់ក៏មាន ។ ក្រោយឆ្នាំ១៩៧៩ គាត់បានឃើញឆ្អឹងលលាដ៍ក្បាលចំនួនប្រហែល៣០០និងមានឆ្អឹង

ជាច្រើននៅពាសពេញរាយប៉ាយរាប់មិនអស់ដោយសារតែប្រជាជនជីកកកាយរកមាស ។ អដ្ឋិធាតុទាំងនោះត្រូវបានយកមកតម្កល់ទុកនៅគល់ស្ពានមោង ។ ប៉ុន្តែក្រោយមកត្រូវមនុស្សលួចជុតបំផ្លាញអស់ ។

លោក ហាក់ សុផល បានបញ្ជាក់បន្ថែមថា នៅគុកវត្តធម្មយុត្តិ ចម្ងាយ១០០ម៉ែត្រពីសាលាស្រុកមោងឫស្សី ពួកខ្មែរក្រហមបានឃុំក្មេងៗដោយឡែក ចាស់ៗដោយឡែក ។ ក្មេងៗត្រូវសម្លាប់ដោយវាយនឹងដើមឫស្សី ចាក់នឹងចំពុះទុងនិងត្រូវចងដៃទាំងអស់ ។ ចំពោះមនុស្សចាស់ត្រូវខ្មែរក្រហមវាយសម្លាប់នឹងត្បូងចប ហើយអូសទៅទម្លាក់ចោលពាសពេញក្នុងប្រឡាយទឹកក្បែរៗនោះ ។ ការប៉ាន់ស្មានរបស់លោក សុផល ជនរងគ្រោះមានចំនួនប្រហែលពី៥០ទៅ១៥០នាក់ ។

**៤) ភូមិពោធិ១៖**

ជាទីតាំងសម្លាប់ជនរងគ្រោះនៅក្រោមរបបខ្មែរក្រហម ទីតាំងនេះស្ថិតនៅក្នុងភូមិពោធិ១ ឃុំគារ ស្រុកមោងឫស្សី ខេត្តបាត់ដំបងដែលមានចម្ងាយ៣០០ម៉ែត្រខាងកើតសាលាស្រុក ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោកបង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែស្របទ១២°៤៦'៣៤០៤" និងខ្សែបណ្តោយ១០៣°២៦'៥៣៥៤" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ ២០៦០៧ និងលេខឯកសារ R០៥០២០៥A ។ ទីតាំងនេះត្រូវបានចុះទៅដល់នៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៩៧ វេលាម៉ោង១៖០០នាទីរសៀល ។

លោក ហាក់ សុផល បានបញ្ជាក់ថាទីតាំងសម្លាប់នៅភូមិពោធិ១មានផ្ទះថ្មមួយសម្រាប់ដាក់ជនរងគ្រោះដែលរត់ចូលទៅវៀតណាមនៅឆ្នាំ១៩៧៩ ។ ពេលវៀតណាមចូលមកសហការជាមួយរណសិរ្សសាមគ្គីសង្គ្រោះជាតិវាយខ្មែរក្រហមចូលមកដល់កន្លែងនេះ ។ បន្ទាប់ពីកងទ័ពរំដោះដកថយទៅវិញ ប្រជាជនដែលបានរត់ចូលទៅរកទ័ពខ្មែររំដោះត្រូវខ្មែរក្រហមបានចាប់បានចំនួន៥០គ្រួសារដោយយកមកឃុំទុកមួយរយៈរួចសម្លាប់ចោលទាំងអស់នៅមុនថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

**ឌួង សុភារិទ្ធ**


លោក ហ៊ុយ គ្រឹម
បង្ហាញរណ្តៅសាកសពនៅវត្តតាលាស់ចាស់

## ពាក្យស្លោកខ្មែរក្រហម

◆ ខ្មះខ្នែងកម្ទេចកម្លាំងខ្មាំង ថែរក្សានិងបំប៉នកម្លាំងយើងកាន់តែ វាយកាន់តែខ្លាំង កាន់តែវាយកាន់តែឈ្នះ។

◆ ប្រយុទ្ធនឹងចលនាទាហានខ្មាំង ហើយបំផុសមហាជនឱ្យក្រោកឡើងវាយដណ្តើមសិទ្ធអំណាចធ្វើម្ចាស់ទឹកដី។

(ដកស្រង់ចេញពីសៀវភៅលេខ២០០៖កណាហ)

◆ បើចង់វាយសត្រូវឈ្នះ ត្រូវវាយសត្រូវក្នុងខ្លួន។

◆ ស្លាប់ជាការធម្មតារបស់អ្នកតស៊ូ។

◆ ស្លាប់ក្នុងសង្គ្រាមប្រសើរថ្លៃថ្លា។

◆ ប្រជាជន ជីវពលស្លាប់អស្ចារ្យ រស់ពិស្តាក្នុងបដិវត្តន៍។

◆ ជនកុម្មុយនិស្តល្អបវរក្រៃ ឥតសំចៃរស់ដើម្បីជាតិ។

(ដកស្រង់ចេញពីសៀវភៅសមមិត្ត អ៊ីវ)

◆រួមផ្សំការប្រយុទ្ធនិងការចលនាបំបាក់បំបែកជួរទាហានខ្មាំង។

(ដកស្រង់ចេញពីសៀវភៅលេខ១៩៨៖កណាហ)

**(តមកពីទំព័រទី១)** របបខ្មែរក្រហមមានន័យថាជនទាំងឡាយណាដែលហ៊ានបញ្ចេញគំនិតឬទស្សនៈឯករាជ្យណាមួយនឹងត្រូវចាត់ទុកថាជា“សត្រូវរបស់អង្គការ” ហេតុដូច្នេះនឹងត្រូវទទួលរងនូវការកម្ទេចចោល ។ ម្តងហើយម្តងទៀត ក្រុមមេដឹកនាំខ្មែរក្រហមនៅតែមានះលើគំនិតដែលថា ភាពប្រសើររបស់ជាតិ គឺតម្រូវឲ្យមានការសម្លាប់ដោយគ្មានការអាណិតអាសូរលើប្រជាជនខ្មែរដោយប្រជាជនខ្មែរដែលខ្លួនបានចាត់ទុកថាជាខ្មាំង ។ មិនត្រឹមតែប៉ុណ្ណោះ ជាក់ស្តែងទៅទៀតពួកខ្មែរក្រហមថែមទាំងបានអនុវត្តលើជំនឿរបស់ខ្លួនជាមួយនឹងការសងសឹក ។ យុត្តិធម៌នៅក្រោមរបបខ្មែរក្រហមក៏មានន័យដែរថា “ត្រូវតែបរិសុទ្ធ” ។ ដូចគ្នានៅក្នុងបញ្ហាផ្សេងៗទៀតគ្រប់ជំពូកអង្គការបានចាត់ទុកខ្លួនជាអ្នកកាត់ក្តីដ៏បរិសុទ្ធស្អាតស្អំ ដោយយល់ឃើញថាអ្នកណាដែលមានចំណេះដឹងឬសម្បុរសបុរស់នៅក្នុងទីក្រុងគឺសុទ្ធតែជាខ្មាំង ។ បើសិនជាប្រជាជនណាម្នាក់ធ្លាក់ចូលទៅក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទខាងលើនេះ ពួកខ្មែរក្រហមនឹងសម្លាប់ចោលឬក៏បង្អត់អាហារឲ្យស្លាប់ជាពុំខាន ។

មានថ្ងៃមួយនៅក្នុងរបបខ្មែរក្រហម ខ្ញុំបានបោចដំឡូងនិងបូតស្រូវឲ្យបងស្រីរបស់ខ្ញុំដែលមានផ្ទៃពោះ ហើយដែលគ្មានម្ហូបអាហារពិតប្រាកដសម្រាប់ទទួលទានអស់ជាច្រើនខែមកហើយ ។ ទង្វើនេះត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋនៅក្រោមរបបខ្មែរក្រហម ។ ដូច្នោះ ពួកខ្មែរក្រហមបានវាយខ្ញុំនឹងពូថៅដៃ រុញខ្ញុំទៅនឹងដី ចងដៃខ្ញុំទាំងពីរទៅក្រោយ រួចយកខ្ញុំទៅដាក់ក្នុងគុកអស់ជាច្រើនសប្តាហ៍ ។ ម្តាយខ្ញុំមិនហ៊ានស្រែកយំនៅចំពោះមុខពួកខ្មែរក្រហមដែលកំពុងធ្វើទារុណកម្មលើរូបខ្ញុំទេ ។ នៅក្រោមរបបខ្មែរក្រហមការស្រែកយំក៏ជាប់ជាបទឧក្រិដ្ឋមួយដែរ ។

ឡុង ណារិន អៀង សារី និង អៀង ធីរិទ្ធ បាននិយាយថា ការចលាចលនឹងកើតមានឡើងប្រសិនបើថ្នាក់ដឹកនាំខ្មែរក្រហមត្រូវបាននាំខ្លួនយកមកកាត់ទោស ។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមគិតដូច្នោះ នៅក្រោមរបបខ្មែរក្រហមប្រជាជនត្រូវបានពួកខ្មែរក្រហមបង្ខំឲ្យបិទមាត់ដោយយកទ្រឹស្តីឲ្យរស់នៅដូចដើម“គ” មកគំរាមប្រជាជន ។ បើប្រជាជនណាម្នាក់ហ៊ាននិយាយអំពីភាពខ្វះខាត គឺមានតែស្លាប់ ។ ទន្ទឹមនឹងនោះដែរ ពួកខ្មែរក្រហមបានបង្ខំអ្នកស្រុកអ្នកភូមិឲ្យប្រឌិតរឿងមិនពិតអំពីខ្លួនយើងនិងអំពីអ្នកដទៃដើម្បីឲ្យរបបខ្មែរក្រហមនិងឧក្រិដ្ឋជនអាចយកមកធ្វើជាហេតុផលបិទបាំងរបបយង់ឃ្នងរបស់ខ្លួន ។

ខ្ញុំឆ្ងល់ថាតើ ឡុង ណារិន អៀង សារី អៀង ធីរិទ្ធ យល់ពីអត្ថន័យនៃការផ្លាស់ប្តូរនិងការអភិវឌ្ឍនៅក្នុងសង្គមប្រជាធិបតេយ្យយ៉ាងណាដែរ ។ ឥឡូវក្រុមថ្នាក់ដឹកនាំខ្មែរក្រហមបាននាំគ្នានិយាយអំពីការបង្រួបបង្រួមជាតិ អំពីការខិតខំពង្រឹងសន្តិភាពនិងវឌ្ឍនភាព និងអំពីការដោះស្រាយភាពក្រីក្ររបស់ប្រជាជន ។ ក្រោយនៃពាក្យសម្តីដែលចេញពីថ្វីមប្រមាត់របស់មនុស្សខ្មែរក្រហមដែលបានធ្វើឲ្យមានគ្រោះមហន្តរាយលើប្រជាជាតិកម្ពុជារួចមកហើយនោះ ពុំចូលភ្នែក ត្រចៀក និងខួរក្បាលរបស់ប្រជាជនខ្មែរដែលធ្លាប់ជាជនរងគ្រោះនៃរបបខ្មែរក្រហមទេ ។ តើយើងអាចបង្រួបបង្រួមជាតិជាមួយមនុស្សដែលទទួលខុសត្រូវនិងសម្លាប់ក្រុមគ្រួសារយើងដោយពុំមានតុលាការឯករាជ្យនិងយុត្តិធម៌មួយបានដែរឬទេ? តើសន្តិភាពបែបណាដែលអាចត្រូវបានពង្រឹងនៅក្នុងប្រទេសជាតិមួយដែលនៅតែពុំទាន់មានដំណោះស្រាយលើបញ្ហាបែបនេះនៅឡើយ? តើរបបខ្មែរក្រហមធ្លាប់បានស្វែងរកការបង្រួបបង្រួមជាតិជាមួយយើងទាំងអស់គ្នាដែលធ្លាប់រស់នៅជាមួយនិងបម្រើឲ្យរបប លន់ ណុល ហើយដែលយើងទាំងអស់គ្នាជាទូទៅគ្រាន់តែជាអ្នកទីក្រុងឬនិស្សិតឬជាអ្នកជំនួញដែរឬទេ? ដូច្នេះតើពាក្យសម្តីរបស់ពួកមេដឹកនាំខ្មែរក្រហមដែលថា“បំភ្លេចរឿងអតីតកាលចោល”នោះស្ថិតនៅត្រង់ណាទៅ? តើចំណាប់អារម្មណ៍របស់ក្រុមមេដឹកនាំខ្មែរក្រហមក្នុងការបង្រួបបង្រួមជាតិឬការពង្រឹងសន្តិភាពនោះស្ថិតនៅត្រង់ណាដែរទៅ? លើសពីនេះទៅទៀត ក្រុមមេដឹកនាំខ្មែរក្រហមធ្លាប់បាននាំគ្នានិយាយអំពីវឌ្ឍនភាពសង្គម ។ ក្រុមមេដឹកនាំខ្មែរក្រហមបានដឹកនាំប្រទេសជាតិក្នុងជំហានមហាលោតផ្លោះមហាអស្ចារ្យដោយកាត់ផ្តាច់ប្រទេសពីទំនាក់ទំនងជាមួយពិភពលោកខាងក្រៅ ដោយបានបង្ខំឲ្យមនុស្សគ្រប់រូបធ្វើការហួសកម្លាំងនៅតាមវាលស្រែ លើកទំនប់ ជីកប្រឡាយឥតឈប់ឈរ ដោយពុំមានស្បៀងអាហារនិងថ្នាំសង្កូវសម្រាប់ព្យាបាលអ្នកជំងឺ ។

តើអ្វីទៅដែលថាក្រុមមេដឹកនាំខ្មែរក្រហមបានយល់ថាធ្វើបែបនេះប្រសើរជាងការអនុញ្ញាតឲ្យបរទេសខាងក្រៅចូលមកមើល ហើយអ្វីទៅដែលថាក្រុមមេដឹកនាំខ្មែរក្រហមពុំបានដឹង




ក្នុងពេលឥឡូវនេះ ។ មិនតែប៉ុណ្ណោះពួកមេដឹកនាំខ្មែរក្រហមបាននាំគ្នានិយាយអំពីដំណោះស្រាយភាពក្រីក្រនិងការអត់ឃ្លាន ។ ខ្ញុំឆ្ងល់ថា តើហេតុអ្វីបានក្នុងរបបខ្មែរក្រហម ប្រជាជនទូទាំងប្រទេសពុំមានសម្លៀកបំពាក់ជម្រកសម្រាប់រស់នៅឲ្យគត់មត់និងពុំមានស្បៀងអាហារឲ្យបានគ្រប់គ្រាន់ផង ហើយដែលតាមការពិតជាក់ស្តែងវិញនោះពួកខ្មែរក្រហមបាននាំចេញនូវភោគផលនិងទ្រព្យសម្បត្តិជាតិ មានទាំងស្រូវអង្ករនិងមាសពេជ្រទៅប្រទេសចិននិងប្រទេសវៀតណាម ។ នេះប្រហែលជាមកពីក្រុមមេដឹកនាំខ្មែរក្រហមមានការមមាញឹកខ្លាំងពេកក្នុងការកម្ទេចអ្នកទោសរបស់អង្គការប្រមាណ៥.២០០នាក់ជារៀងរាល់សប្តាហ៍នៅក្នុងអំឡុងពេល៣ឆ្នាំ៨ខែនិង២០ថ្ងៃក្នុងពេលកាន់អំណាចរបស់ខ្លួនរហូតដល់គ្មានពេលគិតព្រួយបារម្ភដល់មនុស្សរាប់សែននាក់ដែលទុកឲ្យស្លាប់ដោយគ្មានចំណីអាហារនិងថ្នាំសង្កូវនៅមូលដ្ឋាន មន្ទីរពេទ្យនិងវាលស្រែ ។

បងស្រីខ្ញុំម្នាក់បានស្លាប់បាត់បង់ជីវិតដោយសារគាត់ពុំមានអាហារបរិភោគ ។ ក្នុងពេលជាមួយគ្នានោះ កូនស្រីរបស់គាត់ម្នាក់ក៏បានស្លាប់បាត់បង់ជីវិតដែរព្រោះតែបងស្រីរបស់ខ្ញុំពុំមានលទ្ធភាពបំបៅកូនរបស់ខ្លួន ។

មកទល់សព្វថ្ងៃនេះ ក្រុមមេដឹកនាំខ្មែរក្រហមនៅតែមិនព្រមទទួលស្គាល់អំពីការសម្លាប់រង្គាលរបស់ខ្លួនដែលមានប្រជាជនជាង១លាននាក់បានស្លាប់បាត់បង់ជីវិតនៅក្រោមរបបខ្មែរក្រហមរវាងឆ្នាំ១៩៧៥និង១៩៧៩ ។ តើសំអាងលើមូលដ្ឋានអ្វីដែលខ្ញុំត្រូវជឿពួកមេដឹកនាំខ្មែរក្រហមនៅពេលនេះ? តើមានហេតុផលអ្វីខ្ញុំត្រូវជឿ ឡុង ណារិន អៀង សារី និង អៀង ធីរិទ្ធ? តើក្រុមមេដឹកនាំខ្មែរក្រហមទាំងបីរូបនេះប្រាកដជាបានសម្ពឹងព្រះពុទ្ធបដិមាពិតមែនដែរឬទេនៅខណៈពេលដែលខ្លួនធ្វើសក្ការៈបួងសួងនោះ? តើក្រុមមេដឹកនាំខ្មែរក្រហមទាំងនេះគឺជាមនុស្សដែលបានគោរពប្រតិបត្តិព្រះសង្ឃមែនឬ? តើពួកក្រុមមេដឹកនាំខ្មែរក្រហមពិតជាសុំឲ្យមានការលើកលែងទោសកំហុសរបស់ខ្លួនមែនដែរឬទេ?

**ឆាំង យុ**



# លក្ខណៈសម្បត្តិ១០ "ខ" របស់បក្ស

(កត់ត្រាដាំចស្រង់ពីឯកសារទង់បដិវត្តន៍លេខ ៨ ខែសីហា ១៩៧៨)

***(តពីលេខមុន)***

ក្នុងន័យអនុវត្តជាក់ស្តែង បក្ខជនទាំងអស់ ថ្នាក់ណាក៏ដោយត្រូវមានគោលជំហរ អត្តចរិត ស្មារតី និស្ស័យនិងសកម្មភាពថែរក្សាការពារ កសាង ពង្រឹងនិងពង្រីកសាមគ្គីភាពឯកភាពផ្ទៃក្នុងរបស់បក្សជាប់ជានិច្ច តាមគោលជំហរនយោបាយ សតិអារម្មណ៍និងការចាត់តាំងរបស់បក្ស ។ បក្ខជនម្នាក់ៗត្រូវមានលក្ខណៈសាមគ្គីឲ្យបានជាមួយភាគច្រើនដាច់ខាតពី៩៨ ទៅ១០០ភាគរយ ដោយមហាជនទទួលទំនុកទុកចិត្តកក់ក្តៅស្រឡាញ់ពេញចិត្តក្នុងក្របខ័ណ្ឌរបស់ខ្លួនក្នុងក្របខ័ណ្ឌទូទៅក្តី ។

បក្ខជនម្នាក់ៗត្រូវប្រយ័ត្នជាទីបំផុតចំពោះគោលជំហរ អត្តចរិត ស្មារតី និស្ស័យនិងសកម្មភាពប្រឆាំងនិងវាយប្រហារបក្ស វាយប្រហារសមមិត្តជងគ្នាដោយគោលជំហរកម្មសិទ្ធិបុគ្គល ***ស្នួនគួ***និងបក្សពួក ។

បក្សយើងតូច អាយុនៅតិចក៏ពិតមែន តែគោលជំហរសាមគ្គីភាពឯកភាពផ្ទៃក្នុងរបស់បក្សយើងរឹងប៉ឹង ក្តីត្រចះត្រចង់មានកម្លាំងខ្លាំងក្លាវាយឈ្នះចក្រពត្តិអាមេរិកឈ្លានពាន វាយឈ្នះខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី បំបាត់ពូជសាសន៍ វាយឈ្នះពួកសេរីនិយម វាតទីនិយម វាយរំលំរបបសក្តិភូមិម្ចាស់ដីនាយទុនឈានចូលមកក្នុងដំណាក់កាលនៃបដិវត្តន៍សង្គមនិយមយ៉ាងក្លៀវក្លាស្វាហាប់ ជឿជាក់លើជ័យជនៈនៃអនាគតដ៏ត្រចះត្រចង់របស់ខ្លួន ។

បក្ខជនគ្រប់ជំនាន់ដាច់ខាតជ្រោងទង់សាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្សឲ្យខ្ពស់ត្រដែតត្រដឹមឡើងជានិច្ចដើម្បីបន្តភារកិច្ចវាយកម្ទាត់ខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី បំបាត់ពូជសាសន៍

ពីជំនាន់មួយទៅជំនាន់មួយ រក្សាការពារបក្សកុម្មុយនិស្តកម្ពុជាដែលជាព្រលឹងរបស់ជាតិនិងប្រជាជនកម្ពុជាឲ្យស្ថិតស្ថេរជានិច្ចកាល ។

**៤) កសាងគោលជំហររឹងប៉ឹងខាងមាគ៌ាចាត់តាំងដឹកនាំនិងធ្វើការងាររបស់បក្ស**

មាគ៌ាចាត់តាំងគឺជាមាគ៌ាដើម្បីអនុវត្តមាគ៌ានយោបាយរបស់បក្សឲ្យចេញជាសាច់ការជាក់ស្តែង ។ មានមាគ៌ានយោបាយត្រឹមត្រូវ តែបើមាគ៌ាចាត់តាំងខុសគឺមិនអាចសម្រេចមាគ៌ានយោបាយរបស់បក្សបានជាដាច់ខាត ។ មាគ៌ាចាត់តាំង គឺដើម្បីបម្រើមាគ៌ានយោបាយ ។ មាគ៌ាចាត់តាំងជាមូលដ្ឋានរបស់បក្សយើងគឺប្រជាជនកម្ពុជាត្រូវធ្វើបដិវត្តន៍ដោយខ្លួនឯង ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាតែមួយគត់ ។ បក្សកុម្មុយ-និស្តកម្ពុជាចាត់តាំងឡើងដោយវណ្ណៈកម្មករ កម្ពុជាធំធាត់ឡើងក្នុងចលនាតស៊ូបដិវត្តរបស់ប្រជាជនកម្ពុជា ។ កងទ័ពបដិវត្តន៍កម្ពុជាចាត់តាំងឡើងដោយផ្អែកលើវណ្ណៈកម្មករ-កសិករកម្ពុជាក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាដាច់ខាត ។ រដ្ឋអំណាចបដិវត្តន៍កម្ពុជាចាត់តាំងឡើងដោយប្រជាជនកម្ពុជាក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា ។ល ។

ខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី បំបាត់ពូជសាសន៍ វាក្តៅក្រហាយណាស់ចំពោះគោលជំហរចាត់តាំងដ៏ត្រឹមត្រូវរបស់បក្សយើង ។ វាខំឆ្មៀតបញ្ជូលភ្នែកបម្រើវាចូលក្នុងបក្សកុម្មុយនិស្តកម្ពុជា ។ វាខំទូចសុំអប់រំនិងចាត់តាំងកងទ័ពបដិវត្តន៍កម្ពុជា ដើម្បីវាក្តាប់កងទ័ពបដិវត្តន៍កម្ពុជាយើង ។ វាលួចលាក់ចាត់តាំងរដ្ឋអំណាចដែលមានមនុស្សជាអាយ៉ងរបស់វាដើម្បីបម្រើផលប្រយោជន៍របស់វា ។ ខ្មាំងយួនយកលេសថាជួយបដិវត្តន៍កម្ពុជាដើម្បីចាត់តាំងនេះចាត់តាំងនោះ តាមគោលជំហររបស់វាសម្រាប់លេបយកទឹកដីកម្ពុជា ។ តែបក្សកុម្មុយនិស្តកម្ពុជា ប្រជាជនកម្ពុជាជ្រួតជ្រាបនូវមាគ៌ាចាត់តាំងរបស់បក្សបានវាយកម្ទេចផែនការលួចបន្លំចាត់តាំងរបស់ខ្មាំងយួនខ្ទេចខ្ទីរក្សាបានបរិសុទ្ធភាពខាងចាត់តាំងបក្សធ្វើឲ្យខ្មាំងយួនត្រូវទាល់ច្រកបរាជ័យយ៉ាងអាម៉ាស់មុខបំផុត ។

ព្រមជាមួយគ្នានេះបក្ខជនគ្រប់រូបត្រូវខំកសាងខាងគោលជំហរប្រជាធិបតេយ្យប្រមូលផ្តុំទស្សនៈមហាជន មាគ៌ាមហាជននិងមាគ៌ាវណ្ណៈរបស់បក្សត្រឹមត្រូវរឹងប៉ឹង ។ ត្រូវខិតខំកសាងគោលជំហរដឹកនាំធ្វើការងារដោយសមូហភាព ត្រឹមត្រូវនិងរឹងប៉ឹង ហើយនិងជំហរទទួលខុសត្រូវភារកិច្ចនិងអនុវត្តភារកិច្ចដោយខ្ពែកខ្ពស់ ។ ត្រូវខិតខំកសាងគោលជំហរនិងអាកប្បកិរិយាដឹកនាំធ្វើការងារជាប់មហាជនក្នុងសហជីពសហករណ៍និងកងទ័ពបដិវត្តន៍មានគំនិតផ្តើមច្នៃប្រឌិតម្ចាស់ការស្មុះស្មាញនិងវាយសម្រុកក្តៅជាប់ ។ ត្រូវកម្ចាត់ឲ្យអស់គោលជំហរនិងអាកប្បកិរិយាដឹកនាំធ្វើការងារបែបការិយាល័យនិយម នាហ្មឺននិយម អាជ្ញានិយម យោធានិយម សេរីនិយមឯកចិត្តនិយម អត្តនោម័តិនិយមបែបមិនទទួលខុសត្រូវអ្វីទាំងអស់ចំពោះបក្ស ចំពោះបដិវត្តន៍និងប្រជាជន ។

**៥) កសាងគោលជំហរបដិវត្តន៍រឹងប៉ឹងខាងការប្រុងប្រយ័ត្នបដិវត្តន៍របស់បក្ស រក្សាការសម្ងាត់និងការពារកម្លាំងបដិវត្តន៍:**

ការប្រុងប្រយ័ត្នបដិវត្តន៍របស់បក្ស រក្សាការសម្ងាត់និងការពារកម្លាំងបដិវត្តន៍ ជាកត្តាសំខាន់មូលដ្ឋានមួយធ្វើឲ្យបដិវត្តន៍បានទទួលជ័យជំនះ ។ បញ្ហានេះជាលក្ខការណ៍មួយរបស់គ្រប់បក្សដឹកនាំបដិវត្តន៍ ហើយជាកត្តាមួយសម្រាប់វាស់ស្ទង់កម្រិតភ្ញាក់រឭកនយោបាយរបស់បក្ខជន វាស់ស្ទង់ស្មារតីទទួលខុសត្រូវរបស់បក្ខជនដែលមានចំពោះបក្ស ចំពោះបដិវត្តន៍និងប្រជាជន វាស់ស្ទង់ស្មារតីស្រឡាញ់បក្ស ស្រឡាញ់បដិវត្តន៍ស្រឡាញ់ប្រជាជនរបស់បក្ខជន ។ ខ្មាំងយួនឈ្លានពានវាតទីលេបទឹកដីបំបាត់ពូជសាសន៍កម្ពុជា វាចាត់តាំងភ្នាក់ងារភ្នែកបម្រើវាបង្កប់ស៊ីរូងផ្ទៃក្នុងបក្សយើង ផ្ទៃក្នុងជួរបដិវត្តន៍យើងដើម្បីលួចយកការណ៍សម្ងាត់របស់បក្ស របស់បដិវត្តន៍យើងទៅឲ្យវា ហើយដើម្បីកម្ទេចកម្លាំងបដិវត្តន៍យើងទាំងខាងនយោបាយសតិអារម្មណ៍និងចាត់តាំង ។ ខ្មាំងយួនវានៅបន្តធ្វើសកម្មភាពចោរកម្មលួចយកការណ៍សម្ងាត់របស់បក្សយើង បំផ្លាញកម្លាំងបដិវត្តន៍យើងតទៅទៀត តែការប្រព្រឹត្តដ៏ថោកទាបរបស់វាពិតជាត្រូវបរាជ័យទៀត ដូចជាវាធ្លាប់ត្រូវបរាជ័យជាហូរហែមកហើយ ។

បក្ខជនគ្រប់រូបត្រូវយកចិត្តទុកដាក់ឲ្យខ្លាំងថែមទៀតក្នុង

ការកសាងគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ រក្សាការសម្ងាត់និងការពារកម្លាំងបដិវត្តន៍ត្រឹមត្រូវនិងរឹងប៉ឹងគ្រប់កាលៈទេសៈ និងគ្រប់អំពើប្រព្រឹត្ត ធ្វើការងារ និយាយស្តី អាកប្បកិរិយា ការរស់នៅគ្រប់បែបយ៉ាងចំពោះមុខនិងយូរអង្វែងក្នុងបក្សនិងក្រៅបក្ស ។ ត្រូវតស៊ូកម្ចាត់ឲ្យអស់រលីងពីខ្លួនយើងម្នាក់ៗនូវសេរីនិយមនិងគោលជំហរមិនទទួលខុសត្រូវចំពោះការប្រុងប្រយ័ត្នបដិវត្តន៍ ការពារការណ៍សម្ងាត់ ការពារកម្លាំងបដិវត្តន៍ដែលចេញជាអំពើប្រព្រឹត្តធ្វើការងារនិយាយស្តី អាកប្បកិរិយា និងការរស់នៅ ។

កម្មាភិបាលឬបក្ខជនល្អឬមិនល្អ មានគោលជំហរបដិវត្តន៍រឹងប៉ឹងឬមិនរឹងប៉ឹង មានស្មារតីប្រយុទ្ធខ្លាំងក្លាឬមិនខ្លាំងក្លា អាចសម្គាល់បានមួយផ្នែកតាមគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍របស់បក្ស រក្សាការសម្ងាត់និងការពារកម្លាំងបដិវត្តន៍ ។ បើកម្មាភិបាលនិងបក្ខជនណាមិនប្រុងប្រយ័ត្នបដិវត្តន៍របស់បក្សជាខ្សែសង្វាក់ ធ្វើឲ្យបែកការណ៍សម្ងាត់របស់បក្សជាខ្សែសង្វាក់ ធ្វើឲ្យខូចកម្លាំងបដិវត្តន៍ជាខ្សែសង្វាក់ ហើយបក្សបានអប់រំ កសាងជាច្រើនលើកច្រើនគ្រាមិនកែប្រែត្រូវមានវិធានការតាមកម្រិតដែលសមស្រប ។

**៦) កសាងគោលជំហរបដិវត្តន៍រឹងប៉ឹងខាង«ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួននិងខ្លួនធ្វើម្ចាស់លើខ្លួនឯង»របស់បក្សៈ**

បើយើងពិនិត្យមើលសកម្មភាពបំផ្លាញបក្ស ដឹកនាំបដិវត្តន៍របស់បក្ខពួកសេរីនិយម វាតទីនិយមលើសកលលោក ហើយជាពិសេសបើយើងពិនិត្យមើលសកម្មភាពរបស់ខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ដែលវាបំផ្លាញបក្សកុម្មុនិស្តកម្ពុជាយើង គឺយើងឃើញច្បាស់ថាពួកវាសំដៅវាយរំលំគោលជំហរបដិវត្តន៍ខាង«ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួននិងខ្លួនធ្វើម្ចាស់លើខ្លួនឯង»របស់បក្សជាសំខាន់បំផុត ។ បើខ្មាំងយួនវាធ្វើឲ្យសាបរលាបឬបើវាវាយរំលំគោលជំហរបដិវត្តន៍ខាង«ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួននិងខ្លួនធ្វើម្ចាស់លើខ្លួនឯង» របស់បក្សបានសម្រេចនោះ បក្សនិងបដិវត្តន៍យើងមុខនឹងក្លាយទៅជារណបយួន ខ្ញុំយួន ពឹងពាក់លើយួន យួនមកធ្វើម្ចាស់ យួនមកចាត់ចែងវាសនាបក្សបដិវត្តន៍ ប្រទេសជាតិនិងប្រជាជនយើងតាមផលប្រយោជន៍របស់យួន ។ និយាយមួយម៉ាត់ គឺខ្មាំងយួនមានឱកាសល្អលេបទឹកដីកម្ពុជាបំបាត់ពូជសាសន៍កម្ពុជា ។

តាមសភាពការណ៍ជាក់ស្តែងនេះហើយដែលយើងកាន់តែឃើញច្បាស់ថែមទៀតនូវភាពត្រឹមត្រូវ ភ្លឺស្វាង វៃឈ្លាសទាន់ពេលទាន់វេលារបស់បក្សកុម្មុយនិស្តកម្ពុជាដែលបានលើកយកនូវគោលជំហរបដិវត្តន៍ដ៏រឹងប៉ឹងខាង«ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួននិងខ្លួនធ្វើម្ចាស់លើខ្លួនឯង» របស់បក្សមកអប់រំ មកបំផុសទូទាំងបក្ស ទូទាំងប្រជាជន ទូទាំងកងទ័ព ឲ្យស្មារតីឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនធ្វើម្ចាស់លើខ្លួនឯងកម្រើករំពើករំដើបរំជួលប្រែក្លាយចេញជាចលនាបដិវត្តន៍យ៉ាងផុសផុលខ្លាំងក្លា វាយសម្រុកខ្មាំងសត្រូវដូចព្យុះសង្ឃរា ។ មានបដិវត្តន៍ក្នុងឋានៈជាបក្សមួយឯករាជ្យ ជាតិមួយឯករាជ្យ ប្រជាជនមួយឯករាជ្យ ធ្លាប់មានពូជសាសន៍ជាអ្នកប្រយុទ្ធ ជាអ្នកកសាងធ្លាប់មានថ្វីដៃដ៏ខ្លាំងពូកែអស្ចារ្យចារឹកទុកលើផ្ទាំងសិលានៃប្រវត្តិសាស្ត្រជាតិនិងអន្តរជាតិ នរណាឡើយទៅសុខចិត្តសារភាពធ្វើរណបខ្មាំងយួន នរណាឡើយទៅសុខចិត្តឲ្យយួនឈ្លានពានវាតទីលេបទឹកដី បំបាត់ពូជសាសន៍បានងាយៗ ។ បាតដៃទទេគ្មានអាវុធមួយដើមសោះ តែដោយមានអាវុធខ្លាំងក្លាអស្ចារ្យខាងគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនធ្វើម្ចាស់លើខ្លួនប្រជាជនកម្ពុជាទាំង៨លាននាក់ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា បានក្រោកឈរឡើងដណ្តើមយកអាវុធពីខ្មាំងវាយកម្ទេចខ្មាំង កសាងកម្លាំងខ្លួនជំរុញចលនាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យឆេះរាលដាលទូទាំងប្រទេសនាឆ្នាំ១៩៦៨ បន្តរហូតលុះមកបានទទួលមហាជ័យជំនះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ពីដំណាក់កាលប្រជាជាតិ ប្រជាធិបតេយ្យទៅដំណាក់កាលបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនធ្វើម្ចាស់លើខ្លួនរបស់បក្សកាន់តែបានពង្រឹងនិងពង្រីកមិនត្រឹមតែនៅក្នុងក្របខ័ណ្ឌជាតិប៉ុណ្ណោះទេតែបានធ្វើឲ្យសកលលោកភ្ញាក់ផ្អើល កោតស្ញប់ស្ញែង ។ គេកោតស្ញប់ស្ញែងដោយឃើញបក្សកុម្មុយនិស្តកម្ពុជាយើងហ៊ានប្រជាងទង់ឯករាជ្យវាយបំបាក់ទង់ឈ្លានពានវាតទីលេបទឹកដីរបស់ខ្មាំងយួននិងបក្សពួកសេរីវាតទីរបស់វា ។

គេកោតស្ញប់ស្ញែងដោយឃើញបក្សកុម្មុយនិស្តកម្ពុជាយើងហ៊ាន ប្រជាងទង់ខ្លួនទីពឹងខ្លួន ខ្លួនធ្វើម្ចាស់លើខ្លួនឯង វាយបំបាក់មុខយួន ដែលប្រជាងទង់ជង់យាមដើរសុំទានគេគ្រប់ច្រកល្ហកយកមក ចែកគ្នាលិឍ ។

គោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនធ្វើម្ចាស់លើខ្លួន ជាគោលជំហរមិនចេះចាញ់ ជាគោលជំហរមិនចេះរីងស្ងួត ទាំងកម្លាំងមនុស្សទាំងកម្លាំងសម្ភារ ជាគោលជំហរមិនស្លាប់ ជាគោលជំហររស់រហូត រស់ដោយរុងរឿង រស់ដោយថ្លៃថ្នូរ ខ្លាំងពូកែក្នុងកិត្តិយសជាតិនិងអន្តរជាតិ ។



ពិធីគោរពទង់បក្សនៅស្តាតអូឡាំពិក

បក្សកុម្មុយនិស្តយើងឈានពីតិចទៅច្រើន ពីតូចទៅធំ ពីខ្សោយទៅខ្លាំង ក៏មកពីបក្សយើងមានគោលជំហរបដិវត្តន៍រឹងប៉ឹងខាងឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនធ្វើម្ចាស់លើខ្លួន ។ ឯបក្សយួនវិញ អានេះវាឈានពីច្រើនចុះតិច ឈានពីធំទៅតូច ឈានពីខ្លាំងចុះខ្សោយ ។ វាឈ្លានពានកម្ពុជាមកពីវាធ្វើខ្ញុំកញ្ជះពួកសេរីវាតទី វាបាត់ឯករាជ្យ ។ វាដើរសុំទានគេលិឍមកពីមិនពឹងលើខ្លួនវា ។ វាបាត់ម្ចាស់ការនៅក្រោមបញ្ជារបស់ចៅហ្វាយសេរីវាតទីនិយមរបស់វា ។ បក្ខជននៃបក្សកុម្មុយនិស្តកម្ពុជាគ្រប់រូបចូរយើងរក្សាឯករាជ្យជាតិ អធិបតេយ្យជាតិ បូរណភាពដែនដីនិងកិត្តិយសជាតិយើង ដោយខិតខំកសាង ពង្រឹងពង្រីកគោលជំហរបដិវត្តន៍រឹងប៉ឹងខាង «ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនធ្វើម្ចាស់លើខ្លួនឯង» របស់បក្សឲ្យកាន់តែមានប្រសិទ្ធភាពខ្លាំងក្លាឡើងពីជំនាន់មួយទៅជំនាន់មួយ ។ តាមរយៈនេះការប្រយុទ្ធដោយអាវុធ វាយកម្ចាត់ខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ក៏កាន់តែខ្លាំងក្លា ។ លំបាកយ៉ាងណាក៏ដោយយើងស៊ូនៅឯករាជ្យ កុំធ្វើខ្ញុំកញ្ជះគេ ។ ស្មុគស្មាញយ៉ាងណាក៏ដោយយើងស៊ូរក្សាឋានៈម្ចាស់ការរបស់យើងកុំបោះបង់ចោលឋានៈម្ចាស់ការ កុំឲ្យអ្នកដទៃមកធ្វើម្ចាស់លើយើង ។ ខ្វះខាតយ៉ាងណាក៏ដោយស៊ូខ្លួនទីពឹងខ្លួន កុំពឹងអ្នកដទៃ ។ អត់ឃ្លានយ៉ាងណាក៏ដោយស៊ូធ្វើម្ចាស់លើខ្លួនឯង កុំយកអ្នកដទៃធ្វើជាម្ចាស់លើខ្លួន ។ និយាយឲ្យខ្លីមួយម៉ាត់គឺ យើងធ្វើបដិវត្តន៍របស់យើង ដោយខ្លួនយើងក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាយើងតែមួយគត់ ។ ដូច្នេះ ហើយបក្ខជនទាំងអស់ត្រូវមានជំហរ «ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនធ្វើជាម្ចាស់លើខ្លួនឯង» ខ្ពស់ក្នុងការបំពេញភារកិច្ចផ្សេងៗរបស់បក្សលើគ្រប់ផ្នែកទាំងអស់ និងគ្រប់កាលៈទេសៈ ។ ***(នៅមានត)***

## ពាក្យស្លោកខ្មែរក្រហម

**◆បើគ្មានពលកម្មទេ អ្វូសទាញបដិវត្តន៍ទៅមុខមិនកើត បើចង់បានមនុញ្ញផល គស៊ូធើបបានសម្រេច។**

**◆បើចង់ធ្វើបដិវត្តន៍ ត្រូវរកមនុស្សបដិវត្ត ចង់បានមនុស្សបដិវត្តត្រូវមានគោលជំហរសតិអារម្មណ៍លើបដិវត្តន៍។**

*(ដកស្រង់ចេញពីសៀវភៅសមមិត្ត កែវ)*

# សមមិត្ត គង់ ឬ សួង ស៊ីគឿន

## (កត់ត្រាតាមសំណៅរដើមផាំងស្រុង)

***(តចប់) រយៈកាល ឧសភា ១៩៧៥-ឧសភា ១៩៧៧: នៅក្រសួងការបរទេស:***



សួង ស៊ីគឿន

ថ្ងៃទី១២ ខែឧសភា ឆ្នាំ ១៩៧៥ បក្សបានអនុញ្ញាតឲ្យសមាជិកនៃមន្ទីរតំណាងគណៈកម្មាធិការមជ្ឈិមបក្សនៅបរទេសនិងសមាជិកវិទ្យុ«សម្លេងរណសិរ្សរួបរួមជាតិកម្ពុជា»វិលត្រឡប់មកបំពេញភារកិច្ចនៅក្នុងប្រទេស ។ ខ្ញុំធ្វើជាសមាជិកគណៈធ្វើដំណើរទទួលបន្ទុកខាងសម្ភារ ។ ពួកយួនវាបង្កើតការលំបាកគ្រប់បែបយ៉ាងក្នុងការចេញនិងធ្វើដំណើរ ។ យើងខ្ញុំត្រូវចេញពីតំបន់ទី១នៅថ្ងៃ ៩ ខែឧសភា ឆ្នាំ១៩៧៥ ។ អាក្បត់ កែវ មាស ចាងហ្វាងទីភ្នាក់ងារសារព័ត៌មាន«អា.កា.អ៊ី» ក៏ត្រូវធ្វើដំណើរមកជាមួយយើងខ្ញុំដែរ តែយួនវាថាគ្មានយន្តហោះ ។ ការពិតតាមបក្សបានឲ្យដឹងអាក្បត់ កែវ មាស វាមកវៀតណាមខាងត្បូងក្នុងចន្លោះថ្ងៃ ៩ និងថ្ងៃ ១២ ខែឧសភា ឆ្នាំ១៩៧៥ដើម្បីទាក់ទងខ្សែក្បត់របស់វានៅក្នុងប្រទេសក្នុងគោលបំណងរៀបចំផែនការក្បត់បំផ្លាញក្បាលម៉ាស៊ីនបក្ស បំផ្លាញបដិវត្តន៍កម្ពុជា បំផ្លាញប្រជាជននិងប្រទេសកម្ពុជាយើង ។

នៅថ្ងៃ ១២ ឧសភា ពេលចេញដំណើរ យន្តហោះមិនអាចដឹកឥវ៉ាន់មកបានទេ អាចដឹកតែមនុស្សបាន ។ គណៈធ្វើដំណើរដែលមានមិត្ត ស៊ូ ជាប្រធានសាខា បានសម្រេចឲ្យខ្ញុំនិងមិត្តពីរនាក់ទៀត (ទោង និង ខឹម) ចាំដឹកឥវ៉ាន់មកក្រោយ ។ ឥវ៉ាន់នោះមានឯកសារវិទ្យុ ឯកសារមន្ទីរតំណាងបក្ស សម្ភារប្រើប្រាស់ផ្សេងៗ រួមទាំងឥវ៉ាន់របស់ផ្នែក«អា.កា.អ៊ី» ទាំងអស់មាន៣តោន ។ ថ្ងៃស្អែក ១៣ ឧសភា ឈ្មោះ ទោង និង ឈៀង ក៏ដឹកឥវ៉ាន់មួយចំនួនមកមុន ។ ខ្ញុំនៅចាំយន្តហោះដើម្បីដឹកឥវ៉ាន់ដែលនៅសល់ប្រមាណ១តោនជាមួយឈ្មោះ ខឹម ។ នៅរយៈពេល២ថ្ងៃនេះយើងរង់ចាំនៅទីស្នាក់ការ«អា.កា.អ៊ី» ហើយបានទទួលឈ្មោះ ហិញ អនុប្រធានស៊ី.ភី៤៨ មកប្រាប់យើងខ្ញុំថាកុំបារម្ភអីស្អែកប្រុងខានស្អែកមានយន្តហោះទៅភ្នំភ្លឺក្ញុំហើយ ។ នៅថ្ងៃ ១៥ ឧសភា ១៩៧៥ យើងខ្ញុំជិះឧទ្ធម្ភាគចក្រមកដល់ភ្ជុំក្ញុំ ។ នៅភ្ជុំក្ញុំ មានសមមិត្ត ខ្មៅ សមាជិកគណៈតំបន់ស្ទឹងត្រែងបានរង់ចាំទទួលយើងខ្ញុំឲ្យមកដល់ស្ទឹងត្រែងនៅថ្ងៃ ១៧ ឧសភា ។ ថ្ងៃ ១៩ ឧសភា យើងខ្ញុំមកដល់មន្ទីរ ប-២០ ហើយនៅថ្ងៃ ២៧ ឧសភា ១៩៧៥ យើងខ្ញុំជិះកប៉ាល់ពីស្ទឹងត្រែងមកដល់ភ្នំពេញ ។

នៅថ្ងៃ ២៨ ឧសភា ១៩៧៥ សមមិត្ត ហុង ប្រធានមន្ទីរ ប-១ បាននាំខ្ញុំ មី និង នុប មក ក-២ បម្រើអ្នកបច្ចេកទេសចិន ។ នៅ ក-២ យើងខ្ញុំបំពេញភារកិច្ចដោយជ្រះស្រឡះទុកភារកិច្ចជាការកសាងខ្លួនជាក់ស្តែង ។ យើងខ្ញុំរស់នៅកន្លែងនោះជាមួយអាក្បត់ សុខ ទូនជល្លា ។ យើងខ្ញុំមិនបានចាប់អារម្មណ៍ដល់សកម្មភាពក្បត់របស់វាទេ ។ យើងគ្រាន់តែសង្កេតឃើញថាវាមានអាកប្បកិរិយាគោរពយើងហួសហេតុ ហើយមានជំហរមើលងាយបងប្អូនមូលដ្ឋាន ។ ក្នុងពេលនោះអា សុខ ទូនជល្លា បានប្រាប់ខ្ញុំថាវាបានជួបនឹងនារីអាមេរិកម្នាក់ដែលតាំងខ្លួនជាអ្នកប្រឆាំងសង្គ្រាមនៅកម្ពុជាឈ្មោះ ឡូរ៉ា ស៊ុមម័រ (Laura summer) ។ នារីអាមេរិកនេះមកភ្នំពេញនៅឆ្នាំ១៩៧១ ហើយការពិតវាជាភ្នាក់ងារសេ.អ៊ី.អាតាមអាក្បត់នេះ ។ មីនេះបានប្រាប់វាថា វាស្គាល់សមមិត្ត អ៊ុក សាគុន និងអា តូច ខាំឿន នៅប៉ារីស ។ ពីថ្ងៃ ១៦ មិថុនា មកដល់ថ្ងៃ ១៥ កក្កដា ១៩៧៥ ខ្ញុំស្នាក់អាស្រ័យនៅផ្ទះជិតមុខវាំងនៅមាត់ទន្លេជាមួយ គាត ឈន់ និងអា សៅ ។ ខ្ញុំទទួលភារកិច្ចតាមដានវិទ្យុបរទេសរាយការណ៍និងធ្វើទស្សនៈសភាពការណ៍រាល់ខែ ។ នៅកន្លែងនោះ អាក្បត់

តូប ភៀន ខស្សាហ៍ឡើងចុះជាមួយ គាត ឈន់ តែបើនៅកន្លែងនោះវាមិននៅយូរទេ ។ សៀង ប៉ូសែ ក៏ខស្សាហ៍ឡើងចុះដែរ ។ ការនិយាយស្តីគឺគិតគូរតែដុំវិញបញ្ហាហូបនិងសម្ភារប្រើប្រាស់ផ្សេងៗដូចជា មង សំណាញ់ ទូកដើម្បីចាប់ត្រីជាដើម ។

◆ថ្ងៃ ១៥ កក្កដា ៧៥ យើងទាំងបីនាក់ក៏មកនៅកន្លែង ប-១សព្វថ្ងៃ ។ នៅកន្លែងថ្មីភារកិច្ចរបស់ខ្ញុំនៅតែដដែល ។ បន្ទាប់មកយើងខ្ញុំបានទទួលការណែនាំឲ្យរៀបចំទស្សនកិច្ចគណៈប្រតិភូរដ្ឋាភិបាលទៅប្រទេសចិននិងទៅប្រជុំសន្និសីទរដ្ឋមន្ត្រីការបរទេសប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងលីម៉ាប្រទេសប៉េរូ ។ ខ្ញុំក៏បានចូលរួមក្នុងដំណើរការទស្សនកិច្ចនេះនៅខែសីហា ឆ្នាំ១៩៧៥ ក្នុងឋានៈជាអ្នកជំនួយការ ។ ក្រសួងការបរទេសយើងក៏ចាប់បង្កបង្កើតជាបន្តបន្ទាប់ក្រោមការដឹកនាំផ្ទាល់របស់បក្សដែលប្រកាន់យ៉ាងរឹងមាំនូវមាគ៌ាវណ្ណៈនិងគោលជំហរកសាងពីតិចទៅច្រើន ពីទាបទៅខ្ពស់ ដោយយកកត្តាសតិអារម្មណ៍និងកត្តានយោបាយជាសំខាន់ កត្តាបច្ចេកទេសជាកត្តារួមផ្សំ ។

តាំងពីមកបំពេញភារកិច្ចនៅក្រសួងការបរទេសពេលរំដោះភ្នំពេញមកដល់សព្វថ្ងៃនេះ បក្សបន្តសន្តោសអធ្យាស្រ័យអនុគ្រោះចំពោះរូបខ្ញុំ ហើយបានពុះពារអប់រំ កសាងជាប្រចាំអំពីមាគ៌ាជាយុទ្ធសាស្ត្រនិងជាយុទ្ធវិធីរបស់បក្សក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយមនិងការកសាងសង្គមនិយមអំពីមាគ៌ាវណ្ណៈអំពីគោលជំហរជឿជាក់លើការដឹកនាំនិងមោទនភាពលើបក្សរបស់ខ្លួន អំពីស្មារតីជាម្ចាស់ប្រទេស ជាម្ចាស់បដិវត្តន៍ដោយប្រកាន់នូវគោលជំហរឯករាជ្យម្ចាស់ការអំពីសារៈសំខាន់នៃគោលជំហរសតិអារម្មណ៍និងគោលជំហរនយោបាយក្នុងគ្រប់បញ្ហាអំពីមាគ៌ាវណ្ណៈរបស់បក្ស អំពីមាគ៌ានយោបាយបរទេសរបស់បក្សអំពីការចាំបាច់ត្រូវកសាងគោលជំហរវណ្ណៈអធនរបស់បក្សត្រូវកសាងលោកទស្សនៈបដិវត្តន៍ លោកទស្សនៈកុម្មុយនិស្ត ។ តាំងពីចូលបក្សហើយ ជាពិសេសតាំងពីរំដោះមកខាងផ្នែកនយោបាយខ្ញុំឯកភាពទាំងស្រុងជាមួយបក្សជាទស្សនៈលើបញ្ហាមិនចាយលុយ គ្មានផ្សារ គ្មានប្រាក់ខែ បញ្ហាជម្លៀសប្រជាជនពីទីក្រុងពីបញ្ហាធ្វើសហករណ៍ ពីការបន្តធ្វើបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមពីរដ្ឋអំណាចបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមពីរដ្ឋអំណាចបដិវត្តន៍កម្មករ កសិករ ពីរបបសមូហភាពពីមាគ៌ានយោបាយបរទេសរបស់បក្ស ពីមាគ៌ាការពារនិងកសាងប្រទេស ។

ពេលចូលមកក្នុងប្រទេសខ្ញុំមានការរំភើបក្រៃលែងដោយបានមកផ្សារភ្ជាប់ខ្លួនឡើងវិញជាមួយមាតុភូមិជាទីស្នេហា បានមកបម្រើបក្ស បម្រើប្រជាជន ។ ខ្ញុំរីករាយជ្រះស្រឡះក្នុងភារកិច្ច ជាពិសេសពេលចូលមកភ្នំពេញភ្លាមក្នុងរយៈកាលបម្រើភ្ញៀវនៅ ក-២ ។ ជាបន្តបន្ទាប់មកទៀតក្នុងការបំពេញភារកិច្ចនេះខ្ញុំចេះតែខំប្រយុទ្ធបំពេញតាមកម្រិតភ្ញាក់រឭកតាមការយល់ដឹងនិងតាមសមត្ថភាព ។

បក្សបានផ្សារភ្ជាប់ខ្លួនខ្ញុំមកប្រទេសជាតិវិញ មកបដិវត្តន៍កម្ពុជាវិញ បានធ្វើឲ្យខ្លួនខ្ញុំរស់ឡើងវិញ មានកិត្តិយស មានសុភមង្គល ជាជនបដិវត្តកម្ពុជា ជាបុត្រជនកម្ពុជា ។ គុណបំណាច់ដ៏ធំធេងនេះរបស់បក្សរបស់បងៗដឹកនាំបក្សខ្ញុំមិនអាចបំភ្លេចបានទេក្នុងមួយជីវិតខ្ញុំនេះ ។ នេះជាសេចក្តីប្តេជ្ញាចិត្ត ជាគោលបំណងដ៏ពិសិដ្ឋរបស់ខ្ញុំ ។ តែឆ្លងតាមការជាក់ស្តែង ពិសេសឆ្លងតាមចលនាបន្តបោសសម្អាតខ្មាំងជាក្បាលក់ងារសេ.អ៊ី.អាកា.ហ្សេ.បេ និងអាយួនលេបទឹកដីឲ្យអស់រលីងពីដូរយើង ពីមាតុប្រទេសយើង ពីក្រសួងយើង ខ្ញុំបានចាប់អារម្មណ៍និងពិនិត្យឃើញការខ្វះខាតរបស់ខ្ញុំមួយចំនួនតាមសភាពនៃការភ្ញាក់រឭកនិងកម្រិតយល់ដឹងរបស់ខ្ញុំសព្វថ្ងៃដូចតទៅ÷

១) គោលជំហរវណ្ណៈអធនរបស់បក្សមិនទាន់រឹងមាំ ធាតុវណ្ណៈអនុធនជាបញ្ញាជន ធាតុវណ្ណៈជិះជាន់ជំពាក់ជំពិននឹងមុខមាត់បុណ្យសក្តិ ភ្លឺតភ្លើននឹងតំណែងនាទី ។ ពេលលំបាកស្មុគស្មាញជំហរប្រយុទ្ធពុះពារខបសគ្គមិនរឹងមាំច្រើនធ្លាក់ទៅក្នុងទុទិដ្ឋិនិយមទ្រសភាពការណ៍នាំឲ្យបាត់សកម្មភៀវក្លា ។ ពេលជ័យជំនះ ពេលស្រួល មានសភាពស្រាក់ស្រាំសកម្មប្រយុទ្ធ ។

២) លោកទស្សនៈបដិវត្តមិនទាន់រឹងមាំ ។ លោកទស្សនៈវណ្ណៈជិះជាន់ វណ្ណៈនាយទុន សក្តិភូមិ លោកទស្សនៈសើរើមកលងនៅពេលលំបាក ពេលស្មុគស្មាញ ពេលសភាពការណ៍បត់បែន ។ ពិសេសមិនចាប់អារម្មណ៍ជាប្រចាំឲ្យក្តៅជាប់ ហើយស៊ីជម្រៅ

ពីបញ្ហារស់ដើម្បីបម្រើឧត្តមគតិមួយគឺធ្វើបដិវត្តន៍ ហើយធ្វើបដិវត្តន៍ដើម្បីអ្វី ដើម្បីអ្នកណា? ខ្ញុំមិនបានរំពូកឲ្យបានគ្រប់ពេលវេលា គ្រាលំបាកក៏ដូចគ្រាស្រួលនូវឧត្តមគតិដែលនាំឲ្យខ្ញុំចូលបដិវត្តន៍ ឧត្តមគតិដែលបក្សបានអប់រំថែបំប៉នបំផុសជាប្រចាំធ្វើបដិវត្តន៍ដើម្បីប្រទេសជាតិបានចាកផុតពីខ្ញុំគេឲ្យសម្បូរថ្កុំថ្កើងរុងរឿង ឲ្យប្រជាជនក្រីក្រ កម្មករ កសិករ បានរំដោះនិងឡើងកាន់កាប់វាសនាប្រទេសជាតិនិងវាសនាខ្លួនដោយខ្លួនឯង ។

៣) ខ្ញុំនៅជាប់ជំពាក់ជំពិនមិនទាន់បំបាត់ចោលឲ្យអស់រលីងនូវកម្មសិទ្ធិខាងបញ្ញា ខាងសមត្ថភាពបច្ចេកទេសនៅឡើយ ។ ជាបច្ច័យនៅពេលខ្លះនៅមើលស្រាលខាងកត្តាសតិអារម្មណ៍និងគោលជំហរនយោបាយ ។ ជាក់ស្តែងខ្ញុំនៅមិនទាន់ជ្រួតជ្រាបទស្សនៈនិងមាគ៌ាមហាជន ពិសេសមាគ៌ាវណ្ណៈរបស់បក្ស ។ ឥឡូវជាការយល់ដឹងឯកភាពជាមួយបក្សលើបញ្ហានេះតែត្រូវសាកល្បងសាចុះសាឡើងតាមការជាក់ស្តែងទៀត ។

៤) គោលជំហរនេះស្មោះត្រង់ជាមួយបក្ស ។ ជារួមខ្ញុំមិនមានគំនិតដើរខុបាយកលប្រឆាំងបក្ស ប្រឆាំងបដិវត្តន៍ប្រឆាំងប្រជាជនទេ ។ តែក្នុងការជាក់ស្តែងដោយមិនជ្រួតជ្រាបមាគ៌ារបស់បក្សនិងដោយមានបុគ្គល ខ្ញុំមិនបានរំលេចគោលជំហរនិងសតិអារម្មណ៍ស្មោះត្រង់ជាមួយបក្សឲ្យជាសកម្មភាពក្លៀវក្លាមោះមុតដើម្បីការពារមាគ៌ាបក្សនិងអនុវត្តមាគ៌ារបស់បក្សឲ្យបានល្អផូរផង់ជានិច្ច ។ ខ្ញុំច្រើនជាអ្នកសង្កេតការណ៍នៅឡើយ ។

៥) ខ្ញុំនៅមិនទាន់បានសាកល្បងក្នុងចលនាក្តៅស្លាប់រស់មិនទាន់បានលត់ដំខ្លួនញក់ញីសាចុះសាឡើង ។ ដូច្នោះមិនទាន់ទុកចិត្តខ្លួនឯងឲ្យបានពេញលេញ មិនទាន់មានពិសោធន៍គ្រប់គ្រាន់ក្នុងការកសាងខ្លួនក៏ដូចក្នុងការកសាងកម្លាំងរបស់បក្សរបស់បដិវត្តន៍ ។

**ទិសដោះស្រាយគុណវិបត្តិធំៗរបស់ខ្ញុំគឺ ÷**

១) ពុះពារពង្រឹងពង្រីកគោលជំហរស្មោះត្រង់ជាមួយបក្សដោយខិតខំរៀនសូត្រពិចារណាពីមាគ៌ារបស់បក្ស ហើយអនុវត្តមាគ៌ានេះឲ្យល្អជានិច្ចតាមការបំពេញភារកិច្ចប្រចាំថ្ងៃ ។

២) ពុះពារកសាងពង្រឹងនិងពង្រីកគោលជំហរវណ្ណៈអធនរបស់បក្ស កសាងខ្លួនឲ្យទៅជាកម្មកររបស់បក្ស ។

៣) កសាងនិងពង្រឹងពង្រីកលោកទស្សនៈបដិវត្ត ពិសេសត្រង់បញ្ហាធ្វើបដិវត្តន៍ដើម្បីអ្វី ដើម្បីអ្នកណា ។

៤) រៀនសូត្រតាមគំរូបដិវត្តន៍រស់រវើកដ៏ថ្លៃថ្លារបស់ប្រជាជន កម្មករ កសិករ សមូហភាព និងកងទ័ពបដិវត្តន៍យើងពិសេសតាមជីវិតបដិវត្តដ៏រុងរឿងឧត្តុង្គឧត្តមអស្ចារ្យ តាមគោលជំហរលះបង់ឥតត្រើយត្រាណរបស់បងៗដឹកនាំបក្សដែលខ្ញុំបានស្គាល់ស្រឡាញ់គោរពតាំងពីដើមរៀងមក ។

ប្រវត្តិរូបនេះខ្ញុំសរសេរឡើងតាមកម្រិតភ្ញាក់រឭករបស់ខ្ញុំនិងតាមកម្រិតយល់ដឹងនិងកម្រិតស្មារតីស្មោះត្រង់របស់ខ្ញុំចំពោះបក្សក្នុងពេលដែលបក្សអំពាវនាវឲ្យបន្តចលនាបោសសម្អាតខ្មាំងជាភ្នាក់ងារសេ.អ៊ី.អា កា.ហ្សេ.បេនិងអាយួនលេបទឹកដីដែលវាបង្កប់ស៊ីរូងផ្ទៃក្នុង ។ ខ្ញុំយល់ថាយោងទៅតាមជំហរវណ្ណៈរបស់ខ្ញុំសព្វថ្ងៃនិងកម្រិតការភ្ញាក់រលឹកសព្វថ្ងៃ ខ្ញុំមិនទាន់ចាប់អារម្មណ៍ឲ្យដល់កម្រិតពីការខ្វះខាតរបស់ខ្ញុំនៅឡើយទេបើប្រៀបធៀបនឹងសំណូមពររបស់បក្សនិងមហាចលនាមហាជនដ៏សន្ធោសន្ធៅពុះកញ្ជ្រោលសព្វថ្ងៃនេះ ។

ជាសរុបខ្ញុំបានពិនិត្យជីវិតបដិវត្តរបស់ខ្ញុំឃើញថាបត់បែនស្មុគស្មាញមានទទួលឥទ្ធិពលខ្មាំងនៅច្រើនជាទស្សនៈ ជាអត្តចរិត ។ ពេលគ្រាលំបាកស្មុគស្មាញ ពេលដែលខ្ញុំហៀបនឹងធ្លាក់ក្នុងជ្រោះដ៏ជ្រៅ ហៀបនឹងវិនាសអន្តរាយដូចជាបញ្ហាសេរី បញ្ហាគ្រួសារបក្សបានមកសង្គ្រោះខ្ញុំឲ្យផុតពីស្លាប់ ឲ្យផុតពីផ្លូវដ៏ថោកទាបជាជនក្បត់ជាតិ ជនក្បត់បដិវត្តន៍ ។ ដូច្នោះជីវិតបដិវត្តរបស់ខ្ញុំដែលបានរស់រានរហូតមកដល់សព្វថ្ងៃនេះ សុភមង្គលជាជនបដិវត្តន៍ ជាជនកុម្មុយនិស្តរបស់ខ្លួនសព្វថ្ងៃនេះ គឺជាស្នាដៃផ្ទាល់ឥតប្រកែកបានរបស់បក្សដែលបានអនុគ្រោះសែនធំមហិមាដល់ខ្លួនខ្ញុំ ។ ដើម្បីជាការតបស្នងសងគុណចំពោះបក្ស ខ្ញុំមានតែធ្វើការប្តេជ្ញាចិត្តជាទីអវសានដូចតទៅៈ "លះបង់អ្វីៗទាំងអស់ដើម្បីបក្ស បដិវត្តន៍ និងវណ្ណៈ" ។

ភ្នំពេញថ្ងៃសុក្រ ទី១៧ មិថុនា ១៩៧៧

**(ចប់ដោយបរិបូណ៌)**

# ទូរស័ព្ទសម្ងាត់

**◆◆◆ជូនបង៨៩, ទីគោរព ជ្រាប** ១) ថ្ងៃ ៤-២ មិត្តនៅកោះព្រីងបានបាញ់ទូកនេសាទថៃមួយគ្រឿងនៅខាងលិចកោះព្រីងប្រហែល ៥គីឡូម៉ែត្រ រួចវារត់ទៅទិសខាងលិចបាត់ទៅ ។ ២) នៅម៉ោង៦ល្ងាចថ្ងៃ ៥-២នេះ ខាងនេសាទរដ្ឋបាននាំទូកសៀមចូលកោះរុង តែពុំទាន់ដឹងហេតុផលអីផងក៏នាំចេញទៅវិញបាត់ ។ ៣) នៅម៉ោង៨ៈ២៥នាទីថ្ងៃ ៥-២ បងប្អូននៅកោះសេះឃើញគេអា ២ គ្រឿង បេអឹ១គ្រឿងចេញពីខាងត្បូងកោះត្រល់ព័ទ្ធពីខាងលិចវាងចូលកោះត្រល់វិញពីខាងជើង ។ បន្ទាប់មកនៅម៉ោង៦ៈ១៥នាទីបងប្អូន ឮស្នូរកាំភ្លើង១០៥បីគ្រាប់ធ្លាក់ចំកោះត្រល់បែកផ្កាភ្លើងព្រាត ក្រោយមកទៀតនៅម៉ោង៧ៈ១៥នាទីមានបេអឹ ២គ្រឿងមក រួមផ្សំជាមួយអាមុន ហើយបាញ់១២,៧ពីរដងទៅលើកោះត្រល់យ៉ាងខ្លាំង ។ ថ្ងៃ ៦-២, មុត ,ចម្លងជូនបង៨៧ បង៨៩ បង, ឯកសារ (ដកស្រង់ចេញពីឯកសារលេខ ០២បបក) **◆◆◆កងពល១៦៤, ផ្នែកន.ប, សេចក្តីរាយការណ៍ថ្ងៃទី ១២-៨-៧៧ "តាមទូរស័ព្ទសម្ងាត់"** ១) ម្សិលមិញថ្ងៃទី១១-៧-៧៧ យើងចេញល្បាតចាប់បានទូក២គ្រឿង ១ធុន៣៥០សេស ១ទៀត ធុន១៧៥សេស ។ ទូកធុន១៧៥សេសមាន មនុស្ស៥នាក់គ្មានប្រដាប់នេសាទទេ ។ ចាប់បាន នៅកៀកកោះកុងប្រហែល២គីឡូម៉ែត្រ ។ ក្រោយ មកយើងបានសាកសួរឆ្លើយថាដឹងរឿងចាត់តាំង ខ្មែរសនៅស្រុកថៃច្រើន ។ ជាមួយនេះវាបាន ដឹងខ្សែចាត់តាំងចូលមកក្នុងស្រុកយើងច្រើន ស្គាល់ទាំងឈ្មោះថែមទៀត ។ ឥឡូវទាំង៥នាក់ បានយកមកដល់កំពង់សោមហើយ ។ យើងកំពុង សួរថែមទៀត ។ ទាំង៥នាក់នេះមានខ្មែរម្នាក់ ក្រៅពីនេះសៀម ។ នៅលើទូក១៧៥សេស មាន




ក្បួនបុស្សី១៥ ។ (?) តាមជួបសមមិត្ត មុត តាមទូរស័ព្ទថា ក្បួនមួយទេ ។ ២) ម្សិលមិញពេលទូក១៧៥សេស ធ្វើដំណើរមកដល់ ពយអាវយាយសែន មានយន្តហោះប្រតិកម្មមួយគ្រឿងហោះឆ្វេលពីលើ មិនស្គាល់ធុនអីទេ មានកម្ពស់ប្រហែល២-៣គីឡូម៉ែត្រ ។ ៣) ថ្ងៃមិញនេះ ម៉ោង២រសៀលមានយន្តហោះមួយគ្រឿងហោះលើកំពង់សោម កម្ពស់ប្រហែល១២ទៅ១៣គីឡូម៉ែត្រ ហោះទិស ពីលិចទៅកើត ។ ទទួលម៉ោង៧ៈ២៧នាទីយប់ថ្ងៃទី១២-៨-៧៧, មុត ជូនអង្គការ ១.យើងខ្ញុំឲ្យសួររកខ្សែខាងក្នុង ២.រកផ្លូវ ចេញចូល ៣.សភាពការណ៍ពួកអាក្បត់នៅតាមព្រំដែន ។ ខៀវ,១៣-៨ (ដកស្រង់ចេញពីឯកសារលេខ ១៣បបក)

**◆◆◆កងពល១៦៤, ផ្នែកន.ប ទូរស័ព្ទសម្ងាត់ចុះថ្ងៃទី១-៤-៧៨ សេចក្តីរាយការណ៍** ១) សរុបយួនដែលបាញ់ បាននិងបាញ់ផាប់ចាប់ពីថ្ងៃ២៧-៣-៧៨មកដល់ថ្ងៃទី៣០-៣-៧៨ មានចំនួន១២០ក្បាល ទូក១០សេស ដល់៣៧សេសចំនួន ៥គ្រឿងអាវុធមួយចំនួនក្នុងនោះអឹម៧៩១ដើមនិងសម្ភារផ្សេងៗមួយចំនួន ។ ២) សៀមដែលត្រូវដោះលែងមានការយឺតយូរ មិនបានតាមការកំណត់មូលហេតុមកពីមានការខុសឈ្មោះអ្នកដែលមកទទួលខ្លះ តែខុសនេះពិនិត្យគឺមិនមានខុសទាំងស្រុងទេ គឺខុសចុង

ឈ្មោះបន្តិចៗជាមូលដ្ឋានត្រូវ ឯការទាក់ទងដល់យោបល់ ក៏មិនបានតាមសំណូមពរដោយគេអូមិនព្រមគ្នា ផ្អែកលើទូរលេខខាងសមមិត្តឡូញ ហើយដោយមានការបញ្ជូនសារយឺតនិងបាត់បានធ្វើឲ្យការប្រគល់ថ្ងៃនេះពន្យាររហូតដល់ម៉ោង២០ ថ្ងៃ៣១-៣-៧៨ អ្នកមកទទួលមានចៅហ្វាយស្រុកខ្វាងយ៉ៃម្នាក់និងម្នាក់ទៀតអ្នកប្រជាសង្គ្រោះ ។ អាសៀមដែលមកទទួលនេះបានឲ្យបារីពាសុង ប្រេងកូឡា ១ដបដល់មិត្តយើង ។ ៣) អំពីលទ្ធផលបាញ់សាកដាក់ស្តែងនៃគ្រាប់មីនបុកថ្ងៃ៣១-៣-៧៨ យើងចាប់ផ្តើមម៉ោង៨បាញ់ទៅរកទិសដៅតាមកំណត់ ។ ក្រោយចេញពីកាណុងគ្រាប់នេះមុជទៅក្នុងទឹកជម្រៅ២៥ម៉ែត្រ ទើបងើបមកធ្វើដំណើរតាមជម្រៅនិងទិសដៅដែលយើងកំណត់ យើងបាញ់២គ្រាប់ ។ ហើយគ្រាប់ទាំង២នេះយើងបាញ់ចេញ ចាប់ត្រងយកវិញដោយជោគជ័យមិនមានឧបសគ្គអ្វីធំដុំទេ យើងកំពុងដកពិសោធន៍ខាងបច្ចេកទេសនិងនយោបាយ ។ ថ្ងៃ៤-៤-៧៨ យើងបាញ់សាកម្តងទៀតដោយយកនាវាការពារមួយគ្រឿងធ្វើជាទិសដៅវាយប្រហារ ។ សុំស្នើសម្ភារកាំភ្លើង១២,៨២០ដើម មីត្រៃយ៉ើចិន៤០ដើម ដេកា៥៧ ២០ដើម សម្រាប់រៀបទូកចាប់ពី២២សេសដល់១០០សេស ចំនួន២០គ្រឿងទៀតឲ្យកោះ ដោយយកទូកតូចៗចេញយាមហើយកាណូតធំៗទុកសម្រាប់អន្តរាគមកាលណាទូកតូចៗមានការប្រយុទ្ធខាងមុខ ។ ដើម្បីបន្ធូរចំណាយប្រេងម៉ាស៊ីន ម៉ាស៊ូត ហើយធ្វើយ៉ាងនេះកើនចំនួនទូកយាមល្បាត ហើយមិនស្នើប្រេងម៉ាស៊ីនថែមទេ។ ថ្ងៃទី១-៤-៧៨, មុត ចម្លងជូន អ៊ុំ អ៊ុំនួន បងវ៉ាន់ ឯកសារ ដកស្រង់ចេញពីឯកសារលេខ (១៥បបក)◆◆◆**កងពល១៦៤ ផ្នែកន.ប ទូរស័ព្ទសម្ងាត់ចុះថ្ងៃទី២០-៣-៧៨ ជូនបង៨៩, គោរព សភាពការណ៍សមុទ្រ** ៖ ១) នៅកែប វេលាម៉ោង៨យប់ថ្ងៃ១៩-៣-៧៨ យើងបាញ់កាណូតអាយួនលិច ១គ្រឿង ធុន២២សេស នៅខាងត្បូងកោះខ្ចងចម្ងាយ១គីឡូម៉ែត្រ ។ ឯយើងមិនមានខូចខាតអីទេ ។ ២) នៅកោះវៃយប់ថ្ងៃទី ១៩-៣-៧៨ ម៉ោង៤ព្រឹកឡើងថ្ងៃ២០-៣-៧៨ បងប្អូនឃើញកាណូតសៀម១គ្រឿងនៅខាងលិច ឆៀងខាងជើងកោះវៃចាស់ចម្ងាយ៣គីឡូម៉ែត្រ យើងដេញចាប់វាបាននៅម៉ោង៥ភ្លឺ កាណូត២៥០សេស មានមនុស្ស២១នាក់ ។ ៣) នៅកោះតាង វេលាម៉ោង ២:៣០នាទីថ្ងៃ២០-៣-៧៨ កាណូត៨០០សេសរបស់យើងចេញធ្វើការនៅខាងកើតភាគខាងត្បូងកោះតាង ចម្ងាយ១២ គីឡូម៉ែត្រ ចាប់បានកាណូត២គ្រឿងនេះពេញដោយយួន៧៦នាក់ មានក្មេង ចាស់ ប្រុស ស្រី ។ តែក្នុងពេលយើងចងរួចហើយកូនកាណូតតូចឃ្វាងបណ្តាលឲ្យធ្លាក់ទឹកបាត់២នាក់ រកពុំឃើញ ។ បានឲ្យយកមកដល់ដីគោកហើយ ។ ថ្ងៃ២០-៣-៧៨, មុត (ដកស្រង់ចេញពីឯកសារលេខ ១៥បបក)◆◆◆ **កងពល១៦៤ ទូរស័ព្ទសម្ងាត់ចុះថ្ងៃទី៤-៤-៧៨ ផ្នែកន.ប ជម្រាបជូនបង៨៩ គោរព** ១) សភាពការណ៍ថ្ងៃ៣-៤-៧៨ មានព្រួសរបាញ់កាំភ្លើង១០៥មីលីម៉ែត្រជាច្រើនគ្រាប់នៅលើកោះត្រល់ ឯក្រៅពីនេះពុំទាន់មានអ្វីប្លែកទេ ទាំងខាងយួនទាំងខាងថៃ ។ ២) អំពីការបាញ់មីនសាកលើកទី២ថ្ងៃទី៤-៤-៧៨ សភាពការណ៍ទាំងការរៀបចំខាងតួរមីននិងខាងនាវា ជារួមមានពិសោធន៍មួយកម្រិតក្នុងកិច្ចដំណើរការ ។ ពេលបាញ់ដាក់ស្តែងម៉ោង៨ព្រឹកមិញ គ្រាប់មីនចេញពីកាណុងសំដៅទៅនាវាស៊ីបចំទិសដៅដែលយើងកំណត់បានល្អ ។ យើងបាញ់២គ្រាប់ ប៉ុន្តែមានឧបសគ្គពេលស្រង់មីនឡើងមានមីន១គ្រាប់ ពេលស្ទូចពីក្នុងទឹកយើងចងក្បាលមិនបានចងពាក់កណ្តាលខ្លួនដោយមីននោះវាលិចទៅក្នុងទឹកបណ្តាលឲ្យប៉ះបោកកប៉ាល់គេអាដែលដាក់ឡានស្ទូចខ្ទួនក្បាលសម្រាប់បាញ់ហាត់និងតួរមីន កំណាត់ខាងស្លាបចក្រកំពិតប៉ុន



បាតដៃ ឯកំណាត់បណ្តោយដែលមានគ្រឿងម៉ាស៊ីននៅល្អធម្មតា តាមមើលកំណាត់ទាំងពីរដែលកំពិតនេះប្រើតទៅទៀតមិនកើតទេ ។ ទន្ទឹមនេះមានរបួសមិត្តយើង២នាក់ ម្នាក់ធ្ងន់ ម្នាក់មធ្យម ហើយជាមួយនេះរបួសមិត្តចិនម្នាក់ ដោយមីន ពេលស្ទូចឡើងវាបោកផ្ទប់កប៉ាល់គេអា ។ មិត្តចិនដែលរបួសយើងខ្ញុំបានបញ្ជូនទៅព.១៧ ហើយយប់នេះ ។ តាមពិនិត្យមូលហេតុជាបឋមគឺរលកថ្មាំងថ្នាក់ទី៨ ពេលស្រង់មីន ។ កាលពីពេលបាញ់មិនសូវរលកប៉ុន្មានទេ ។ ចម្លងជូន អ៊ី អ៊ីនួន បងវ៉ាន់ បង វន មន្ទីរ ថ្ងៃ៤-៤-៧៨, មុត (ដកស្រង់ចេញពីឯកសារលេខ ១៥បបក)◆◆◆**កងពល១៦៤ ផ្នែកឧ.ប សារតាមទូរស័ព្ទសម្ងាត់ចុះថ្ងៃទី១៣-៧-៧៧ គោរពជូនសមមិត្តបង មុត ស្នេហាជ្រាប** ១) សភាពការណ៍អគ្គភាពយើងនៅអូរឈើទាលនិងនៅកោះរុងសន្លឹមមិនឃើញមានសកម្មភាពអ្វីប្លែកទេ ។ ដោយឡែកសភាពនៅរាមខ្ញុំបានទៅជួបធ្វើការងារជាមួយបងប្អូននៅមានបញ្ហាមួយចំនួនដូចខាងក្រោមនេះៈ ឈ្មោះមិត្ត ចន អ្នកដឹកជញ្ជូនគេ.៩១៨ បានដើរកម្សាចនៅក្នុងក្រុមដឹកជញ្ជូនដូចគ្នាថាឲ្យរៀបចំប្រដាប់ប្រដាទាំងអស់ទាំងស្លុតទាំងសើមឲ្យលឿនទៅជួបសមមិត្តបង រឿន នៅឯអូរឈើទាលជាបន្ទាន់ក្រោយមកទៀតគាត់បានថាមិនបាច់យកឥវ៉ាន់អីទៅជាមួយទាំងអស់ទេព្រោះប្រញាប់ណាស់ ។ សភាពការណ៍នេះធ្វើឲ្យបងប្អូនក្រុមដឹកជញ្ជូននៅជាមួយគ្នាពីរ-បីនាក់ទេមានការព្រួយបារម្ភ ។ បញ្ហា


យុទ្ធជនវ័យក្មេងក្នុងលេណដ្ឋាន

ខាងលើនេះបានសាកសួររកទៅមិត្ត ចន ឆ្លើយថាគាត់និយាយលេងទេចំពោះរឿងនេះខ្ញុំបានពិភាក្សាជាមួយសមមិត្ត ខាត់ ឆេន និង ម៉ៅ ក្តាប់សភាពការណ៍នេះឲ្យជាប់នឹងដៃរួចស្រេចអស់ហើយ ។ ២) អំពីការសិក្សាបច្ចេកទេសនាវាការពារ ខ្ញុំបានទៅជួបសមមិត្តបង ហន ផ្ទាល់ គាត់ថាបានចប់សព្វគ្រប់អស់នៅថ្ងៃ១៧-៧-៧៧ ទាំងស្រុងហើយ ហើយអាចបម្រើសំណូមពររបស់បក្សបានទាំងស្រុង ។ ចំពោះការរៀនសូត្រថ្មីនេះកំពុងដំណើរការទៅជាប្រក្រតីមិនមានបញ្ហាអីស្មុគស្មាញទេ ។ ជូនសេចក្តីរាយការណ៍ខាងលើសុំសមមិត្តបងជ្រាប ទទួលម៉ោង៨ៈ៤៥នាទី ថ្ងៃទី១៤-៧-៧៧ ជូនពរអ្នកដឹកនាំសុខភាពល្អ ថ្ងៃ១៣-៧-៧៧ មឿន ចម្លងជូនបង៨៩ បងមុត មន្ទីរ ឯកសារ (ដកស្រង់ចេញពីឯកសារលេខ ៩បបក) ◆◆◆**កងពល១៦៤ ផ្នែកឧ.ប សារតាមទូរស័ព្ទសម្ងាត់ចុះថ្ងៃទី១៣-៧-៧ គោរពជូនសមមិត្តបង មុត ជ្រាប** បញ្ហាចិនចូលរួមពិនិត្យនិងកម្ចាត់ឧបសគ្គម៉ាស៊ីននិងរ៉ាដានាវា០២មិនទាន់ហើយទេ គេសំណូមពរយកនាវានេះទៅរាមដើម្បីៈ ១) ខាងម៉ាស៊ីនងាយស្រួលទាក់ទង ជាមួយរោងជាងគ្រឿង ។ ២) ខាងរ៉ាដាងាយស្រួលទាក់ទងជាមួយចិនខាងនេសាទឲ្យជួយធ្វើការ ហេតុនេះសុំយោបល់បងសម្រេចយ៉ាងណា ។ ទទួលម៉ោង ៨ៈ៤៥នាទី ថ្ងៃទី១៣-៧-៧៧ ជូនពរសុខភាពល្អថ្ងៃទី១៤-៧-៧៧, មឿន ចម្លងជូនបង៨៩ បងមុត មន្ទីរ ឯកសារ (ដកស្រង់ចេញពីឯកសារលេខ ៩បបក)◆◆◆ ***ដកស្រង់ចេញពីក្រុមឯកសារប្រភេទទូរសា ។ ឯកសារប្រភេទទូរសានេះមានចំនួនជាងមួយពាន់សន្លឹកបានបកប្រែជាភាសាអង់គ្លេសរួចហើយ ។***

**ឆាំង យុ**

## (តពីលេខមុន) ការជ្រើសរើសសត្រូវ

មន្ទីរសន្តិសុខ ស-២១ គឺជាស្ថាប័នពេញលេញមួយដែលមានបេសកកម្មស្វែងរក សួរចម្លើយ និងកម្ទេចខ្មាំងរបស់មជ្ឈិមបក្ស ។ បើយោងតាមការហូរចូលនៃចំនួនអ្នកទោសនិងចំនួនអ្នកទោសដែលត្រូវបានសម្លាប់ មន្ទីរសន្តិសុខ ស-២១ប្រហែលជាស្ថាប័នដ៏មានប្រសិទ្ធភាពបំផុតនៅក្នុងប្រទេសកម្ពុជា ។ បើគិតពីការសង្កត់ធ្ងន់របស់បក្សឲ្យការពារខ្មាំងវិញ មន្ទីរនេះក៏នៅតែមានសារៈសំខាន់ដែរ ។ ទ្រឹស្តីនៃរបបកម្ពុជាប្រជាធិបតេយ្យជឿថាមានខ្មាំង ហើយការតាមដានរកខ្មាំងគឺជាគ្រឿងផ្សំមួយមុខយ៉ាងសំខាន់ក្នុងការអនុវត្តជាក់ស្តែងរបស់ខ្លួន ។ ដោយសារតែអ្នកដឹកនាំកម្ពុជាដើរតាមលទ្ធិម៉ៅ "ខ្មាំង" ដែលប្រឆាំងនឹងបដិវត្តន៍ត្រូវបានបង្កើតជាបន្តបន្ទាប់ ហើយការបោសសម្អាតក៏ចាំបាច់ត្រូវតែមានជាបន្តបន្ទាប់ដែរដើម្បីធានាសន្តិសុខដល់មជ្ឈិមបក្សនិងរក្សាភាពស្អាតស្អំនិងការពង្រីកកម្លាំង ។ បើដូចនេះ ពាក្យថា"ខ្មាំង"ច្បាស់ជាមាននៅគ្រប់កន្លែង ។ "ការបោសសម្អាត" ខ្មាំងមិនចេះចប់ឡើយ ។ ការកសាងនិងការពារប្រទេសត្រូវមានការរួមដៃគ្នា ។ ដូចដែលទិសស្លោករបស់បក្សកុម្មុយនិស្តកម្ពុជាបានចែងថា "ដៃម្ខាងបង្កបង្កើនផល ដៃម្ខាងវាយខ្មាំង" ។[1]




**សម្លេងពីមន្ទីរ ស-២១**
**ខគ្គទី៣: ការជ្រើសរើសសត្រូវ**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ចំពោះ ប៉ុល ពត និងដៃជើងរបស់ខ្លួន មិត្តនិងសត្រូវគឺ "ទំនាស់ស្លាប់រស់" ។ ក្នុងការបែងចែកនេះ ប៉ុល ពត បានស្រង់សម្តីរបស់ ម៉ៅ សេទុង ដែលនិយាយនៅឆ្នាំ១៩៥៧ថា "ចំពោះការដោះស្រាយត្រឹមត្រូវនៃទំនាស់ក្នុងជួរប្រជាជន" ម៉ៅ សេទុង បានចាត់ទុក"ការកម្ចាត់ខ្មាំងបដិវត្តន៍"ថាជាឧទាហរណ៍នៃ "ទំនាស់ទី១"(ពោលគឺទំនាស់រវាងខ្មាំងនិងយើង) ។

២០ឆ្នាំក្រោយមក នៅក្នុងសុន្ទរកថាដែលមានរយៈពេល៤ម៉ោងដែលនិយាយអំពីអស្ថិរភាពរបស់បក្សកុម្មុយនិស្តកម្ពុជា ប៉ុល ពត បាននិយាយថា "នៅក្នុងសង្គមកម្ពុជាមានទំនាស់ស្លាប់រស់ដូចជាសត្រូវដែលជាខ្សែបង្កប់របស់ចក្រពត្តិនិងបនប្រតិកិរិយាបរទេស ។ ពួកនេះនៅតែបង្កប់ជាមួយយើងប្រព្រឹត្តនូវអំពើវិទ្ធង្សនាផ្សេងៗប្រឆាំងនឹងបដិវត្តន៍...ខ្មាំងប្រភេទនេះមានមួយចំនួនតូចទេគឺប្រហែល១ឬ២ភាគរយប៉ុណ្ណោះក្នុងចំណោមប្រជាជនយើងទាំងអស់" ។ តាមគំនិតរបស់ ប៉ុល ពត ក្នុងចំណោមប្រជាជនកម្ពុជាចំនួន៧លាននាក់យ៉ាងច្រើនមាន១៤០.០០០នាក់(២ភាគរយ)ប៉ុណ្ណោះជាខ្មាំងពិតប្រាកដរបស់របបនេះ ។ ប៉ុល ពត បន្ថែមថា "ទំនាស់ជាមួយពួកទាំងនេះត្រូវតែដោះស្រាយតាមវិធីដែលយើងដោះស្រាយជាមួយខ្មាំងដទៃទៀតដែរ" ។ វិធានការទាំងនេះរួមមាន"និយាយលួងឲ្យស្រួលស្តាប់" និង "អប់រំ" ខ្មាំងមួយចំនួន ហើយនៅសល់ពីនោះព្យាយាម "ធ្វើកុំឲ្យមានបញ្ហា" ។ ចុងក្រោយ ប៉ុល ពត ស្នើឲ្យ "បំបែកនិងកម្ទេចមនុស្សមួយចំនួនតូច ពោលគឺអ្នកដែលប្រឆាំងបដិវត្តន៍ដាច់ខាតនិងអ្នកដែលចូលដៃជើងជាមួយខ្មាំងបរទេសប្រឆាំងនឹងជាតិខ្លួនឯងប្រជាជនខ្លួនឯងនិងបដិវត្តន៍"[2] ។ ដូចដែល ប៉ុល ពត បាននិយាយដូច្នេះដែរ មានប្រជាជនចំនួនរាប់ពាន់នាក់ត្រូវបានសួរចម្លើយ ធ្វើទារុណកម្មនិងសម្លាប់ចោលនៅមន្ទីរ ស-២១ ។

កម្ពុជាប្រជាធិបតេយ្យបានបែងចែកខ្មាំងជាពីរពួក គឺខ្មាំងខាងក្នុងនិងខ្មាំងខាងក្រៅ ដូចដែល ស្តាលីន និង ម៉ៅ បានធ្វើដែរ ។ ខ្មាំងខាងក្រៅមានមហាអំណាចដឹកនាំដោយសហរដ្ឋអាមេរិកដែលប្រឆាំងនឹងសង្គមនិយមនិង"ពួកសេរីនិយម" ឬ "ពួកវាតទីនិយម" ដូចជាសហភាពសូវៀត វៀតណាមនិងសម្ព័ន្ធមិត្ត ។ ប៉ុល ពត និងបក្សពួកច្រើនតែនិយាយថាការបំផ្លាញប្រទេសកម្ពុជាមានសារៈសំខាន់ណាស់ចំពោះខ្មាំងទាំងនេះ ដែលតាមរយៈនេះពួកវា

និងមានលទ្ធភាពសម្រេចគោលបំណងរបស់វា ។ ដូចគ្នានេះដែរ ឯកសារដែលថែរក្សាទុកនៅមន្ទីរ ស-២១ នៅខែមីនា ឆ្នាំ ១៩៧៦ បានប្រមើលមើលថា កម្លាំងវៀតណាមខាងត្បូង និងវៀតណាមកុម្មុយនិស្តដែលត្រូវបណ្តេញចេញពីតំណែង កំពុងតែសហការរីករាយជាមួយគ្នានៅក្នុងប្រទេសវៀតណាម ដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ដោយសហការជាមួយប្រទេសថៃនិងក្រុមទី៧របស់អាមេរិក ។ ៦ខែក្រោយមកមានឯកសារមួយទៀតនៅមន្ទីរសន្តិសុខ ស-២១ ដកស្រង់ព័ត៌មានអំពីអតីតទាហានរបប លន់ ណុល ដែលបានទទួលការហ្វឹកហាត់នៅសហរដ្ឋអាមេរិកបានសរសេរអំពីអង្គការសន្ធិសញ្ញាអាស៊ីភាគអគ្នេយ៍មួយដែលមានតៃវ៉ាន់ កូរ៉េខាងត្បូង ឥណ្ឌូនេស៊ី និងវៀតកុង ជាសមាជិកគោលគំនិតនយោបាយចម្បងរបស់អង្គការនេះគឺចង់កម្ទេចកម្ពុជាប្រជាធិបតេយ្យ ។ នាឆ្នាំ១៩៧៨ នួន ជា មន្ត្រីជាន់ខ្ពស់ទី២របស់មជ្ឈិមបក្ស បានប្រាប់ដល់ភ្ញៀវជាជនជាតិដាណឺម៉ាកថា "គឺថា...អ្នកណាក៏ដឹងដែរថាសហរដ្ឋអាមេរិកមានផែនការចង់ប្លន់អំណាចពីយើង៦ថ្ងៃក្រោយពីការរំដោះភ្លាម ។




គម្រោងការនេះមានការចូលរួមពីសំណាក់សហរដ្ឋអាមេរិក កា.ហ្សេ.បេ និងវៀតណាម ។ ក្រុមនេះបម្រុងវាយព្រមគ្នាពីខាងក្នុងនិងខាងក្រៅ ។ ប៉ុន្តែយើងបានកម្ចាត់ផែនការនេះទាន់" ។

ខ្មាំងខាងក្រៅងាយស្រួលសម្គាល់ណាស់ ។ ពួកនេះត្រូវបានឃាត់ខ្លួនត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នដោយកងការពារនិងមិត្តភក្តិមហាអំណាច ។ ដូចដែល ប៉ុល ពត បាននិយាយទៅកាន់កម្មាភិបាលរបស់ខ្លួននៅក្នុងឆ្នាំ១៩៧៧ថា "ប្រទេសចិនអាចជួយកម្ចាសត្រូវរបស់យើង ។ មានមិត្តដូចជាចិននេះពិតជាល្អណាស់ ។ ក៏ប៉ុន្តែក្រុមប្រឆាំងផ្ទៃក្នុងរបស់របបនេះពិបាកសម្គាល់ណាស់ ។ ហើយមានគ្រោះថ្នាក់ជាងខ្មាំងខាងក្រៅ ។ ចំណែកអ្នកដែលធ្វើសកម្មភាពចេញមុខមិនបង្កជាគ្រោះថ្នាក់អ្វីឲ្យលេចធ្លោនោះទេ" ។ សមាសភាពទាំងនេះរួមមានប្រជាជន"ថ្មី" ឬ"១៧ មេសា" ដែលត្រូវបានជម្លៀសចេញពីក្រុងនានាកាលពីឆ្នាំ១៩៧៥និងប្រជាជនទាំងប្រុសទាំងស្រីនៅសល់ពីសង្គមចាស់ដែលមានដើមកំណើតនិងប្រវត្តិរូបមានការប៉ះពាល់ដល់បដិវត្តន៍ ។ ក្រោយ១៧ មេសា ឆ្នាំ១៩៧៥ ប្រជាជនប្រភេទនេះរាប់សែននាក់ត្រូវស្ថិតនៅក្រោមការឃ្លាំមើលយ៉ាងប្រុងប្រយ័ត្ននៅតាមជនបទឬក៏បញ្ជូនទៅសាលាអប់រំដែលមិនមានលក្ខណៈខុសពីគុកប៉ុន្មានឡើយ ហើយនៅទីនោះមានមនុស្សរាប់ពាន់នាក់ត្រូវបាត់បង់ជីវិត ។

## ខ្មាំងផ្ទៃក្នុង

អ្វីដែលធ្វើឲ្យបក្សមានការព្រួយបារម្ភជាងគេនោះ គឺខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ។ ទោះបីជាប្រជាជនទាំងនេះបានចូលបម្រើបដិវត្តន៍ក៏ដោយ ប៉ុន្តែឥឡូវកំពុងតែក្បត់នឹងបដិវត្តន៍វិញ ។ នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ នួន ជា បានវាយប្រហារខ្មាំងប្រភេទនេះជាចំហក្នុងឱកាសនិយាយជាមួយកម្មាភិបាលបក្ស ។ ២-៣ខែក្រោយមក បទវិចារណកថានៅក្នុងសៀវភៅទង់បដិវត្តន៍ប្រកាសថា ខ្មាំងផ្ទៃក្នុងបាន"ព្យាយាមផ្លាស់ប្តូរពណ៌សម្បុររបស់បដិវត្តន៍" ។ នៅឆ្នាំ១៩៧៨ មានបទវិចារណកថាមួយនៅក្នុងទិនានុប្បវត្តិសរសេរប្រឆាំងនឹងអ្នកដែលកាន់ផ្លាកបដិវត្តន៍បណ្តោះអាសន្នក្លែងខ្លួនធ្វើជាអ្នកបដិវត្តបង្កប់ខ្លួនដើម្បីកសាងកម្លាំងនៅក្នុងជួរបដិវត្តន៍និងបំផ្លាញបដិវត្តន៍ពេលដែលបដិវត្តន៍យើងចុះខ្សោយ មិនក្តៅឬមិនប្រយុទ្ធដាច់ខាតនៅពេល

ដែលបណ្តាញផ្ទៃក្នុងប្តូរពេលដែលយើងកាត់ផ្តាច់ពីមហាជន ។ ប៉ុន្តែឥឡូវនេះពេលកម្លាំងបដិវត្តន៍ប្រមូលផ្តុំគ្នាមានអំណាចខ្លាំងក្លា ពេលដែលបណ្តាញសម្ងាត់ភ្ញាក់រឭកដល់ចំណុចនេះ ខ្មាំងបង្កប់ផ្ទៃក្នុងលែងមានការលាក់ខ្លួនទៀតហើយទោះជាខ្មាំងទាំងនោះសំខាន់យ៉ាងណាក៏ដោយ ។ គ្រប់សកម្មភាពស្ងប់ស្ងាត់ការពារខ្លួន និងបិទមុខដែលសំដៅកម្ទេចបដិវត្តន៍ត្រូវបានមហាជនមើលឃើញយ៉ាងច្បាស់ ហើយអាចកម្ទេចតែម្តងគឺអស់ ។

នៅជិតចុងបញ្ចប់នៃរបបនោះ នៅពេលនិយាយជាមួយឈ្មោះ ដេវុឌ្ឍ នួន ជា បានកត់សម្គាល់ថា «យើងមិនព្រួយបារម្ភអំពី... ការឈ្លានពានដោយយោធាពីខាងក្រៅទេ ។ យើងបារម្ភបំផុតគឺខ្មាំងផ្ទៃក្នុង» ។ ការឈ្វេចរកខ្មាំងផ្ទៃក្នុងចេះតែបន្តជ្រៅទៅៗ ស្មុគស្មាញទៅៗ និងពិបាកជាងការ«កម្ទេច»ជនក្បត់ ។ គំនិតកេងប្រវ័ញ្ច ការចូលចិត្តនិងអាកប្បកិរិយារបស់ពួកគហបតីត្រូវបានគិតថាបានកប់យ៉ាងជ្រៅនៅក្នុងមនសិការរបស់ប្រជាជនគ្រប់រូប ហើយនេះគឺជាដើមគំនិតរបស់ ប៉ុល ពត ដែលដើរតាមស្តាលីន និង ម៉ៅ ។ នៅឆ្នាំ១៩៧៧ ប៉ុល ពត បានប្រកាសថា «យើងទាំងអស់គ្នាមាននាំយកមកនូវចរិតលក្ខណៈរបស់វណ្ណៈពីសង្គមចាស់ដែលបានចាក់ឫសយ៉ាងជ្រៅពីជំនាន់មុនៗ» ។ គំនិតទាំងនេះត្រូវតែបានកម្ទេចមុននឹងសម្រេចគោលដៅសង្គមនិយម ។ មួយឆ្នាំមុននេះ អ្នកនិពន្ធសៀវភៅទង់បដិវត្តន៍ម្នាក់បាននិយាយថា «ចំពោះសមាជិកបក្សនិងកម្មាភិបាលបក្សយើងត្រូវតែកម្ចាត់របស់អ្វីក៏ដោយឲ្យតែជារបស់វណ្ណៈជិះជាន់ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ជិហរ ទស្សនៈ មនោសញ្ចេតនា ទំនៀមទម្លាប់ វប្បធម៌ដែលស្ថិតនៅក្នុងខ្លួនយើងទោះតិចឬច្រើនក៏ដោយ» ។

ក្នុងការបោសសម្អាតជនក្បត់ និងប្រជាពលរដ្ឋកុំឲ្យមានគំនិត«គហបតី»សន្តិបាលបានធ្វើការយ៉ាងទូលំទូលាយ គ្មានដែនកំណត់និងគ្មានមេត្តា ។ ដូចដែលពាក្យស្លោករបស់កម្ពុជាប្រជា-ធិបតេយ្យបាននិយាយថា«ការចាប់ខ្លួនមនុស្ស១០នាក់ប្រឡំប្រសើរជាងដោះលែងមនុស្សម្នាក់ដែលមានកំហុស» ។

ពេលដែលត្រូវបានរកឃើញ ចាប់ខ្លួន និងយកទៅមន្ទីរ ស-២១ ជនសង្ស័យរបស់មជ្ឈិមបក្សក្លាយជា «ជនមានកំហុស» គឺមានកំហុសដោយសារខ្លួនត្រូវបានចាប់ចងមិនមែនដោយសារខ្លួនបានប្រព្រឹត្តកំហុសនោះទេ ។ អ្នកទោសត្រូវទទួលរងនូវអំពើអមនុស្សធម៌យ៉ាងទាន់ហន់និងដាច់ខាតដូចដែល លន់ ណុល ចាត់ទុកអ្នកប្រឆាំងនឹងខ្លួនជា«ទមិឡ» ។ សភាជាន់ទាបសហរដ្ឋអាមេរិកចាត់ទុកជនកុម្មុយនិស្តកម្ពុជា «មិនមែនជាអាមេរិកាំង»និងដូចដែល ប៉ុល ពត និងបក្សពួកខ្លួន ចាត់ទុកខ្មាំងផ្ទៃក្នុងថាជាជនបរទេសនិងមិនស្អាតស្អំអ៊ីចឹងដែរ ។ ខ្មាំងផ្ទៃក្នុងអាចនាំឲ្យមានគ្រោះថ្នាក់ធំណាស់ ។ នៅក្នុង«គម្រោងចុងក្រោយ» ឌុច បានធ្វើការប្រៀបធៀបយុទ្ធសាស្ត្ររបស់ខ្មាំងផ្ទៃក្នុងទាំងនោះទៅនឹង«សត្វខ្មូតនៅក្នុងឈើឬប្រេងដែលជ្រាប និងប្រៀបធៀបទៅនឹងជំងឺវប្ចមេរោគដែលកើតចេញមកពីសេ.អ៊ី.អា វៀតណាម និងអ្នកដទៃទៀតក្នុងការវាយប្រហារប្រជាជនបដិវត្តន៍ក្លាហាន» ។

នៅពេលដែលមនុស្សម្នាក់មានជំងឺ អ្នកនោះច្បាស់ជាចម្លងជំងឺទៅអ្នកដទៃទៀតមិនខាន ។ បើមិនក្តិចបណ្តូលវាទេ នោះការប្រឆាំងបដិវត្តន៍នឹងរាលដាលកាន់តែខ្លាំងឡើងៗមិនខាន ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៦ ប៉ុល ពត បាននិយាយសង្កត់ធ្ងន់



ទីតាំងមិនច្បាស់(សូមជួយផ្តល់ព័ត៌មាន)

ទៅលើកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាដោយលើកពីមនោគមវិជ្ជាដែលទាក់ទងនឹងបច្ចេកទេសពេទ្យបន្តិចបន្តួចថា «យើងមិនអាចមើលឃើញវាច្បាស់ទេ ។ មានជំងឺត្រូវតែពិនិត្យឲ្យបានច្បាស់ ។ ពីព្រោះកម្តៅនៃការធ្វើបដិវត្តន៍ប្រជាជន និងធ្វើបដិវត្តន៍ប្រជាធិបតេយ្យវាមិនស្មើនឹងការតស៊ូរបស់ប្រជាជន និងការតស៊ូវណ្ណៈឡើយ...យើងខំស្វែងរកមេរោគនៅក្នុងបក្ស ប៉ុន្តែមិនបានជោគជ័យ ។ នៅក្នុងបក្ស ជួរទ័ព និងក្នុងជួរប្រជាជន យើងនឹងអាចរកឃើញមេរោគចង្រៃនោះ ។ វានឹងត្រូវបានកម្ចាត់ចេញដោយសារធាតុពិតរបស់បដិវត្តន៍» ។

ដូចនៅក្នុងសម្តីផ្សេងទៀតរបស់ ប៉ុល ពត ដែរ សម្តីមួយឃ្លានេះមានលាយឡំដោយការសន្និដ្ឋាន ការមិនទុកចិត្តគ្នា និងគំនិតសង្ស័យទុកមុន ។ គំនិតនេះមិនបានកំណត់ឲ្យច្បាស់អំពី «សារជាតិពិត» របស់បដិវត្តន៍ មិនបានពន្យល់អំពីទំហំនៃជំងឺប៉ុនណា ឬសំខាន់បំផុតមិនបានបង្ហាញឲ្យឃើញថាបក្សពិតជាមានកម្លាំងក្បត់សម្ងាត់បង្កប់មែន ។ ប៉ុន្តែសម្តីនេះនិយាយយោងមិនច្បាស់និងពិបាកយល់ដល់ការ«ឃ្លាំមើលនៅអំឡុងពេល១០ឆ្នាំចុងក្រោយ» ។

## ការធ្វើវិសុទ្ធកម្មក្នុងឆ្នាំ១៩៧៥

វិសុទ្ធកម្ម(ការបោសសម្អាត) ធ្វើឡើងដោយមជ្ឈិមបក្ស និងអនុវត្តនៅមន្ទីរសន្តិសុខ ស-២១ អាចចែកចេញជាពីរជំហានធំៗ ។ ជំហានទីមួយគឺចាប់ធ្វើឡើងពីខែកញ្ញា ឆ្នាំ១៩៧៥ដល់ខែកញ្ញា ឆ្នាំ១៩៧៦ ។ ហើយជំហានទី២ គឺបន្តរហូតទៅដល់ថ្ងៃដួលរំលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មនុស្សដែលជាមុខសញ្ញាក្នុងការធ្វើវិសុទ្ធកម្មលើកទី១ គឺប្រជាជនស៊ីវិលនិងទាហានមានសក្តិធំៗរបស់របប លន់ ណុល ។ ជាលទ្ធផល ប្រជាជនរាប់ពាន់លាននាក់ត្រូវបានប្រមូលយកទៅសម្លាប់ចោល ។ ផ្ទុយទៅវិញនៅក្នុងប្រទេសវៀតណាម ប្រជាជនជំពូកនេះត្រូវបានបញ្ជូនទៅកន្លែងអប់រំកសាងខ្លួនដែលនៅទីនោះមានប្រជាជនជាច្រើនត្រូវស្លាប់និងរាប់ម៉ឺននាក់បានលេចមុខមកសាជាថ្មី។ អំពើមនុស្សឃាតក្នុងឆ្នាំ១៩៧៥ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដូចជាការអប់រំកសាងខ្លួននៅប្រទេសវៀតណាមដែរ គឺធ្វើឡើងតាមបញ្ជាពីថ្នាក់លើបំផុត ។ តាមចម្លើយសារភាពរបស់ ជៅ ចាន់ ឆ្នាំ១៩៧៧ បានឲ្យដឹងថា «ក្រោយពីប្រទេសទាំងមូលត្រូវបាន



ទីតាំងមិនច្បាស់(សូមជួយផ្តល់ព័ត៌មាន)

ថ្ងៃរំដោះ អង្គការបានចេញអនុវត្តការកម្ទេចមន្ត្រីជាបន្តបន្ទាប់ចាប់ពីឧត្តមសេនីយ៍ចុះមកដល់វរសេនីយ៍ទោព្រមទាំងភ្នាក់ងារសន្តិសុខ ប៉ូលិស តម្រួតយោធានិងរដ្ឋការប្រតិកិរិយា» ។

ការសម្លាប់មនុស្សនេះបានធ្វើឲ្យសង្គ្រាមស៊ីវិលរីកកាន់តែធំនិងបង្ហាញពីអំពើឃោរឃៅទៀតផង ។ គំរូប្រវត្តិសាស្ត្រនៃសង្គ្រាមស៊ីវិលអាចរកបាននៅសហភាពសូវៀតក្រោយឆ្នាំ១៩១៧ នៅប្រទេសចិនក្នុងអំឡុងឆ្នាំ១៩៤៩-៥០និងនៅប្រទេសវៀតណាមនៅក្នុងឆ្នាំ១៩៥៤ ។ ទាំងនេះគឺជាការចង្អុលបញ្ជាក់តាមយោបល់របស់លោក ណម ឆមស្គី និង អេដវ៉ាដ ហ៍រមែន ។ នៅក្នុងប្រទេសបារាំងក៏ដូចជាប្រទេសកម្ពុជាដែរគឺថា កំហឹងរបស់ប្រជាជន អំណាចកំហឹងរបស់ជនរងគ្រោះព្រមទាំងខ្វះការធានាអំពើយុត្តិធម៌បានរួមផ្សំគ្នាបង្កើតជាអំពើមួយដែលលើសពីដែនសមត្ថកិច្ចរបស់តុលាការរួមទាំងការសម្លាប់ពេញទឹកពេញដីទៀតផង ។ ***(នៅមានត)***

## សេចក្តីកែតម្រូវ

នៅក្នុងទស្សនាវដ្តីស្វែងរកការពិតលេខ១០ ផ្នែកសំបុត្រ «ត្រីងៀតឆ្អៀតពង» ដែលបានសរសេរពាក្យ«ព្រះមហាក្សត្យ» សូមកែមក«ព្រះមហាក្សត្រ»វិញ ។ ***សូមអរគុណ***

# ការបំផ្លាញមូលដ្ឋានគ្រួសារក្នុងសង្គមខ្មែរ

នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ គោលបំណងមេដឹកនាំខ្មែរក្រហមគឺសម្រេចឲ្យបាននូវបដិវត្តន៍កុម្មុយនិស្ត "បរិសុទ្ធ" មួយដែលបានរៀបចំផែនការបង្កើនផលិតផលកសិកម្ម ហើយកែប្រែសណ្តាប់ធ្នាប់កម្ពុជាឲ្យផុយស្រឡះពីល័ក្ខខ័ណ្ឌនៃមនុស្ស ។ ដើម្បីសម្រេចផែនការនេះខ្មែរក្រហមត្រូវការចាំបាច់នូវភាព"លះបង់ដាច់ខាត"ពីប្រជាជន ។ មុនពេលដែលរបបខ្មែរក្រហមអនុវត្តនូវផែនការបដិវត្តន៍"បរិសុទ្ធ" អត្តសញ្ញាណរបស់ប្រជាជនកម្ពុជាផ្សារភ្ជាប់យ៉ាងរឹងមាំទៅនឹង "គ្រួសារ" ។ ភាពផ្សារភ្ជាប់នេះគឺផ្ទុយពីតម្រូវការរបស់ខ្មែរក្រហមដែលត្រូវជំនួសដោយភក្តីភាពថ្មីមួយចំពោះអង្គការដែលពុំមែនជាមនុស្សឬជាវិញ្ញាណ ។

ខ្មែរក្រហមបានប្រើប្រាស់វិធីបីយ៉ាងដើម្បីបំបែកសមាជិកគ្រួសារនិងដើម្បីបំផ្លាញរចនាសម្ព័ន្ធគ្រួសារឲ្យទៅជាចំណែកតូចៗតាមរយៈ១)ការជម្លៀស ២)ការប្រហារជីវិត ៣)ការធ្វើការនិងរស់នៅតាមបែបសមូហភាព ។

## ការជម្លៀស

គ្រួសារនៅទីក្រុងស្ទើរតែទាំងអស់ត្រូវបានបំបែកនៅក្នុងការជម្លៀសយ៉ាងអមនុស្សធម៌នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ក្នុងចំណោមប្រជាជនដែលបានសម្ភាស៩៣ភាគរយបានបញ្ជាក់ថាគ្រួសាររបស់ខ្លួនត្រូវបានជម្លៀសពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងនោះ៣៣ភាគរយបានបែកខ្ញែកពីគ្រួសារដោយសារការជម្លៀស ។ មិនតែប៉ុណ្ណោះសោត សមាជិកគ្រួសារមួយចំនួនត្រូវស្លាប់ដោយកង្វះស្បៀងអាហារនិងជំងឺ ។ ដូចក្នុងករណីរបស់ណារ៉ុម ដែលត្រូវបានជម្លៀសជាមួយគ្រួសារចេញពីភ្នំពេញបានបាត់បង់ឪពុករបស់គាត់ តាមរយៈការរៀបរាប់ដូចតទៅៈ "នៅពេលដែលគ្រួសារខ្ញុំត្រូវបានជម្លៀសចេញពីភ្នំពេញ ខ្ញុំបានបែកចេញពីឪពុកម្តាយរបស់ខ្ញុំ ។ គ្រួសារខ្ញុំរស់នៅជិតនឹងរបប លន់ ណុល ហើយមានការភ័យខ្លាចថាមានការទម្លាក់គ្រាប់បែកមកលើផ្ទះរបស់ខ្ញុំដូច្នេះឪពុកម្តាយរបស់ខ្ញុំយកពួកខ្ញុំទៅនៅជាមួយម្តាយមីងខ្ញុំ ។ នៅពេលដែល ប៉ុល ពត ចូលមក បងប្អូនខ្ញុំបែកគ្នា ហើយត្រូវបានជម្លៀសទៅខេត្តកំពង់ធំដែលជាស្រុកកំណើតរបស់ឪពុកខ្ញុំ ។ ខ្ញុំបានប្រាប់ឪពុកម្តាយរបស់ខ្ញុំឲ្យទៅ ខ្ញុំនៅទីនោះ ។ ឪពុកម្តាយខ្ញុំក៏ទៅតាមពួកខ្ញុំ ហើយនៅពាក់កណ្តាលផ្លូវទៅទីនោះ ខ្មែរក្រហមបានយកឪពុកខ្ញុំទៅសម្លាប់ពីព្រោះខ្មែរក្រហមដឹងថាគាត់ធ្វើការងារអ្វីនៅក្នុងរបបមុន ។ យោធាខ្មែរក្រហមដឹងថាឪពុកខ្ញុំគឺជានាយទុន ។ ចាប់តាំងពីពេលនោះមក ខ្ញុំព្រាត់ឪពុកខ្ញុំរហូត ខ្ញុំពុំដែលបានជួបគាត់ម្តងទៀតឡើយ" ។ ដំណើរការជម្លៀសនៅក្នុងស្ថានការណ៍ពោរពេញទៅដោយភាពចលាចលនិងវឹកវរនេះបានបណ្តាលឲ្យបាត់បង់នូវប្រព័ន្ធទ្រទ្រង់ដែលមានសារៈសំខាន់ដល់ការរស់នៅរបស់គ្រួសារទាំងឡាយ ។

## ការសម្លាប់រង្គាល

ភាគច្រើននៃប្រជាជនដែលត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហមគឺដោយសារការសម្លាប់រង្គាលឬបង្អត់អាហារ ។ ក្នុងចំណោមបទសម្ភាសន៍ទាំងអស់ ៤៨ភាគរយឆ្លើយថា សមាជិកម្នាក់ឬលើសពីនេះនៃសមាជិកគ្រួសារត្រូវបានសម្លាប់ ហើយ២៤ភាគរយទៀតបញ្ជាក់ថា ការស្លាប់របស់សមាជិកគ្រួសារគឺដោយសារការបង្អត់អាហារនិងបរិភោគអាហារមិនគ្រប់គ្រាន់ ។ ករណីរបស់បងស្រី រតនា ដែលបានបាត់បង់ឪពុកនិងបងប្អូនប្រុសបានរៀបរាប់ថា "កាលនៅស្វាយរៀង ពួកខ្មែរក្រហមយកឪពុកខ្ញុំបន្ទាប់មក២ខែ ខ្មែរក្រហមបានយកបងប្អូនប្រុសរបស់ខ្ញុំទៅសម្លាប់ ។ បងប្អូនប្រុសរបស់ខ្ញុំម្នាក់បានត្រឡប់មកពី "គុក" វិញ ដើម្បីមកមើលម្តាយរបស់ខ្ញុំនៅប្រហែលម៉ោង១២អាធ្រាត ។ ម្តាយរបស់ខ្ញុំក៏បានដាំបាយឲ្យគាត់ហូប ហើយគាត់ក៏បានប្រាប់ម្តាយខ្ញុំថាតើគាត់ជួបការលំបាកដូចម្តេចខ្លះ ។ គាត់ត្រូវធ្វើការយ៉ាងលំបាកខ្លាំងណាស់ ។ នៅម៉ោងប្រហែល៣ព្រឹក គាត់បានត្រឡប់ទៅវិញ ហើយពួកខ្មែរក្រហមយកគាត់ទៅវាយដំធ្វើបាប ។ ពួកខ្មែរក្រហមបានចោទប្រកាន់គាត់ថាបានលួចទៅជួបម្តាយ ។ ម្តាយខ្ញុំបានដឹងថាបងប្រុសខ្ញុំបានឃ្លាតទៅឆ្ងាយយូរណាស់មកហើយ អ៊ីចឹងគាត់ក៏ស្ងោរដំឡូងសម្រាប់បងប្រុសខ្ញុំ ហើយដាក់ក្នុងកំប៉ុងមួយ ។ ខ្ញុំបានទៅជាមួយប្អូនស្រីតូចរបស់ខ្ញុំ ហើយឲ្យប្អូនស្រីខ្ញុំយកកំប៉ុងដំឡូងនេះទៅឲ្យបងប្រុសរបស់ខ្ញុំ ។ ប៉ុន្តែពួកខ្មែរក្រហមពុំអនុញ្ញាតឲ្យប្អូនស្រីខ្ញុំជួបគាត់ទេ

ពីព្រោះឆ្មាំគុកខ្មែរក្រហមបានវាយដំបងប្រុសខ្ញុំឲ្យរបួសយ៉ាងធ្ងន់ ។ ពួកខ្មែរក្រហមក៏បានយកកំប៉ុងដំឡូងនោះ ហើយបរិភោគដំឡូងនោះអស់ទៅ ។ ២ថ្ងៃក្រោយមក ពួកខ្មែរក្រហមក៏យកគាត់ទៅសម្លាប់ចោល ។ បងប្រុសរបស់ខ្ញុំស្លាប់មុនឪពុករបស់ខ្ញុំ ។ ឪពុករបស់ខ្ញុំស្លាប់ដោយសារតែជំងឺនិងខ្វះម្ហូបអាហារ ។ ពួកខ្មែរក្រហមពុំដែលឲ្យម្ហូបអាហារគាត់ទទួលទានទេ ។ ពួកខ្មែរក្រហមបានដឹងថាបងប្រុសរបស់ខ្ញុំមានមុខតំណែងខ្ពស់ពីមុន» ។

## ការងារនិងការរស់នៅជាសមូហភាព

បន្ថែមពីលើការបំបែកសមាជិកគ្រួសារដោយការជម្លៀសនិងការសម្លាប់ ខ្មែរក្រហមបានប្រើប្រាស់វិធីបំបែកគ្រួសារតាមរយៈការងារនិងការរស់នៅដោយសមូហភាព ។ នេះគឺជាវិធានការទីបីដែលខ្មែរក្រហមប្រើប្រាស់ឡើងដើម្បីកាត់ផ្តាច់ទំនាក់ទំនងមនោសញ្ចេតនាក្នុងគ្រួសាររវាងឪពុក ម្តាយ កូន ប្តី ប្រពន្ធ ។ល ។



គ្រួសារទាំងឡាយត្រូវបានបែងចែកជាបីប្រភេទទៅតាមប្រភេទការងារដោយកំណត់ទៅតាមភេទនិងអាយុ ។ ក្រុមទីមួយគឺជាក្រុមមនុស្សចាស់ដែលមានអាយុចាប់ពី៥០ឆ្នាំឡើងទៅនិងត្រូវបានបែងចែកជាពីរក្រុមរវាងបុរសនិងស្ត្រី ។ ក្រុមទីពីរ គឺជាក្រុមកងចល័តដែលរួមមានបុរសនិងស្ត្រីមានអាយុចាប់ពី១៨ទៅ៥០ឆ្នាំ ។ បុរសនៅក្នុងកងបុរស រីឯស្ត្រីនៅក្នុងកងស្ត្រី ។ ក្រុមការងារទីបី គឺជាក្រុមការងារដែលមានវ័យក្មេងបំផុតហៅថាកងកុមារដែលមានអាយុ១៣ឆ្នាំនិងក្រោម១៣ឆ្នាំ ។ ក្មេងប្រុសនៅក្នុងកងកុមារា ក្មេងស្រីនៅក្នុងកងកុមារី ។ បងស្រីជ័យ ដែលបានក្លាយទៅជាស្ត្រីមេម៉ាយនិងព្រាត់ប្រាសកូននៅក្នុងរបបខ្មែរក្រហមបានរៀបរាប់ថា «កូនរបស់ខ្ញុំបានស្លាប់បាត់ទៅហើយ ។ ពួកវាបានទៅកងផ្សេងៗ ។ កូនធ្វើការនៅកន្លែងមួយ ម្តាយធ្វើការនៅកន្លែងមួយផ្សេងទៀត ។ យើងទាំងអស់គ្នាបានបែកចេញពីគ្នា ។ យើងស្ទើរតែពុំអាចជួបគ្នា...មួយស្របក់ក្រោយមកកូនរបស់ខ្ញុំបានមកលេងខ្ញុំ ។ កូនស្រីរបស់ខ្ញុំបានជួបជុំ ហើយខ្ញុំបានសួរកូនស្រីខ្ញុំថាតើគេបានការអនុញ្ញាតដែរឬអត់មុននឹងមកនេះ ។ កូនស្រីខ្ញុំឆ្លើយថា «ទេ ម៉ាក់ ខ្ញុំអត់មានទេ» ។ ខ្ញុំបានប្រាប់កូនស្រីខ្ញុំឲ្យត្រឡប់ទៅវិញ ។ នៅពេលដែលខ្ញុំនិយាយអ៊ីចឹងស្រាប់តែកម្មាភិបាលខ្មែរក្រហមម្នាក់បានមកដល់ហើយចាប់ផ្តើមស្រែកជេទាលដាក់ ហើយនិយាយថា «មើលវាដើរហើរសេរី» ។ កូនស្រីរបស់ខ្ញុំប្រាប់ខ្ញុំថាវាគ្រាន់តែចង់មកកោសខ្យល់ឲ្យតែប៉ុណ្ណោះ កោសខ្យល់ហើយខ្ញុំនិងត្រឡប់ទៅវិញ ។ នៅពេលដែលកូនស្រីខ្ញុំត្រឡប់ទៅវិញ ពួកខ្មែរក្រហមឲ្យកូនស្រីខ្ញុំកាប់ដីកាន់តែច្រើនឡើងថែមទៀត ។ ហើយប្រសិនបើកូនស្រីខ្ញុំពុំអាចបញ្ចប់ការងារ ពួកខ្មែរក្រហមនឹងបង្អត់អាហារកូនខ្ញុំ» ។ ក្រៅពីការបំផ្លាញរចនាសម្ព័ន្ធគ្រួសារតាមវិធីខាងលើខ្មែរក្រហមបានបន្តប្រើប្រាស់មធ្យោបាយផ្សេងៗទៀតដូចជាការវាយប្រហារលើទ្រព្យសម្បត្តិផ្ទាល់ខ្លួននិងស្ថាប័នគ្រួសារជារៀងរាល់ថ្ងៃ ការហូបបាយជាសមូហភាព ការបង្ខំឲ្យរៀបការ ការបំបិទសាសនាក្នុងគោលបំណងលុបបំបាត់ចំណងនៅក្នុងគ្រួសារនិងចំណងប្រពៃណី ហើយឲ្យប្រជាជនស្មោះស្ម័គ្រចំពោះអង្គការតែម្យ៉ាងប៉ុណ្ណោះ ។ ប៉ុន្តែផ្ទុយទៅនឹងសេចក្តីប៉ងប្រាថ្នានូវគោលនយោបាយរបស់ខ្មែរក្រហម ដំណាក់កាលដ៏លំបាកនេះបានធ្វើឲ្យចំណងមនោសញ្ចេតនានៅក្នុងគ្រួសារកាន់តែមានភាពស្អិតរមួតនិងជ្រាលជ្រៅថែមទៀត ។ ជាការពិត គោលនយោបាយដែលខ្មែរក្រហមបានបង្កើតឡើងដើម្បីទាមទារនូវភាព«លះបង់ដាច់ខាត»របស់ប្រជាជនចំពោះអង្គការតាមរយៈការគំរាមកំហែង ចាប់បង្ខំសម្លាប់ ពុំអាចធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យសម្រេចនូវក្តីប្រាថ្នាទាំងនោះឡើយ ។ តាមមធ្យោបាយស្ងៀមស្ងាត់និងសម្ងាត់ សមាជិកនៃក្រុមគ្រួសារទាំងឡាយបានប្រឈមមុខតទល់នឹងគោលនយោបាយរបស់ខ្មែរក្រហម ហើយបានបង្ហាញពីការតាំងចិត្តដាច់ខាតស្មោះស្ម័គ្រចំពោះគ្រួសារទោះបីជាដឹងថាខ្លួនកំពុងប្រឈមមុខនឹងគ្រោះថ្នាក់ដល់អាយុជីវិតក៏ដោយ ។

**ឈ ស៊ីវ ឡេង**

# ច្បាប់យុត្តិសាស្ត្រ

តុលាការយុត្តិធម៌អន្តរជាតិពុំបានចេញសាលក្រមលើករណីបទល្មើសនៃការធ្វើទារុណកម្មឬការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅ អមនុស្សធម៌ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្សឡើយមកដល់ពេលបច្ចុប្បន្ននេះ ។ គណៈកម្មាធិការសិទ្ធិមនុស្សបានបង្កើតឡើងក្រោមកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឆ្នាំ១៩៦៦បានទទួលការចោទប្រកាន់មកលើបុគ្គលជាច្រើនអំពីការរំលោភបំពានមាត្រា៧ដែលហាមឃាត់ការធ្វើទារុណកម្មនិងការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវ ឃោរឃៅ អមនុស្សធម៌ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ។ ប៉ុន្តែសេចក្តីសម្រេចរបស់គណៈកម្មាធិការនេះតែងតែមិនបានញែកឲ្យដាច់រវាងឧក្រិដ្ឋកម្មទាំងពីរនេះ ដោយយោងទៅតាមទស្សនៈរបស់ខ្លួនដែលថាវាពុំមានសារៈសំខាន់“ក្នុងការញែកឲ្យដាច់ស្រឡះពីគ្នារវាងការដាក់ទណ្ឌកម្មឬការប្រព្រឹត្តគ្រប់ទ្រង់ទ្រាយដែលបានហាមប្រាមនោះឡើយ” ។


សម្ភារសួរចម្លើយនៅមន្ទីរ ស-២១

លើសពីនេះ គណៈកម្មាធិការនេះបានពិចារណាទៅលើការចោទប្រកាន់នានាអំពីការធ្វើទារុណកម្មនិងការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅ អមនុស្សធម៌ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ស្របតាមមាត្រា១០“១”ដែលតម្រូវឲ្យមានការប្រព្រឹត្តមកលើអ្នកទោសក្នុងលក្ខណៈ

ជាមនុស្សនិងដោយគោរពភាពថ្លៃថ្នូរជាមនុស្សដែលមានពីកំណើតរបស់អ្នកទោសនោះ ។

គណៈកម្មាធិការនេះបានឃើញយ៉ាងច្បាស់នូវចំណុចដូចគ្នាមួយចំនួនរវាងមាត្រា៧និងមាត្រា១០«១»ត្រង់ចំណុចនៃការប្រព្រឹត្តអមនុស្សធម៌ដែលគណៈកម្មាធិការនេះរកឃើញថាភាគីរដ្ឋមួយមិនបានប្រព្រឹត្តមកលើអ្នកទោស «ក្នុងលក្ខណៈជាមនុស្សធម៌និងដោយមិនគោរពភាពថ្លៃថ្នូរជាមនុស្សដែលមានពីកំណើតរបស់អ្នកទោសនោះ» ។

ជួនកាលគណៈកម្មាធិការចាត់ទុកអំពើបែបនេះជាការរំលោភបំពានលើមាត្រា៧និងមាត្រា១០«១»ប៉ុណ្ណោះ ។ មិនតែប៉ុណ្ណោះវាជាការសំខាន់ណាស់ដែលត្រូវធ្វើការកត់សម្គាល់ថាតាមធម្មតាគណៈកម្មាធិការនេះមិនចាត់ទុកអំពើធម្មតារបស់បុគ្គលទាំងឡាយជាការប្រព្រឹត្តផ្សេងៗទៀតដែលមានលក្ខណៈសាហាវឃោរឃៅ អមនុស្សធម៌ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្សទេ ។ ប៉ុន្តែយកការប្រមែប្រមូលលក្ខខណ្ឌទាំងអស់នៃការប្រព្រឹត្តនោះមកធ្វើជាមូលដ្ឋាននៃការចេញសាលក្រមឬការចេញសេចក្តីសម្រេច ។

### ១) រឿងក្តីរវាង អាល់ប៊ឺតូ គ្រីលម៉ូតា ទល់នឹងអ៊ុយរូហ្គាយ

អ្នកប្តឹងម្នាក់ជនជាតិអ៊ុយរូហ្គាយ បានអះអាងនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ថា រូបលោកត្រូវបានឃាត់ខ្លួននៅក្នុងក្រុងម៉ុងតេវីដេអូ នៅផ្ទះមិត្តរបស់លោក ។ លោកត្រូវបាននាំយកទៅនាយកដ្ឋានទី៥នៃការិយាល័យទទួលបន្ទុកសារព័ត៌មាននិងការស៊ើបការណ៍ ។ នៅទីនោះ រូបលោកត្រូវបានសួរចម្លើយនិងជំរុញឲ្យសារភាពថា លោកកាន់តំណែងនៅក្នុងគណបក្សកុម្មុយនិស្ត ហើយឲ្យបង្ហាញនូវអ្នកជាប់ឃុំដទៃទៀតដែលជាសមាជិកក្រុមយុវជនកុម្មុយនិស្ត ។ ប្រហែលជា៥០ថ្ងៃបន្ទាប់ពីការឃុំខ្លួនលោក អាល់ប៊ឺតូ រូបលោកបានអះអាងថា លោកនិងអ្នកជាប់ឃុំឃាំងដទៃទៀតជាមួយលោកត្រូវបានធ្វើទារុណកម្មយ៉ាងឃោរឃៅ ។ សកម្មភាពធ្វើទារុណកម្មទាំងនោះរួមមាន ការប្រើខ្សែភ្លើងឆក់ ការចាប់ជ្រមុជក្បាលទៅក្នុងទឹកស្អុយ ការដាក់បញ្ចូលដបឬកាណុងកាំភ្លើងវែងស្វ័យប្រវត្តិទៅក្នុងទ្វារធំរបស់លោក បង្ខំឲ្យលោកនៅឈរត្រង់ គ្របក្បាលនិងដាក់ខ្នោះ ហើយនិងញាត់ឈើមួយដុំទៅក្នុងមាត់របស់លោកអស់រយៈពេលជាច្រើនយប់ថ្ងៃ ។

ការអះអាងតវ៉ាដទៃទៀតពាក់ព័ន្ធនឹងកង្វះខាតរបស់អ្នកប្តឹងក្នុងការស្វែងរកមេធាវី ។ អ្នកប្តឹងត្រូវបានកាត់ទោសដោយតុលាការយោធានៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៦ ។ លោក អាល់ប៊ឺតូ និងអ្នកជាប់ឃុំឃាំងជាមួយលោក ៣នាក់ទៀតបានរត់គេចខ្លួនទៅស្ថានទូតវេណេហ្ស៊ុយអេឡា ដែលនៅទីនោះអ្នកទាំង៤ត្រូវបានផ្តល់នូវសិទ្ធិជ្រកកោន ។ ការឆ្លើយតបរបស់ប្រទេសអ៊ុយរូហ្គាយ បដិសេធជាទូទៅនូវការចោទប្រកាន់ក្នុងប្រទេសដែលលោកអាចមានលទ្ធភាពទទួលយកបានក្រោមប្រព័ន្ធតុលាការអ៊ុយរូហ្គាយ ។ គណៈកម្មការបានយកការបដិសេធរបស់រដ្ឋនេះមកបញ្ជាក់ថាពុំមានលក្ខណៈគ្រប់គ្រាន់ ហើយបានកត់សម្គាល់បន្ថែមទៀតថា រដ្ឋាភិបាលអ៊ុយរូហ្គាយ មិនបានបង្ហាញឲ្យឃើញថាការចោទប្រកាន់ទាំងនេះត្រូវបានធ្វើការស៊ើបអង្កេតដោយត្រឹមត្រូវឡើយ ។

គណៈកម្មាធិការបានរកឃើញថារឿងរ៉ាវឃាត់ខ្លួននិងការកាត់ទោសលោក អាល់ប៊ឺតូ គឺមានការពិតទាំងស្រុងហើយថា ការធ្វើទារុណកម្មនិងការមិនបានយកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវល្អដែលរងដោយអ្នកប្តឹង គឺជាការរំលោភនូវមាត្រា៧និងមាត្រា១០«១»នៃអនុសញ្ញា ដោយហេតុថាអំពើទាំងនេះបានកើតបន្តបន្ទាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ដែលជាការបរិច្ឆេទមួយដែលអនុសញ្ញានិងពិធីការជ្រើសរើសបានចូលជាធរមានសម្រាប់ប្រទេសអ៊ុយរូហ្គាយ ។

### ២) អ៊ីស្មើរ សូរីយ៉ាណូ ដឺប៊ូវិគុន ប្រឆាំងតវ៉ានឹងអ៊ុយរូហ្គាយ (ឆ្នាំ១៩៨១)

អ្នកប្តឹងត្រូវបានឃាត់ខ្លួនដោយគ្មានដីកានៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។ នាងត្រូវបានឃុំឃាំងដោយគ្មានអន្តរាគមន៍អស់រយៈពេល៨ខែមុនពេលដែលនាងត្រូវបានកាត់ទោសដោយតុលាការយោធា ហើយរកឃើញថានាងគ្មានទោសពៃរ៍អ្វីទេ ។ អ្នកប្តឹងបានចោទប្រកាន់ថារូបនាងបានទទួលការរងទុក្ខទោសពីការមិនយកចិត្តទុកដាក់ឲ្យល្អត្រឹមត្រូវពេលដែលនាងជាប់ឃុំឃាំងរួមមានសកម្មភាពដូចខាងក្រោមនេះ÷

◆នាងត្រូវបានបង្ខំឲ្យឈរអស់រយៈពេល៣៥ម៉ោង ដោយអនុញ្ញាតឲ្យឈប់តិចតួចបំផុត ។

◆កដៃរបស់នាងត្រូវបានចងផ្ដោបគ្នាដោយខ្សែក្រវាត់ ត្រឹមដែលធ្វើឲ្យនាងឈឺចាប់ ហើយភ្នែកទាំងគូរបស់នាងត្រូវបានរុំដោយបង់ដាអចិន្ត្រៃយ៍ ។

◆ទាំងយប់ទាំងថ្ងៃនាងបានស្ដាប់ឮសម្រែកឈឺចាប់របស់អ្នកជាប់ឃុំឃាំងដទៃទៀតដែលកំពុងត្រូវបានធ្វើទារុណកម្ម ។

◆ក្នុងពេលសួរចម្លើយ នាងត្រូវបានគំរាមកំហែងដោយ "មធ្យោបាយដ៏កាចសាហាវជាងការធ្វើទារុណធម្មតាទៅទៀតក្នុងគោលបំណងធ្វើឲ្យនាងនិយាយ" ។

◆នាងត្រូវបានដាក់ឲ្យអង្គុយលើកន្ទេល រុំមុខជិតនិងមិនអនុញ្ញាតឲ្យកម្រើកខ្លួនអស់រយៈពេលជាច្រើនថ្ងៃ ។

◆នាងត្រូវបានអនុញ្ញាតឲ្យងូតទឹកតែ១ដងប៉ុណ្ណោះ ក្នុងរវាង១០ទៅ១៥ថ្ងៃ ។

ភាគីរដ្ឋាភិបាលបានបដិសេធនូវការចោទប្រកាន់ទាំងអស់នេះក្នុងលក្ខណៈទូទៅ ក៏ប៉ុន្តែរដ្ឋាភិបាលមិនបានផ្ដល់ភស្តុតាងថាការចោទប្រកាន់នេះត្រូវបានធ្វើការស៊ើបអង្កេតឡើយ ។ ស្របពេលជាមួយគ្នានេះដែរ គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញថារដ្ឋាភិបាលអ៊ុយរូហ្គាយ បានរំលោភដល់មាត្រា៧និងមាត្រា១០"១"នៃអនុសញ្ញាជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដោយសារការប្រព្រឹត្តឧក្រិដ្ឋកម្មដោយអំពើអមនុស្សធម៌និងឃោរឃៅចំពោះអ្នកប្ដឹង ។ ជាមួយគ្នានេះដែរ គណៈកម្មាធិការបានបញ្ចេញនូវទស្សនៈរបស់ខ្លួនថារដ្ឋាភិបាលអ៊ុយរូហ្គាយ ស្ថិតនៅក្រោមកាតព្វកិច្ចផ្ដល់ដល់អ្នកប្ដឹងនូវគ្រឿងសំណងដ៏មានប្រសិទ្ធភាព រួមមានការសងជំងឺចិត្តចំពោះការរំលោភដែលនាងរងទុក្ខទោសបន្ទាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ នៅពេលដែលរដ្ឋាភិបាលអ៊ុយរូហ្គាយ បានជាប់កិច្ចសន្យាជាមួយអនុសញ្ញានេះ ។

## ៣) រឿងក្ដីរវាង ដេវ ម៉ារៀស ជីអរ ទល់នឹង ម៉ាដាហ្គាស្កា (ឆ្នាំ១៩៨៣)

អ្នកប្ដឹងជនជាតិអាហ្វ្រិកខាងត្បូងមួយរូបដែលជាអ្នកដំណើរតាមយន្តហោះមួយដែលត្រូវបានបង្ខំឲ្យចុះចតជាបន្ទាន់នៅប្រទេសម៉ាដាហ្គាស្កានៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៧ ។ អ្នកបើកយន្តហោះដែលជាអ្នកប្ដឹងនិងអ្នកដំណើរម្នាក់ទៀតត្រូវបានកាត់ទោសពីបទហោះកាត់ទឹកដីម៉ាដាហ្គាស្កា ហើយត្រូវបានកាត់ទោសដោយដាក់ពិន័យនិងជាប់ពន្ធនាគារចំនួន៥ឆ្នាំ ។ ពេលកំពុងជាប់ឃុំឃាំង អ្នកប្ដឹងរូបនេះបានលួចរត់ តែត្រូវចាប់ខ្លួនបានមកវិញ បន្ទាប់មកត្រូវបានកាត់ទោសម្ដងទៀតពីបទលួចរត់ចេញពីពន្ធនាគារ ហើយត្រូវដាក់ទោសឲ្យជាប់ឃុំឃាំងដាច់ពីគេដោយរងទុក្ខទោសគ្មានស្រាកស្រាន្ត ព្រោះគុកនេះស្ថិតនៅក្នុងបន្ទប់ក្រោមដីដែលមានទំហំ២ម៉ែត្រគុណនឹង១ម៉ែត្រ ។

គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញថា រដ្ឋាភិបាលម៉ាដាហ្គាស្កាបានរំលោភបំពានមាត្រា៧និងមាត្រា១០"១"នៃអនុសញ្ញាស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដោយសារលក្ខខណ្ឌមនុស្សធម៌ដែលអ្នកប្ដឹងបានរងទុក្ខទោស ។ គណៈកម្មាធិការបានបង្ហាញនូវទស្សនៈរបស់ខ្លួនថា ម៉ាដាហ្គាស្កាស្ថិតនៅក្រោមកាតព្វកិច្ចផ្ដល់នូវគ្រឿងសំណងដ៏មានប្រសិទ្ធភាពចំពោះការរំលោភនិងចាត់វិធានការប្រឆាំងនឹងការរំលោភបំពានប្រហាក់ប្រហែលគ្នានេះនាពេលអនាគត ។

## ៤) រឿងក្ដី អ៊ីលីនណា ប៊ីនទ្រីស វ៉ាស៊ីស្ដី ទល់នឹង អ៊ុយរូហ្គាយ (ឆ្នាំ១៩៨៣)

អ្នកប្ដឹងត្រូវបានឃាត់ខ្លួននៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧២ ពីបទចោទប្រកាន់ថាជាសមាជិកក្នុងក្រុមនយោបាយលួចលាក់មួយក្នុងការតស៊ូប្រដាប់អាវុធនោះ ។ រឿងក្ដីរបស់នាងត្រូវបានដាក់ជូនតុលាការយោធាកាលពីខែកញ្ញា ឆ្នាំ១៩៧២ ។ សាលក្រមត្រូវបានប្រកាសនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៧ ហើយអ្នកប្ដឹងត្រូវបានកាត់ទោសឲ្យជាប់គុកចំនួន២៨ឆ្នាំយ៉ាងលំបាកវេទនានិងបន្ថែមពី៥ឆ្នាំទៅ១០ឆ្នាំទៀតសម្រាប់ការឃុំឃាំងជាវិធីការពារទុកជាមុន ។ ដោយបានប្ដឹងឧទ្ធរណ៍កាលពីខែឧសភា ឆ្នាំ១៩៨០ ការកាត់ទោសរបស់នាងត្រូវបានបង្កើនរហូតដល់៣០ឆ្នាំនិងបន្ថែមពី៥ឆ្នាំទៅ១០ឆ្នាំទៀតសម្រាប់ឃុំឃាំងជាវិធីការពារទុកជាមុន ។ ខាងក្រោមនេះជាលក្ខខណ្ឌនៅក្នុងពន្ធនាគារដែលត្រូវបានចោទ

ប្រកាន់ដោយអ្នកប្តឹង÷

◆អ្នកប្តឹងត្រូវបានដាក់នៅក្នុងបន្ទប់ដែលមានអ្នកទោសចំនួន១៨នាក់ផ្សេងទៀត ។

◆ការខកខានមិនបានបំពេញការងាររបស់អ្នកទោសត្រូវបានដាក់ទណ្ឌកម្មដោយឲ្យស្ថិតនៅក្នុងគុកតែម្នាក់ឯងគត់ចំនួនដល់ទៅ៣០ឆ្នាំ និងមិនមានការសាកសួរសុខទុក្ខពីសាច់ញាតិនិងមិនឲ្យជក់បារី ។ល ។

◆ការសាកសួរសុខទុក្ខអ្នកទោសអនុញ្ញាតឲ្យមានរវាង ១៥ថ្ងៃម្តងនិងមានរយៈពេលកន្លះម៉ោង ។ មានតែសាច់ញាតិទេដែលអនុញ្ញាតឲ្យមកសួរសុខទុក្ខ ។

◆អ្នកទោសត្រូវបានដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរពីបទ



ពិភាក្សាពីស្ថានភាពក្នុងពន្ធនាគារជាមួយសាច់ញាតិនិងពីបទនិយាយជាមួយមិត្តរួមបន្ទប់ឃុំឃាំងនៅក្នុងពេលកំណត់ណាមួយនោះ ។

◆របបអាហារនៅក្នុងពន្ធនាគារគ្មានគុណភាពនិងខ្វះជាតិប្រូតេអ៊ីននិងវីតាមីន ។

◆ថ្នាំពេទ្យដែលសាច់ញាតិរបស់នាងផ្ញើទៅឲ្យនាងមិនដែលបានដល់ដៃនាងទេ ។

◆អ្នកទោសស្ទើរតែមិនត្រូវបានអនុញ្ញាតឲ្យហាត់ប្រាណឡើយ ។

◆អ្នកទោសត្រូវបានបង្ខំឲ្យផ្ងូតទឹកត្រជាក់នៅក្នុងរដូវធ្លាក់ទឹកកកដ៏សែនត្រជាក់ ។

◆បន្ទប់ឃុំឃាំងងងឹតគ្មានពន្លឺព្រះអាទិត្យ ។

រដ្ឋាភិបាលបានបដិសេធចោលនូវការចោទប្រកាន់ទាំងអស់នេះជាទូទៅ ក៏ប៉ុន្តែមិនបានពិពណ៌នាជាពិសេសអំពីអ្វីដែលតាមទស្សនៈរបស់ខ្លួន ជាគោលការណ៍ពិតប្រាកដរបស់ការងារ ហើយក៏មិនផ្តល់នូវភ័ស្តុតាងដែលថាការចោទប្រកាន់ទាំងអស់នេះត្រូវបានស៊ើបអង្កេត ។ ដោយហេតុដូច្នេះ គណៈកម្មាធិការបានរកឃើញថា រដ្ឋាភិបាលអ៊ូរូហ្គាយបានរំលោភបំពានមាត្រា៧និងមាត្រា១០“១” ដោយឈរលើមូលដ្ឋានថាអ្នកប្តឹង“មិនបានទទួលនូវការប្រព្រឹត្តក្នុងលក្ខណៈមនុស្សជាតិដោយគោរពនូវភាពថ្លៃថ្នូរជាមនុស្សដែលមានពីកំណើតនៅនៅពេលជាប់ឃុំឃាំង” ។ គណៈកម្មាធិការបានបង្ហាញនូវទស្សនៈរបស់ខ្លួនថា ភាគីរដ្ឋមានកាតព្វកិច្ចផ្តល់គ្រឿងសំណងដ៏មានប្រសិទ្ធភាពឲ្យដល់ អ៊ីលីនណា ប៊ីនទ្រីស វ៉ាស៊ីស៊្គី ហើយជាពិសេសផ្តល់ឲ្យនាងនូវការប្រព្រឹត្តដ៏សមរម្យមួយដែលបានចែងក្នុងមាត្រា១០នៃអនុសញ្ញានេះ ។ រដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់ការថែរក្សាផ្នែកវេជ្ជសាស្ត្រឲ្យត្រឹមត្រូវក្នុងការផ្សព្វផ្សាយជូនដល់នាងនូវទស្សនៈរបស់គណៈកម្មាធិការនិងនៅក្នុងការធានាថាការរំលោភបំពានប្រហាក់ប្រហែលគ្នានេះមិនបានកើតឡើងក្នុងពេលអនាគត ។

មាត្រា៣នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានចែងថា “គ្មាននរណាម្នាក់ត្រូវបានដាក់ឲ្យរងនូវការធ្វើទារុណកម្ម ការដាក់ទណ្ឌកម្មនិងការប្រព្រឹត្តដែលមានលក្ខណៈឃោរឃៅអមនុស្សធម៌ឡើយ” ។ សេចក្តីសម្រេចរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានជួយកំណត់ព្រំដែននូវការរំលោភបំពានចំនួនពីរប្រភេទ ។ **អេលីហ្សាប៊េត វ៉ាន់ស្លាក់**

## ពាក្យស្លោកខ្មែរក្រហម

**◆ឈរដាច់ខាតនិងគ្រប់កាលៈទេសៈលើជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន កាន់កាប់វាសនារបស់ខ្លួនដោយខ្លួនឯង។**

**◆កម្ទេចដាច់ខាតយួនឈ្លានពានវាតទីលេបទឹកដីឱ្យវិនាសអន្តរធានពីទឹកដីកម្ពុជាជារៀងរហូត។**

*(ដកស្រង់ចេញពីសៀវភៅលេខ ០៧៦ គណហ)*

# ដែនសមត្ថកិច្ចសកលនិងបញ្ហារួចទោសនៅកម្ពុជា

នៅក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ បក្សកុម្មុយនិស្តកម្ពុជា ដែលត្រូវបានស្គាល់ជាទូទៅថា "ខ្មែរក្រហម" បានអនុវត្តនូវមហាមនុស្សឃាតមួយដ៏អាក្រក់បំផុតក្នុងសតវត្សរ៍ទី២០នេះ ។ ប្រជាជនកម្ពុជាប្រមាណ២លាននាក់ដែលត្រូវជា១ភាគ៤នៃចំនួនប្រជាជនទាំងមូលបានបាត់បង់ជីវិតនៅក្នុងអំឡុងពេលមិនដល់៥ឆ្នាំផង ។ ជាក់ស្តែងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ដែលបានពិនិត្យទៅលើឯកសារទាក់ទងនឹងករណីខ្មែរក្រហមសុទ្ធតែបានទាញសេចក្តីសន្និដ្ឋានថាមេដឹកនាំរបស់អង្គការចាត់តាំងខ្មែរក្រហមគឺមិនអាចចៀសផុតពីការជំនុំជម្រះទោសទៅលើបទឧក្រិដ្ឋសង្គ្រាម អំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀតបានឡើយ ។

ការសិក្សាស្រាវជ្រាវទៅលើបញ្ហានៃការទទួលខុសត្រូវចំពោះមុខច្បាប់របស់ខ្មែរក្រហមត្រូវបានដំណើរការអស់រយៈពេលជាង៤ឆ្នាំហើយនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការរវាងកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍នៅសកលវិទ្យាល័យយេល សាលាពត៌មានវិទ្យា បណ្ណាល័យនិងបណ្ណសារនៃសាលកវិទ្យាល័យញូសៅវែល សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងព្រមទាំងជាមួយស្ថាប័នផ្សេងៗទៀតនៅទូទាំងពិភពលោក ។

ដោយមានជំនួយការពីបណ្តាអ្នកច្បាប់ អ្នកជំនាញការនិងអ្នកសិក្សាជាន់ខ្ពស់កម្រិតអន្តរជាតិពីបញ្ហាខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានការរីកចំរើនយ៉ាងច្រើនក្នុងការយល់ដឹងពីអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ការរកឃើញដ៏សំខាន់មួយគឺការលាតត្រដាងនូវអាថ៌កំបាំងរបស់យន្តការរបស់ខ្មែរក្រហមដែលជីវិតមនុស្សអស់ជាច្រើនលាននាក់ ។ និយាយឲ្យខ្លីគឺថាមេដឹកនាំខ្មែរក្រហមបានបង្កើតបណ្តាញប្រហារជីវិតរបស់បក្សកុម្មុយនិស្តកម្ពុជានៅទូទាំងប្រទេសប្រឆាំងនឹងខ្មាំងពិតប្រាកដនិងមនុស្សដែលខ្លួនស្រមើស្រមៃថាជាខ្មាំង ។ បណ្តាញដែលមានការរៀបចំឡើងជាខ្សែសង្វាក់បានពិឃាតមនុស្សជាមធ្យមអស់៥២០០នាក់ក្នុងមួយសប្តាហ៍ក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ។ មនុស្សប្រមាណមួយលាននាក់ផ្សេងទៀតស្លាប់ដោយការធ្វេសប្រហែសមិនអើពើពីសំណាក់អ្នកគ្រប់គ្រងដូចជាការអត់អាហារ ជំងឺនិងធ្វើការបាក់កម្លាំង ។ ឯកសារនៃមន្ទីរផ្សេងៗរបស់ខ្មែរក្រហមបានបង្ហាញយ៉ាងច្បាស់ថាមេដឹកនាំខ្មែរក្រហមទាំងអស់ជាអ្នកបានចូលរួមចំណែកក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្មជាប្រវត្តិសាស្ត្រនេះ ។

ក៏ប៉ុន្តែអស់រយៈពេលជាង២០ឆ្នាំក្រោយពីការចេញពីអំណាច មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់នៅតែបន្តទទួលបាននូវការរួចទោសចំពោះទង្វើរបស់ខ្លួននៅក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ មានហេតុផលច្រើនយ៉ាងចំពោះការរួចទោសនេះ ប៉ុន្តែកង្វះខាតកិច្ចខិតខំប្រឹងប្រែងក្នុងការនាំជនជាប់ចោទមកជម្រះទោសមិនមែនជាមូលហេតុពិតប្រាកដឡើយ ។

### ១) មានកិច្ចខិតខំប្រឹងប្រែងធ្វើឡើងដោយរដ្ឋាភិបាលកម្ពុជាក្នុងការជម្រះក្តីពីបទឧក្រិដ្ឋកម្មខ្មែរក្រហម

ដោយមានលក្ខណៈផ្ទុយគ្នាទៅនឹងគំនិតរបស់បរទេស មានកិច្ចខិតខំប្រឹងប្រែងច្រើនណាស់ធ្វើឡើងដោយរដ្ឋាភិបាលកម្ពុជាក្នុងការនាំយកជនដៃដល់ដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មមកធ្វើការស្រាយបំភ្លឺអំពីទង្វើរបស់ខ្លួននៅចំពោះមុខតុលាការ ។

នៅក្នុងឆ្នាំ១៩៧៩ របបកម្ពុជាថ្មីមួយដែលបានបណ្តេញខ្មែរក្រហមពីអំណាចបានរៀបចំបង្កើត"តុលាការប្រជាជនបដិវត្តន៍កម្ពុជា"មួយនៅទីក្រុងភ្នំពេញ ។ មេដឹកនាំខ្មែរក្រហម ប៉ុល ពត និង អៀង សារី ត្រូវបានតុលាការកាត់ឲ្យជាប់ទោសនិងកាត់ទោសប្រហារជីវិតកំបាំងមុខពីបទអំពើប្រល័យពូជសាសន៍ ។ ធាតុពិតនោះ សាលក្រមនៃតុលាការនេះមិនដែលមានប្រសិទ្ធភាពម្តងណាឡើយ ជាពិសេសការកម្រិតទោសនិងសាលក្រមចំពោះ

ករណី អៀង សារី ត្រូវបានលុបចោលនៅក្នុងឆ្នាំ១៩៩៦ ។

ក្នុងអំឡុងឆ្នាំ១៩៧៩-៨៣និងឆ្នាំ១៩៩៤-៩៧ មានកម្មាភិបាលខ្មែរក្រហមមួយចំនួនត្រូវបានចោទប្រកាន់ ហើយមួយចំនួនទៀតត្រូវបានកាត់ទោសឲ្យជាប់គុកនៅក្រោមច្បាប់ជំនុំជម្រះទោសក្នុងស្រុករបស់ប្រទេសកម្ពុជាចំពោះរាល់ការពាក់ព័ន្ធជាមួយខ្មែរក្រហមនិងឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ។ ប៉ុន្តែមកដល់សព្វថ្ងៃនេះមិនទាន់មានករណីណាមួយដែលថាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាម្នាក់ត្រូវបានជម្រះក្តីតាមនីតិវិធីនេះឡើយ ។

នៅខែមីនា ឆ្នាំ១៩៩៩ មេដឹកនាំយោធាជាន់ខ្ពស់របស់ខ្មែរក្រហមដែលមានឈ្មោះថា ឈិត ជឿន ហៅ ម៉ុក ត្រូវបានចាប់ខ្លួន ហើយឥឡូវនេះ ម៉ុក កំពុងតែរង់ចាំការជម្រះទោសនៅចំពោះមុខតុលាការសឹកកម្ពុជា ។ ប្រភពផ្សេងៗពីរដ្ឋាភិបាលបានបង្ហើបឲ្យដឹងថានៅក្នុងពេលណាមួយមេដឹកនាំខ្មែរក្រហមដទៃទៀតដែលសព្វថ្ងៃរស់នៅដោយសេរីនៅក្នុងប្រទេសកម្ពុជាដូចជា ខៀវ សំផន គណៈប្រធានរដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា ឧបនាយករដ្ឋមន្ត្រីខ្មែរក្រហម ក៏អាចនឹងត្រូវទទួលការចោទប្រកាន់ដែរ ។

ដោយសារតែសារជាតិកម្សោយនៃរចនាសម្ព័ន្ធច្បាប់ក្នុងស្រុករបស់កម្ពុជា កង្វះខាតបុគ្គលិកដែលមានការហ្វឹកហ្វឺនត្រឹមត្រូវ និងប្រព័ន្ធច្បាប់កម្ពុជាដែលមានឥទ្ធិពលនយោបាយបានធ្វើឲ្យអ្នកជំនាញការអន្តរជាតិមួយចំនួនស្ទើរតែមានការឯកភាពគ្នាទៅលើគំនិតដែលគិតថាដំណើរការជំនុំជម្រះក្តីនៅក្នុងស្រុកទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមគឺជាដំណោះស្រាយមួយដែលមានលក្ខណៈអនុគ្រោះដល់បញ្ហារួចទោសនៅកម្ពុជា ។ ចំណុចនេះនាំយើងឲ្យគិតដល់បញ្ហាជំនុំជម្រះក្តីមួយចំនួនចំពោះមេដឹកនាំផ្សេងៗនៅបរទេសតាមរយៈការលើកយកនូវច្បាប់ដែនសមត្ថកិច្ចសាកលមកធ្វើការពិភាក្សា ។

**២) ខ្ញុំនឹងលើកយកមកធ្វើការពិភាក្សាវែកញែកអំពីកិច្ចខិតខំប្រឹងប្រែងដែលត្រូវបានធ្វើឡើងចំពោះករណីលោក ពីណូចេ ព្រមទាំងដំណោះស្រាយដែលលើសដែនសមត្ថកិច្ចជាតិមួយចំនួន**

នៅពេញមួយទសវត្សរ៍ចុងក្រោយនេះ សកម្មជនផ្នែកច្បាប់នៅសហរដ្ឋអាមេរិកបានមានបំណងចង់ប្រើប្រាស់ច្បាប់របស់សហរដ្ឋអាមេរិក(ច្បាប់បណ្តឹងទាមទារការខូចខាតពីជនបរទេសនិងច្បាប់ការពារជនរងគ្រោះពីអំពើទារុណកម្ម) ។ ច្បាប់ទាំងពីរនេះអនុញ្ញាតឲ្យមានការជំនុំជម្រះទោសជនបរទេសទៅលើអំពើដែលត្រូវបានប្រព្រឹត្តឡើងនៅក្រៅទឹកដីសហរដ្ឋអាមេរិក ។ ការប្រើប្រាស់ទាំងពីរនេះគឺក្នុងគោលបំណងប្តឹងប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម ។ កិច្ចខិតខំប្រឹងប្រែងមួយដែលធ្វើឡើងកាលពីឆ្នាំ១៩៩៣គឺមានបំណងចោទប្រកាន់ផ្នែករដ្ឋប្បវេណីចំពោះការបង្កឲ្យមានឃាតកម្មដ៏អាក្រក់ប្រឆាំងនឹងគណៈប្រធានរដ្ឋរបស់ខ្មែរក្រហមឈ្មោះ ខៀវ សំផន ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនេះត្រូវទទួលបរាជ័យដោយសារអសមត្ថភាពរបស់ដើមចោទក្នុងការអនុវត្តនូវដែនសមត្ថកិច្ចទៅលើចុងចោទដែលត្រូវបានរំពឹងទុក ។

ទោះបីជារូបខ្ញុំគ្មានសិទ្ធិនិងសមត្ថភាពក្នុងការវិភាគលម្អិតជាងនេះក៏ដោយ ប៉ុន្តែខ្ញុំអាចប្រាប់មិត្តអ្នកអាននិងបងប្អូនមីងមាទាំងអស់បានថា កិច្ចខិតខំប្រឹងប្រែងថ្មីមួយឥឡូវនេះកំពុងតែត្រូវបានរិះរកដើម្បីប្រើច្បាប់នេះក្នុងការចោទប្រកាន់ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមដែលសព្វថ្ងៃនេះកំពុងតែជ្រកកោននៅសហរដ្ឋអាមេរិក ។ ខ្ញុំមានការជឿជាក់ថា ប្រទេសដទៃៗជាច្រើនទៀតសុទ្ធតែមានលក្ខន្តិកៈដូចគ្នាទៅនឹងច្បាប់ទាំងពីរដែលលើកមកបង្ហាញខាងលើ ហើយនឹងក្លាយជាជំហានដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពរួចទោសនៅក្នុងប្រទេសកម្ពុជា ប្រសិនបើប្រទេសផ្សេងៗទៀតដែលមានមធ្យោបាយផ្នែកច្បាប់សមស្របអាចបង្ហាញពីឆន្ទៈចង់ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមដែលមានវត្តមាននៅលើទឹកដីរបស់ខ្លួន ។

គំនិតផ្តួចផ្តើមស្តីពី“ដំណោះស្រាយលើសពីដែនសមត្ថកិច្ចជាតិ”មួយទៀតប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមត្រូវបានជំរុញតាមរយៈចំណាត់វិធានការមួយប្រឆាំងនឹង ពីណូចេ នៃប្រទេសឈីលី ដែលត្រូវបានធ្វើឡើងនៅចក្រភពអង់គ្លេស និងប្រទេសអេស្ប៉ាញ ។ ឆ្នាំកន្លងទៅនេះ សំណុំពាក្យបណ្តឹងត្រូវបានធ្វើឡើងដោយជនរងគ្រោះនៃរបបខ្មែរក្រហមនៅ

តុលាការនៃប្រទេសបារាំងនិងប្រទេសប៊ែលហ្ស៊ិក ។ ទោះបីជាមានសកម្មភាពច្បាប់របៀបនេះកើតមានឡើងជាលក្ខណៈទ្រង់ទ្រាយតូចៗនៅឡើយក្តី តុលាការរបស់ប្រទេសប៊ែលហ្ស៊ិកបានយល់ព្រមបើកសវនាការស្តាប់នូវបណ្តឹងប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម ។ ករណីរបៀបនេះ ការជំនុំជម្រះក្តី(លើសពីដែនសមត្ថកិច្ចជាតិ)អាចផ្តល់ក្តីសង្ឃឹមចំពោះជនរងគ្រោះនៃរបបខ្មែរក្រហមក្នុងការស្វែងរកយុត្តិធម៌ក្រោយពីរងទុក្ខវេទនាអស់ជាច្រើនឆ្នាំនិងកង្វះខាតនូវផ្នែកច្បាប់ ។

### ៣) ខ្ញុំសូមលើកយកមកពិចារណានូវមតិស្របនិងមតិប្រឆាំងមួយចំនួនលើរឿងជំនុំជម្រះក្តីខ្មែរក្រហមនៅបរទេស

នៅក្នុងខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន បានដាក់ជូនសំណើជូនសំណើផ្លូវការមួយជូនដល់អង្គការសហប្រជាជាតិសុំជំនួយក្នុងការបង្កើតតុលាការមានលក្ខណៈអន្តរជាតិមួយដើម្បីជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ដោយសារតែមានភាពរីករវើផ្នែកនយោបាយនៅក្នុងប្រទេសកម្ពុជា និងសារជាតិនៃដំណើការពិចារណារបស់អង្គការសហប្រជាជាតិពន្យារពេលដល់ខែកុម្ភៈឆ្នាំ១៩៩៩ទើបក្រុមអ្នកជំនាញការច្បាប់របស់អង្គការសហប្រជាជាតិដាក់សំណើជូនដល់អគ្គលេខាអង្គការសហប្រជាជាតិស្នើឲ្យមានការជំនុំជម្រះក្តីមួយដែលមានលក្ខណៈអន្តរជាតិចំពោះខ្មែរក្រហម ។ ក្រុមអ្នកជំនាញការបានឲ្យយោបល់សុំឲ្យមានការពង្រីកដែនសមត្ថកិច្ចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅយូហ្គោស្លាវី ដើម្បីបញ្ចូលបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។ ក៏ប៉ុន្តែនៅក្នុងគំនិតផ្ទុយគ្នាដ៏គួរឲ្យមានការភ្ញាក់ផ្អើល កម្ពុជាបានច្រានចោលនូវអនុសាសន៍របស់អង្គការសហប្រជាជាតិ ហើយបានប្រកាសថា ការជំនុំជម្រះក្តីមេដឹកនាំយោធាខ្មែរក្រហមដែលទើបតែចាប់បានឈ្មោះតា ម៉ុក អាចកើតឡើងក្រោមច្បាប់ក្នុងស្រុករបស់កម្ពុជា ។ ជាការពិត ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនៅកម្ពុជានឹងផ្តល់ផលប្រយោជន៍ជាច្រើន ។

នៅក្រោមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ភាគីរដ្ឋមានកាតព្វកិច្ចសំខាន់ក្នុងការជំនុំជម្រះក្តីទៅលើអំពើប្រល័យពូជសាសន៍ដែលកើតឡើងនៅក្នុងទឹកដីរបស់ខ្លួន ។ ចំណុចផ្សេងទៀតក៏មានលក្ខណៈដូចគ្នា ។ ដូច្នេះវានឹងក្លាយជាឧទាហរណ៍មួយនៅក្នុងករណីរបស់ប្រទេសកម្ពុជា ។ ឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ហើយជាផលវិបាក ជនរងគ្រោះនិងជនដៃដល់និងភ័ស្តុតាងទាំងអស់មិនទាន់ទៅណាឆ្ងាយនៅឡើយទេ គឺស្ថិតនៅក្នុងប្រទេសកម្ពុជា ។

ក្នុងករណីនេះប្រហែលជាមានតែប្រជាជនកម្ពុជាទេ ដែលជាទស្សនិកជនដ៏សំខាន់ចំពោះការ«សម្តែងល្ខោនសីលធម៌» ពោលគឺការបើកសវនាការកាត់ក្តីអំពើប្រល័យពូជសាសន៍ ។ ដូចដែលលោក ថមម៉ាសហាម៉ាប៊ឺក អតីតតំណាងពិសេសរបស់អគ្គលេខាអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅកម្ពុជាបានកត់សម្គាល់ដូច្នេះដែរថា មិនត្រឹមតែការសម្រេចបាននូវយុត្តិធម៌ទេ តែការដែលប្រជាជនកម្ពុជាឃើញយុត្តិធម៌ផ្ទាល់នឹងភ្នែកគឺជាជោគជ័យដ៏មានតម្លៃណាស់ ។ ទន្ទឹមគ្នានេះដែរក៏អាចមានគុណវិបត្តិធ្ងន់ធ្ងរផ្សេងទៀតក្នុងការជម្រះទោមេដឹកនាំខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ។

បញ្ហាសំខាន់ទាក់ទងនឹងការជំនុំជម្រះក្តីពីបទប្រល័យពូជសាសន៍នៅកម្ពុជា គឺសមត្ថកិច្ចរបស់ប្រព័ន្ធតុលាការក្នុងស្រុក ។ មានកិច្ចព្រមព្រៀងទូទៅមួយដែលយ៉ាងហោចណាស់ស្ថិតនៅឆ្ងាយពីរដ្ឋាភិបាលកម្ពុជា ហើយសមត្ថកិច្ចនេះមិនមាននៅក្នុងប្រទេសកម្ពុជាឡើយ ។

ចំពោះបញ្ហាផ្សេងៗទៀតគ្មានច្បាប់អនុវត្តក្នុងស្រុកឡើយក្រោយពីមានការធ្វើសច្ចាប័នលើអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍និងលើសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ។ ដូច្នេះរាល់ការជំនុំជម្រះក្តីមួយណាក៏ដោយត្រូវតែផ្អែកលើក្រឹត្យច្បាប់ឆ្នាំ១៩៧៩ចែងដោយ«រណសិរ្ស»ដែលបានផ្តួលរំលំរបបខ្មែរក្រហម ។ មានគុណសម្បត្តិជាច្រើនណាស់ចំពោះការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម ។

ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមមិនមែនជាឧក្រិដ្ឋកម្ម

ប្រឆាំងនឹងប្រជាជនកម្ពុជាទេ ។ ឧក្រិដ្ឋកម្មនេះមានលក្ខណៈធ្ងន់ធ្ងរ និងអាក្រក់គួរឲ្យស្អប់ខ្ពើមដល់កម្រិតមួយដែលត្រូវបានចាត់ចូលទៅក្នុងជំពូកឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ តុលាការមានលក្ខណៈអន្តរជាតិមួយ គឺជាដែនសមត្ថកិច្ចដ៏សមស្របមួយក្នុងការបើកសវនា ការស្តាប់នូវការចោទប្រកាន់ដ៏ធ្ងន់ធ្ងរនេះ ។

ច្បាប់នីតិវិធីនិងច្បាប់យុត្តិសាស្ត្រដែលត្រូវបានបង្កើតឡើងដោយសកម្មភាពរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា ផ្តល់ជាគំរូមួយសម្រាប់តម្លាភាពនិងភាពយុត្តិធម៌នៅក្នុងករណីខ្មែរក្រហមរបស់កម្ពុជា ។ វាគឺជាភាពត្រឹមត្រូវក្នុងការផ្អែកលើច្បាប់និងស្ថាប័នដែលមានស្រាប់ដើម្បីចោទប្រកាន់ខ្មែរក្រហមជាជាងធ្វើតាមលទ្ធភាពប្រថុយប្រថាននៅក្នុងដំណើរការគ្មានសណ្តាប់ធ្នាប់នៅក្រោមបរិយាកាសច្បាប់សព្វថ្ងៃរបស់កម្ពុជា ។

ប្រសិនបើមានការចូលរួមពីបុគ្គលដែលជាចុងចោទនិងសាក្សីដំណើរការជម្រះទោសកម្រិតអន្តរជាតិមួយនឹងអាចផ្តល់ការធានាកាន់តែកក់ក្តៅតាមនីតិវិធីត្រឹមត្រូវចំពោះជនជាប់ចោទនិងសាក្សីជាងតុលាការដែលធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែទន្ទឹមគ្នានេះដែរក៏មានផលវិបាកខ្លះចំពោះការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមជាលក្ខណៈអន្តរជាតិ ។

ទីក្រុងឡាអេ ស្ថិតនៅឆ្ងាយពីប្រទេសកម្ពុជា ។ មានគ្រោះថ្នាក់មួយដោយហេតុថាដំណើរការនីតិវិធីដែលនៅឆ្ងាយដូវការនិងមានភាពមិនចូលចំណោមបង្កើតឡើងដោយតុលាការនៅប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា មើលទៅហាក់ដូចជាមិនមានលក្ខណៈច្បាស់លាស់ចំពោះប្រជាជនកម្ពុជា ហើយថាប្រជាជនកម្ពុជាអាចមិនមើលលទ្ធផលដែលចេញពីតុលាការថាជាយុត្តិធម៌សម្រាប់ខ្លួន ។ ដោយសារតែសាក្សី ជនសង្ស័យ និងភស្តុតាងទាំងអស់មាននៅក្នុងប្រទេសកម្ពុជា ជាការច្បាស់ណាស់នឹងមានបញ្ហាផ្នែកភស្តុការនិងហិរញ្ញវត្ថុចំពោះដំណើរការជំនុំជម្រះក្តីដែលមានកម្រិតអន្តរជាតិ ។ តើអ្នកណាជាអ្នកចំណាយរាល់ថវិកាសម្រាប់ដំណើរការទាំងអស់? តុលាការដែលមានស្រាប់នៅប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា ជួបប្រទះនូវការលំបាកណាស់ក្នុងការរកប្រភពថវិកាគ្រប់គ្រាន់មកចំណាយលើតុលាការរបស់ខ្លួន ។

មានគុណសម្បត្តិនិងគុណវិបត្តិសំខាន់ៗច្រើនទៀតដើម្បីលើកមកពិចារណាក្នុងការវាយតម្លៃគុណធម៌នៃការស្វែងរកយុត្តិធម៌ជាលក្ខណៈក្នុងស្រុកនិងលក្ខណៈអន្តរជាតិចំពោះករណីខ្មែរក្រហម ។

ជាសង្ខេបមក ខ្ញុំធ្វើការសង្កេតជាមូលដ្ឋានទៅលើបញ្ហាដែនសមត្ថកិច្ចសកលចំពោះករណីខ្មែរក្រហមនៃប្រទេសកម្ពុជា ។ ក្រោយពីធ្វើឲ្យមានតុល្យភាពវាងមតិស្របនិងមតិផ្ទុយនៃការជម្រះក្តីចំពោះបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហមជាលក្ខណៈក្នុងស្រុកនិងជាលក្ខណៈអន្តរជាតិរួចមក ខ្ញុំទាញហេតុផលថាការជំនុំជម្រះក្តីជាលក្ខណៈអន្តរជាតិអាចជាដំណោះស្រាយមួយដ៏សមស្របបំផុតដែលបង្ហាញនូវចំណុចដែលមានបញ្ហាសំខាន់ដ៏តិចបំផុតនិងមានសក្តានុពលភាពយ៉ាងខ្លាំងចំពោះយុត្តិធម៌មិនលម្អៀងដែលមិនគ្រាន់តែនឹងត្រូវបានធ្វើទេ តែថែមទាំងត្រូវបានឃើញថាបានធ្វើឡើងពិតប្រាកដទៀតផង ។

លទ្ធផលសំខាន់បំផុតចេញពីតុលាការប្រល័យពូជសាសន៍សម្រាប់ប្រទេសកម្ពុជានឹងជះឥទ្ធិពលទៅលើ "វប្បធម៌នៃការរួចទោស" ។ មានមន្ត្រីរាជការស៊ីវិលជាច្រើនរូប រួមទាំងអ្នកនយោបាយ ប៉ូលិស និងទាហាន ហើយសូម្បីតែប្រជារាស្ត្រធម្មតាបានរស់នៅអស់ជាងបីទសវត្សរ៍មកហើយ នៅក្នុងបរិយាកាសមួយដែលត្រូវបានហៅថាការរួចទោស "អ្នកខ្លាំងធ្វើអ្វីដែលខ្លួនចង់ធ្វើចំណែកអ្នកខ្សោយជាអ្នកទទួលការឈឺចាប់" ហើយគ្មាននរណាម្នាក់រំពឹងថាវិធាននៃច្បាប់នឹងធ្វើអន្តរាគមន៍ក្នុងការផ្លាស់ប្តូរនូវទំនាក់ទំនងនេះឡើយ ។ ជាការច្បាស់ណាស់ ការផ្តន្ទាទោសចំពោះឧក្រិដ្ឋជនឃោរឃៅបំផុតដែលមិនដែលធ្លាប់មាននៅកម្ពុជា ពោលគឺមេដឹកនាំកម្ពុជា គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតដែលយើងអាចចាប់ផ្តើមធ្វើឲ្យសឹកនូវវប្បធម៌នៃការរួចទោសនិងមូលដ្ឋានប្រេះស្រាំនៃវប្បធម៌ដែលត្រូវបានកសាងនៅលើវិធាននៃច្បាប់ ។ បញ្ហានេះអាចត្រូវបានធ្វើឡើងដោយជោគជ័យដោយអនុវត្តដែនសមត្ថកិច្ចសកលតាមនីតិវិធីអន្តរជាតិចំពោះមេដឹកនាំខ្មែរក្រហម ។

**ឆាំង យុ**




# គំរូមួយនៃភ័ស្តុតាងឯកសារភ្ជាប់មេដឹកនាំថ្នាក់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជាដែលនៅរស់ នៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

## (ភាគ២)

***(តពីលេខមុន)***

*ម៉េត បានចូលរួមប្រជុំសេនាធិការមួយលើកទៀត កាលពីថ្ងៃ៣០ សីហា ដែលមានរបៀបវារៈផ្តោតលើ«ពិនិត្យសភាពការណ៍ខ្មាំងនិងចំណាត់វិធានការ» ។ ក្នុងការបើកអង្គប្រជុំ សុន សេន រាយការណ៍ថា កាលពី៤ថ្ងៃមុនមាន«សកម្មភាពរំដើបរំជួលខ្មាំងនៅអង្គព្រួចនៅចន្លោះព្រំប្រទល់ស្រុកកណ្តាលស្ទឹង» តំបន់២៥និងតំបន់៣៣ដែលនៅជាប់គ្នា ។ តំបន់ទាំងពីរនេះស្ថិតក្នុងភូមិភាគនិរតី ។ អ្នកដែលធ្វើការតវ៉ាទាំងនោះបាន«លើកទង់ជ័យស និងពាក្យស្លោកដាក់ថា ជយោ!ព្រះពុទ្ធសាសនា ជយោ!រណសិរ្សរំដោះខ្មែរសពីអង្គរកំប៉ុង» ។ ចលនាគាំទ្រព្រះពុទ្ធសាសនា គាំទ្រកុម្មុយនិស្តនិងប្រឆាំងនឹងរបបហូបចុកអង្គរកំប៉ុងបាន «ប្រុងដើងរួចជាស្រេចក្នុងការបង្កភាពវឹកវរ» ប៉ុន្តែចលនានេះ«ត្រូវបានចាត់ការឲ្យមានរបៀបរៀបរយរួចអស់ហើយ» ក្រោយពីក្រុមនយោបាយមូលដ្ឋានចាប់បានមនុស្សប្រមាណជា១៦០នាក់ ។ លើសពីនេះទៀត សុន សេន បានពន្យល់ថា «ចម្លើយសារភាព»របស់ពួកក្បត់បានបង្ហាញថាប្រហែលជាមាន «ទំនាក់ទំនងរវាងសភាពការណ៍នេះនឹងទាហានរបស់យើង» ព្រោះពួកវាបានឆ្លើយដាក់ឈ្មោះ ចាន់ ចក្រី ហៅ នៅ មាន អតីតលេខាគណៈកងពលមជ្ឈិម១៧០ដែលមានមូលដ្ឋាននៅជាយក្រុងភ្នំពេញថាជា«មេរបស់ពួកវា» ។ ចក្រី ត្រូវបានប្តូរមកជាលេខាកងពលធំ១៧០និងឲ្យធ្វើជាអនុប្រធានសេនាធិការនៅថ្ងៃទី១៥ ខែមីនា ហើយក្រោយមកត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ ខែឧសភា ។*

*សុន សេន និយាយតាមភ័ស្តុតាងមិនច្បាស់ថា «អង្គការ ...ដឹកនាំរបស់ខ្មាំង» ស្ថិតនៅពីក្រោយការរំដើបរំជួលនិងបញ្ហានៅក្នុងជួរទ័ពបានបង្ហាញការពិតថា ថ្មីៗនេះមានយុទ្ធជនកងពលធំ១៧០ មួយចំនួនបាន«រត់ចោលជួរ»និងរត់ទៅភូមិភាគបូព៌ា តំបន់២០ដែលនៅទីនោះពួកវាបាន«ឃោសនាថាមានការរំដើបរំជួលនៅក្នុងទីក្រុងភ្នំពេញ» ហើយថាលើសពីនេះទៀតមាន «ការឃោសនាឲ្យលួចរបស់របរ»នៅតាមអង្គភាពយោធានានា ។ សុន សេន បានឲ្យយោបល់ ម៉េត និងកម្មាភិបាលជាន់ខ្ពស់ដទៃទៀតដែលមានមុខថា គួរតែ«ពិនិត្យនិងតាមដានសមាសភាព*

មិនល្អ» នៅតាមកងពលរៀងៗខ្លួននិង«ឲ្យរៀបចំចាត់ការដាច់ដោយឡែកពីគ្នា» ពោលគឺដកពួកវាចេញពីអង្គភាពព្រមទាំងពិនិត្យរកកំហុសផ្សេងទៀត ។

នៅក្នុងកិច្ចប្រជុំនោះ ម៉េត បានរាយការណ៍ថាមានកូនទាហានម្នាក់បានរត់ចោលជួរ ហើយថ្មីៗនេះមានម្នាក់ទៀតបាន «ចងកសម្លាប់ខ្លួន» ។ បន្ទាប់មក កម្មាភិបាលដឹកនាំផ្សេងៗទៀតបាននិយាយអំពីការចាប់ខ្លួនថ្មីៗនៅក្នុងអង្គភាពរបស់ខ្លួន ។ លេខាកងពលលេខ៤៥០ឈ្មោះ ជា ណុន ហៅ សួង (ក្រោយមកត្រូវបានបោសសម្អាត) បានរាយការណ៍ថាបានចាប់ខ្លួនមនុស្សពីរនាក់ដែលជាអតីតនិរសាររត់ចូលក្នុងព្រៃជាមួយ «ខ្មែរស» ។ អនុលេខាកងពល៣១ ឈ្មោះ យឹម ឈឿន ហៅ វឿង (ក្រោយមកត្រូវបានបោសសម្អាត) បានរាយការណ៍ថាបានចាប់ខ្លួនមនុស្សពីរនាក់ដែលលួចស្បៀងនៅពហុកីឡដ្ឋានជាតិអូឡាំពិកនិងនៅមន្ទីរពេទ្យកាល់ម៉ែតក្នុងទីក្រុងភ្នំពេញ ។ ពេលសួរចម្លើយ ជនឃុំខ្លួនពីរនាក់នោះបាននិយាយថា «ខ្លួនហៀបនឹងលួចអង្ករដើម្បីធ្វើដំណើរ»ទៅភូមិកំណើតនៅតាមជនបទ ។ វឿង បានរាយការណ៍ថា«នៅក្នុងកងពល៣១០ មានអំពើចោរកម្មនិងការឃោសនាបំផុសថាធ្វើបដិវត្តន៍សង្គមនិយមគឺហូបបបរលាយវល្លិ៍ ហើយពេលដែលយើងសម្រេចបានលទ្ធិកុម្មុយនិស្តហើយ យើងនឹងហូបវល្លិ៍សុទ្ធ» ។ គណៈកងពលមជ្ឈិមលេខ៨០១រាយការណ៍ថាមានយុទ្ធជនម្នាក់នៅក្នុងអង្គភាពនេះដែលវាយឈរជើងនៅភូមិភាគឦសានបានព្យាយាមរត់ចេញទៅប្រទេសឡាវ តែត្រូវ«ចាប់បានវិញ» ។ ពេលសួរចម្លើយ យុទ្ធជននោះបាននិយាយថា«បដិវត្តន៍របស់យើងរឹងត្អឹងនិងពិបាកណាស់ មិនដូចជានៅប្រទេសឡាវនិងវៀតណាមទេ» ។ យុទ្ធជនម្នាក់ដែលធ្វើការនៅក្នុងអគ្គសេនាធិការគឺជាអ្នកសកម្មប្រឆាំងនឹងការហូបចុករួមដោយនិយាយថា«បដិវត្តន៍កុម្មុយនិស្តស្អីស៊ីបបរអីចឹង» ។

សុន សេន ទាញសេចក្តីសន្និដ្ឋានពីព័ត៌មានទាំងនេះថាវាជាការ«ច្បាស់លាស់ថាខ្មាំងបានចាប់ផ្តើមសកម្មភាពហើយទាំងនេះគឺជាសកម្មភាពដែលមានពាក់ព័ន្ធជាមួយនឹងខ្សែដឹកនាំពីព្រោះព័ត៌មានទាំងនេះមានលក្ខណៈដូចគ្នា ហើយពាក្យស្លោកក៏ដូចគ្នាដែរ» ។ សុន សេន បានព្រមានថា ខ្មាំងចង់ឆ្លៀតឱកាសប្រមូលសមាសភាពមិនល្អដែលគ្រួសាររបស់ខ្មាំងនោះយើងយកកម្ទេចអស់ហើយ អ្នកដែលយើងបានដកចេញពីតំណែង អ្នកដែលមិនដើរតាមចលនាបដិវត្តន៍និងមិនអាចដើរទាន់អ្នកផ្សេងៗទៀត ព្រមទាំងប្រជាជនថ្មីដែលមិនទាន់យល់ការណ៍នៅឡើយ និងអ្នកដែលយើងធ្វើឲ្យមានការលំបាកនិងខ្វះស្បៀង ។ ខ្មាំងសេ.អ៊ី.អាកំពុងតែរកឱកាសប្រមូលផ្តុំសមាសភាពទាំងនេះដើម្បីវាយយើង ។

សុន សេន បានទទូចថា ទោះជាមាន«៩៥ភាគរយនៃប្រជាជនទាំងអស់...សុទ្ធតែល្អក៏ដោយ» ប៉ុន្តែមានប្រហែលជា២ភាគរយជា«សមាសភាពមិនល្អ» ហើយពួកទាំងនេះមាននៅក្នុងជួរកងទ័ព ។ សុន សេន បានប្រកាសថា ជាការ«សំខាន់ណាស់ក្នុងការបោសសម្អាតសមាសភាពមិនល្អតទៅទៀត» និង «ម៉ឺងម៉ាត់»ជាមួយពួកវា «ប៉ុន្តែមិនឆ្វេងនិយមទេ» ។ សុន សេន ពន្យល់វែកញែកថា នេះមានន័យធ្វើឲ្យខុសគ្នារវាងអ្នកដែលជា «អ្នកគាំទ្រ»ខ្មាំងនិងអ្នកដែលមិនគាំទ្រ ហើយនៅក្នុងចំណោមអ្នកគាំទ្រទាំងនោះយើងត្រូវដឹងថា«ដោយសារតែគេមិនយល់ឬមួយជាពួកសមាសភាពដែលធ្វើការសម្ងាត់ជាមួយខ្មាំង?» ។ ទោះជាករណីណាក៏ដោយ ពួកសមាសភាពមិនល្អត្រូវតែកម្ទេចចេញពីអង្គភាព និងត្រូវតែ«ប្រមូលដាក់មួយកន្លែង»ដើម្បីកសាងដាច់ដោយឡែកៗពីគ្នា ។ សុន សេន បានបន្ថែមទៀតថាដាច់ខាតមិនឲ្យខ្មាំងទាំងនោះ«ចុះដល់ប្រជាជនមូលដ្ឋានឡើយ» ។

នៅក្នុងរបាយការណ៍នៅលើចំណាររបស់ សុន សេន ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦ ម៉េត បានជម្រាបដល់អគ្គសេនាធិការថា វរសេនាតូច៥១៣ កងពល៥០២ បានចាប់ខ្លួន «មនុស្សពីរនាក់ដែលក្នុងនោះមានម្នាក់ឈ្មោះ ស៊ុត និងម្នាក់ទៀតឈ្មោះ អេង កាលពីថ្ងៃទី១៥ ខែសីហា» នៅជិតរបងខាងត្បូងព្រលានយន្តហោះពោធិចិនតុង ។ ហេតុការណ៍នេះកើតឡើងក្រោយពីមានឧបទ្ទវហេតុមួយកាលពីថ្ងៃទី១៥ ខែសីហា ពេលដែល«ជនចម្លែកលួចសម្ភារ» នៅក្នុងបរិវេណតំបន់សឹកវរសេនាតូច៥១៣ ។ យោលតាមរបាយការណ៍របស់ ម៉េត នៅពេលសួរចម្លើយ ស៊ុត និង អេង ឆ្លើយថា


ប៉ុល ពត


ខៀវ សំផន


អៀង សារី


នួន ជា


សុន សេន


វន វេត


តាម៉ុក


ឌុច


កែ ពក


អៀង ធីរិទ្ធ


ខៀវ ប៉ុណ្ណារី


យុន យ៉ាត

ខ្លួនជាយុទ្ធជនកងម៉ារីនគណៈមជ្ឈិមវរសេនាធំ១៥២ ហើយរបាយការណ៍បានចាត់ទុកថាអ្នកទាំងពីរជាបណ្តាញខ្មាំង ។ របាយការណ៍នេះប្រកាសថា យោងតាម«សម្តីសារភាព» របស់វា «វាដើរក្រឡឹងជុំវិញលួចរបស់ផ្សេងៗស៊ីដូចជា អង្ករ មាន់ និងរបស់ផ្សេងៗទៀត» ។ «សកម្មភាពខ្មាំង»ទាំងនេះប្រហែលជាត្រូវបាន«បោសសម្អាត»ដែលជាផ្នែកមួយនៃ«ផែនការចាត់តាំង»របស់ខ្មាំងធ្វើឡើងដោយមនុស្សពីរនាក់មានឈ្មោះ សុវណ្ណ និង សាន ដែលធ្វើការបំផុសបំផុលថា «ធ្វើបដិវត្តន៍ពិបាក គ្មានបាយហូបគ្រប់គ្រាន់» ហើយថា«អ្នកដែលចង់ធ្វើធំគួរតែមានឋានៈបុណ្យសក្តិត្រឹមត្រូវ» ។

ម៉េត បានចូលរួមប្រជុំកម្មាភិបាលដឹកនាំកងពលធំនានាថ្ងៃទី១៦ ខែកញ្ញា ។ នៅក្នុងកិច្ចប្រជុំនោះ ម៉េត បានស្តាប់របាយការណ៍ចាប់ខ្លួនជាច្រើនទៀត ព្រមទាំងការពន្យល់និងការឲ្យយោបល់ពី សុន សេន ។ អនុលេខាកងពលធំលេខ៣១០ ឈ្មោះ វឿន បានរាយការណ៍ថាបានឃាត់ខ្លួនក្មេងម្នាក់នៅព្រែកក្តាមស្ថិតនៅភាគខាងជើងទីក្រុងភ្នំពេញដែលនិយាយថា «ស្ត្រីម្នាក់ឈ្មោះ មឿង...បានចាត់តាំងវាឲ្យមកឈ្លបការណ៍ឃ្លាំងអាវុធរបស់យើងនៅភ្នំពេញ» ។ លេខាកងពលធំលេខ៧០៣ ឈ្មោះ ពីន បានរាយការណ៍ថា«បានចាប់ខ្លួនប្រជាជន៨នាក់ដែលធ្វើដំណើរតាមទូកចេញពីកំពង់ចាម ចង់រត់ទៅ

វៀតណាម» ។ ពីន និយាយថា «ប្រជាជនទាំងនោះត្រូវបានបញ្ជូនត្រឡប់ទៅមូលដ្ឋានវិញហើយ» ។

ពេលនោះ សុន សេន បាននិយាយអំពី«សកម្មភាពខ្មាំងចក្រពត្តិអាមេរិក និងបរិវាររបស់វា» ។ ដោយយោងតាមលទ្ធផលជាក់ស្តែងពីការសួរចម្លើយនៅមន្ទីរ ស-២១ ទៅលើជនជាតិកម្ពុជាដែលអនុញ្ញាតឲ្យវិលត្រឡប់មកពីសហរដ្ឋអាមេរិក សង្កត់ធ្ងន់ថា «ខ្មែរ ចក្រី ជាខ្មែរបង្កប់ធំដែលទាក់ទងជាមួយចក្រពត្តិផង ជាមួយពួកសេរីរើផង» ។ ពួកវាទាក់ទងអូសទាញពួកទំនាស់មុខមាត់បុណ្យសក្តិនិងពួកមិនពេញចិត្តរបបបដិវត្តន៍របស់យើង» ។ នេះពីព្រោះតែ«សូវៀត វៀតណាម និងខ្មែរសេ.អុី.អាភ្ជាប់ជាមួយនឹងចក្រី» ។ «សកម្មភាពផុសផុលជ្រួលជ្រើម» ក្នុងជួរកងទ័ពបានបង្ហាញថាមាន«ខ្មែរសេ.អុី.អា»


អៀង ធីរិទ្ធ

និងកន្លែងផ្សេងទៀតតាំងពីខែមេសា ឆ្នាំ១៩៧៥ សុន សេន បានប្រកាសថា «យោងតាមចម្លើយរបស់អ្នកវិលត្រឡប់ពីបរទេសដែលយើងបានបញ្ជូនទៅធ្វើការងារបង្កបង្កើនផល ហើយរត់បាត់នោះ និយាយថា «ខ្លួនរត់នេះគឺដើម្បីទៅរាយការណ៍ឲ្យសេ.អុី.អានៅវៀតណាមខាងត្បូង» ។ «ការឆ្លើយ»របស់ប្រជាជនទាំងនេះប្រហែលជាការបង្ហាញពីផែនការរបស់ចក្រពត្តិបារាំងនិងអាមេរិកក្នុងការវាយប្រហារទៅលើដីកោះខ្មែរនៅក្នុងឈូងសមុទ្រថៃ។ ដោយលើកឡើងអំពី«ការលបជ្រៀតចូលនៃខ្មែរបណ្តាញ»របស់អតីតលេខាកងពល១៧០ដែលបានចាប់ខ្លួនរួចហើយឈ្មោះ ចាន់ ចក្រី ហៅ នៅ មាន សុន សេន ក្នុងចំណោម«ពួកជំហរបដិវត្តន៍មិនត្រឹមត្រូវ» ។ ទាំងនេះបង្ហាញថាកងទ័ពមានការធូររលុងបណ្តាលឲ្យសមាសភាពមិនល្អទាហានរត់ចោលជួរនិងខ្មាំងជ្រៀតចូលផ្សេងៗទៀតដែលត្រូវបានបោសសម្អាតពីជួរកងទ័ពក្នុងសម័យសង្គ្រាមឆ្នាំ១៩៧០-៧៥ ចូលមកម្តងទៀតក្រោយឆ្នាំ១៩៧៥ ជាមួយ«អ្នកមកថ្មីដែលមិនដែលច្បាំងសោះ» ព្រមទាំងប្រជាជនដែលត្រូវបានជម្លៀសមកពីភ្នំពេញ ។

សុន សេន បានស្នើឲ្យកម្មាភិបាលដឹកនាំតាមដានប្រវត្តិរបស់កងទ័ពឲ្យបានច្បាស់លាស់ ពិសេសប្រវត្តិរបស់អ្នកដែលទើបតែបានចុះចូលឈ្មោះថ្មីៗគឺដើម្បីកម្ទេចសមាសភាពទាំង

នោះតាមវិធានការផ្សេងៗ ។ មិនតែប៉ុណ្ណោះ សុន សេន បានចូលរួមក្នុងកិច្ចប្រជុំថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ រវាង "សមមិត្ត"ក្នុងកងពលធំ១៦៤ដែលនៅពេលនោះមានការពិភាក្សាអំពីការរកឃើញផែនការខ្មាំងរត់ចោលជួររៀបចំដោយកម្មាភិបាលអនុសេនាតូចម្នាក់ ព្រមទាំងមនុស្សប្រហែល៤០នាក់ទៀតនៅក្នុងកងពល និងមានការសម្តែងការព្រួយបារម្ភអំពី "សកម្មភាពមិនប្រក្រតី"នៅតាមមូលដ្ឋានជិតកំពង់សោម ។ កម្មាភិបាលទាំងនោះបានបន្ទោសអតីតទាហានសាធារណរដ្ឋដែលពាក់ព័ន្ធ"ចលនាមិនល្អ" ។ មិនតែប៉ុណ្ណោះកម្មាភិបាលបានជជែកពិភាក្សាអំពីការចាប់ខ្លួនថ្មីៗនៃអតីតទាហានសក្តិពីរបស់របបសាធារណរដ្ឋ។ សុន សេន បានណែនាំឲ្យកងពល"ចាប់ខ្លួននិងសួរចម្លើយ"កម្មាភិបាលអនុសេនាតូចឈ្មោះ វង្ស ស្រួល ។ សុន សេន ធ្វើដូច្នេះដើម្បី"ប្រមូល"អ្នករត់ចោលជួរនិងឲ្យពួកទាំងនោះ"បន្តបង្កើនផលនៅមួយកន្លែង" ព្រមទាំងដើម្បីប្រមូល "សមាសភាពអតីតទាហាន"សាធារណរដ្ឋ ។ សុន សេន មិនបានបញ្ជាក់ច្បាស់អំពីថាតើត្រូវចាត់វិធានការបែបណាឡើយចំពោះទាហានដែលជាមុខសញ្ញានេះ ។

វាមិនពិតទេថាតើ មុត មានវត្តមាននៅក្នុងកិច្ចប្រជុំនៅថ្ងៃ១៦ ខែកញ្ញា ប៉ុន្តែវាច្បាស់ណាស់ថាទាំង មុត និង ម៉េត បានចូលរួមប្រជុំសេនាធិការធ្វើឡើងនៅថ្ងៃទី១៩ ខែកញ្ញា ដែលពេលនោះមាន ហ៊ុយ កម្មាភិបាលទីបីតំណាងឲ្យមន្ទីរ ស-២១ឡើងធ្វើបទឧទ្ទេសនាម ។

កម្មាភិបាលដែលរៀបរាប់ទាំងនេះព្រមទាំងកម្មាភិបាលផ្សេងៗទៀតដែលមានវត្តមាននៅក្នុងកិច្ចប្រជុំបានស្តាប់ព្តការលើកឡើងអំពីសភាពការណ៍ឧទ្ទេសនាមដោយ សុន សេន ដែលស្នើសុំឲ្យមានការប្រុងប្រយ័ត្នបន្តទៅទៀត "ចំពោះសកម្មភាពខ្មាំងនៅខាងក្នុងប្រទេសនិងក្នុងជួរកងទ័ពយើង" សកម្មភាពទាំងអស់នោះគឺ "សកម្មភាពសេ.អ៊ី.អា" ។ ដោយយោងតាមអ្នកដែលត្រូវបានចោទដោយមន្ទីរ ស-២១ ថាជា "ជនក្បត់" ក្នុងចំណោមប្រជាជនខ្មែរដែលត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់មកពីសហរដ្ឋអាមេរិកនិងប្រទេសផ្សេងៗទៀតនោះ សុន សេន បាននិយាយថា ខ្សែទីមួយរួមមានអ្នកដែល "ធ្វើពុតជាស្នើសុំចូលស្រុកវិញស្របច្បាប់"និង"ពួកដែលលួចចូលដោយស្ងាត់ៗតាមព្រំដែនថៃ" ។ យោងតាម សុន សេន "សកម្មភាពកម្មេច" ប្រជាជនដែលជាមុខសញ្ញាទាំងនោះគឺចាប់ផ្តើមក្នុងខែមិថុនា ឆ្នាំ១៩៧៦ ។ ផ្ទុយទៅនឹងចម្លើយសារភាពរបស់ប្រជាជនទាំងនោះ សុន សេន បង្ហាញថា គម្រោងខ្សែបណ្តាញនេះគឺដើម្បី "វាយសម្រុកដើម្បីរំដោះឲ្យបានត្រឹមឆ្នាំ១៩៨០ ។ ខ្មាំងលួចសម្លាប់កម្មាភិបាល ព្រមទាំងបំផ្លាញកន្លែងស្តុកប្រេងព្រលានយន្តហោះនិងរោងចក្រ" ។ ទន្ទឹមនឹងនេះដែរខ្សែសូវៀតវៀតណាមបាន"ចេញទៅក្រៅអស់ដើម្បីពង្រីក""កម្លាំងជ្រៀតចូលក្នុងជួរកងទ័ពនិងតាមមូលដ្ឋាន" ដែលជាផ្នែកមួយនៃគម្រោងផែនការ "វាយយកយើងនៅឆ្នាំ១៩៨០ ដូចសេ.អ៊ីអាដែរ" ។ ជាភស្តុតាងនៃការទាក់ទងគ្នា សុន សេន បានលើកឡើងពីករណី "បណ្តាញរបស់អាចក្រីដែលជាសេ.អ៊ី.អា ប៉ុន្តែមានការទាក់ទងជាមួយនឹងពួកសេរីរីនៅតាមមូលដ្ឋាន តំបន់២៤និងតំបន់២៥ដែលជាប់ជាមួយនឹងវៀតណាម ។ ខ្មាំងបានប្រមូលយកកម្មាភិបាលដែលមានទំនាស់បុណ្យស័ក្តិមុខមាត់ ។ ពួកខ្មាំងបានប្រមូលផ្តុំគ្នាក្នុងបំណងកម្ទេចអង្គការយើងនៅក្នុងខែមេសា ឆ្នាំ១៩៧៦ ។ ជាមួយគ្នានេះដែរ ពួកខ្មាំងបានធ្វើសកម្មភាពខាងនយោបាយនិងវាយឆ្មក់ខាងយោធា" ។

ទោះបីជាយើងបានវែកមុខ ចក្រី ហើយក៏ដោយ ប៉ុន្តែខ្មាំងសំខាន់ណាស់ក្នុងការបន្តការប្រុងប្រយ័ត្នចំពោះការគំរាមកំហែងឥតឈប់ឈររបស់ "ការវាយពីខាងក្នុង" ដោយ"ខ្មាំងដែលបង្កប់ក្នុងជួរយើង" ។ សុន សេន ពន្យល់ថា អ្នកដែលមកប្រជុំនេះត្រូវតែ"ក្តាប់ឲ្យជាប់ជំហរវណ្ណៈនិងការតស៊ូវណ្ណៈ" ដែលបណ្តាលឲ្យមានទំនាស់"រវាងបដិវត្តន៍និងពួកចក្រពត្តិសេរីរី ។ លក្ខណៈនេះមានសារៈសំខាន់ជាងមុនទៅទៀត" ។ ដូច្នេះទោះបីជាការវាយប្រហាររបស់ខ្មាំង"ដែលបង្កប់នៅតាមមូលដ្ឋាននិងក្នុងជួរទ័ព"ត្រូវបានយើងធ្វើឲ្យបរាជ័យពីព្រោះយើងបាន "វាយកម្ទេច"បណ្តាញខ្មាំងក៏ដោយ ក៏វានៅតែមានសល់ទៀតដែរ ។ "សំខាន់ត្រូវមានជំហរថា ខ្មាំងមិនទាន់អស់ទេ ។ ពួកខ្មាំងនៅតែបន្តធ្វើសកម្មភាពវាយយើង ។ ដូច្នេះកុំភ្លើតភ្លើនខុសពីបដិវត្តន៍ ។

**(នៅមានត)**

**ស្ទីវ ហេឌ័រ**


ប៉ុល ពត


អៀង សារី


សុន សេន

# សៀវភៅខ្មៅ

## ទស្សនៈខ្មែរក្រហមចំពោះទឹកដីកម្ពុជាក្រោម

បោះពុម្ពផ្សាយដោយដោយមន្ទីរឃោសនាការនិងព័ត៌មាន
នៃក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ
ខែកញ្ញា ឆ្នាំ១៩៧៨


ខៀវ សំផន


នួន ជា


វន វេត

***(តពីលេខមុន) ៣) ការតស៊ូរវាងកម្ពុជានិងវៀតណាមស្តីអំពីបញ្ហាខ្សែបន្ទាត់នយោបាយចាប់តាំងពីឆ្នាំ១៩៥៤ដល់១៩៧០***

*នៅក្នុងរយៈកាលពីឆ្នាំ១៩៥៤ដល់ឆ្នាំ១៩៧០*

នៅក្នុងរយៈកាលពីឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៥៤ បដិវត្តន៍កម្ពុជាដែលពេលនោះកំពុងតស៊ូប្រឆាំងនឹងមាគ៌ានយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា មាគ៌ាឯករាជ្យ អធិប-តេយ្យភាព ម្ចាស់ការលើខ្លួនឯងនិងកំណត់ជោគវាសនារបស់ខ្លួនដោយខ្លួនឯង ប្រឆាំងនឹងមាគ៌ាពង្រីកនិងវាតទីលេបយកទឹកដីរបស់បក្សវៀតណាម ។ នោះជាការតស៊ូមួយដ៏ស៊ិតស្វាញនិងចបេសរីងរូស ។ ការតស៊ូនេះអាចបែងចែកទៅជាពីរដំណាក់កាល ។

*ទី១) ដំណាក់កាលចន្លោះឆ្នាំ១៩៥៤និងឆ្នាំ១៩៦០*

នៅក្នុងអំឡុងពេលនេះ ជនបដិវត្តកម្ពុជាពុំទាន់មានបក្សមួយដែលមានមាគ៌ានយោបាយកំណត់បានច្បាស់លាស់ ។ ក៏ប៉ុន្តែជនបដិវត្តវៀតណាមបានដឹកនាំចលនាបដិវត្តន៍កម្ពុជាដោយខ្លួនឯង ការតស៊ូជាចំហនិងសម្ងាត់នៅតាមទីក្រុងជាច្រើនក៏ដូចជានៅតាមទីជនបទ ។ នៅក្នុងរយៈកាលនេះចលនាបដិវត្តន៍កម្ពុជាបានលត់ដំខ្លួននៅក្នុងចលនាតស៊ូដែលអនុញ្ញាតឲ្យជនបដិវត្តន៍កម្ពុជាលត់ដំគោលជំហររបស់ខ្លួនជាបន្តបន្ទាប់គឺជំហរឯករាជ្យអធិបតេយ្យភាពពឹងផ្អែកលើកម្លាំងផ្ទាល់ហើយកំណត់ជោគវាសនារបស់ខ្លួនក៏ដូចជាការជឿជាក់នៅក្នុងកងកម្លាំងរបស់ខ្លួននិងមានសមត្ថភាពក្នុងការធ្វើបដិវត្តន៍ដោយខ្លួនឯង ។

ដោយផ្អែកលើបទពិសោធន៍ពិតប្រាកដចន្លោះឆ្នាំ១៩៥៤និងឆ្នាំ១៩៦០ដែលជនបដិវត្តកម្ពុជាបានរៀបចំសមាជមួយដើម្បីបង្កើតបក្សកម្មុយនិស្តកម្ពុជានៅថ្ងៃទី៣០

ខែកញ្ញា ឆ្នាំ១៩៦០ ដើម្បីអនុម័តលក្ខន្តិកៈបក្សនិងដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មាធិការមជ្ឈិមរបស់បក្ស ។ ជនបដិវត្តកម្ពុជាពេលនោះបានដាក់ចុះនូវមាគ៌ានយោបាយនិងមធ្យោបាយរបស់ខ្លួន ។

នៅពេលដែលវៀតណាមបានដឹងថាបក្សកុម្មុយនិស្តកម្ពុជាបានបង្កើតឡើងយ៉ាងពិតប្រាកដ វៀតណាមបានចាប់ផ្តើមបើកការវាយប្រហារជាប្រព័ន្ធប្រឆាំងនឹងបដិវត្តន៍កម្ពុជា ។ ក្នុងគោលដៅនេះវៀតណាមបានប្រើប្រាស់នីតិវិធីជាច្រើន ជាពិសេសនីតិវិធីពីរខាងក្រោមនេះ ÷

ក) ជាសម្ងាត់ វៀតណាមបានរៀបចំអង្គការដឹកនាំមួយទៀតដោយពុំមានការយល់ដឹងអំពីជនបដិវត្តកម្ពុជា ។ នៅពេលនោះហើយដែលបដិវត្តន៍កម្ពុជាបានបោះជំហានយ៉ាងធំ ក៏ប៉ុន្តែវាជាពេលដែលការគាបសង្កត់របស់សត្រូវកំពុងលាតត្រដាងគ្របសង្កត់យ៉ាងខ្លាំងដែរ ។ អ្នកដែលវៀតណាមបានជំនួសមុខតំណែងជាកម្មាភិបាលចាស់ៗដែលវៀតណាមបានបណ្តុះបណ្តាលមុនកិច្ចព្រមព្រៀងក្រុងហ្សឺណែវឆ្នាំ១៩៥៤



ដែលក្រោយមកជាសមាជិកក្រុមប្រជាជន ។

ធាតុផ្សំមួយចំនួននៃក្រុមនេះអាចបើកចំហវាយប្រហារបក្សកុម្មុយនិស្តកម្ពុជា នៅពេលដែលអ្នកដទៃទៀតអនុវត្តល្បិចកលញុះញង់ ។ វៀតណាមបានបើកឱកាសវាយប្រហារជាបន្តបន្ទាប់នៅពេលដែលបក្សរបស់យើងពុំទាន់បានសម្រេចការឯកភាពគ្នា នៅក្នុងប្រទេសទាំងមូលទេ ។ វៀតណាមបានរៀបចំបង្កើតសកម្មភាពទាំងនេះប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជានៅក្នុងបក្សកម្ពុជាផ្ទាល់ ។



១) វៀតណាមបានវាយប្រហារនយោបាយបក្សកុម្មុយនិស្តកម្ពុជាចាប់តាំងពីឆ្នាំ១៩៦០

◆វៀតណាមប្រឆាំងនឹងការវិភាគរបស់បក្សកុម្មុយនិស្តកម្ពុជាពាក់ព័ន្ធនឹងការបែងចែកសង្គមកម្ពុជាទៅជាវណ្ណៈផ្សេងៗ ។

◆វៀតណាមធ្វើពុតជាយល់ថា កម្ពុជាពុំទាន់ប្រមែប្រមូលផ្តុំគ្នានូវបំណែកនៃសង្គមរបស់ខ្លួនដែលត្រូវបានបែងចែកវណ្ណៈជាច្រើន ។ វៀតណាមអះអាងថា សង្គមកម្ពុជាមានលក្ខណៈដូចគ្នាទៅនឹងប្រទេសឡាវដែរ ដោយទាត់ចោលនូវការវិភាគវណ្ណៈនានានៃបក្សកុម្មុយនិស្តកម្ពុជា ។ ជាការច្បាស់ណាស់ថាវៀតណាមបានប្រឆាំងទៅនឹងមាគ៌ាបក្សទាំងមូល ។

◆វៀតណាមបានប្រឆាំងនឹងមាគ៌ាឯករាជ្យនិងអធិបតេយ្យភាពរបស់បក្សកុម្មុយនិស្តកម្ពុជា ។

◆មិនតែប៉ុណ្ណោះវៀតណាមបានប្រឆាំងនឹងមាគ៌ាដែលមានទិសធ្វើការតស៊ូប្រដាប់អាវុធផងនិងតស៊ូនយោបាយផង ។

ដើម្បីគាំទ្រការទាញហេតុផលរបស់ខ្លួន វៀតណាមបាននិយាយយោងទៅលើសេចក្តីសម្រេចចិត្តរបស់ភាគី៨១ប្រទេសដែលត្រូវបានអនុម័តនៅក្នុងទីក្រុងម៉ូស្គូក្នុងឆ្នាំ១៩៦០ ដែលចាត់ទុកការការពារសន្តិភាពពិភពលោកជាភារកិច្ចមួយដ៏មានអត្ថិភាព ។

ទី២) រយៈកាលចន្លោះឆ្នាំ១៩៦១ដល់ឆ្នាំ១៩៧០

ក្នុងឆ្នាំ១៩៦១ វៀតណាមបានបន្តវាយប្រយុទ្ធមកលើមាគ៌ានយោបាយបក្សកុម្មុយនិស្តកម្ពុជា ។ វៀតណាមបានដាក់ចេញនូវមាគ៌ានយោបាយសម្រាប់បក្សកុម្មុយនិស្តកម្ពុជា ហើយបានប្រគល់ជូនឯកសារនេះជាភាសាវៀតណាមទៅមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ។ វៀតណាមបានចោទប្រកាន់បក្សកុម្មុយនិស្តថាជាអ្នកផ្សងព្រេងនិងឆ្វេងនិយម ។ តាមពិតវៀតណាមត្រូវបានធ្វើឲ្យភ័យខ្លាចដោយសារចលនាបដិវត្តន៍របស់កម្ពុជាបានពុះកញ្ជ្រោលឡើងដោយការអភិវឌ្ឍជាបន្តនិងពង្រីងបក្សកុម្មុយនិស្តកម្ពុជានិងកងកម្លាំងបដិវត្តន៍បក្សកុម្មុយនិស្តកម្ពុជា ។ប្រឈមមុខនឹងសភាពការណ៍នេះវៀតណាមបានផ្តោតលើការវាយប្រហារប្រឆាំងនឹងមាគ៌ាបក្សដោយសម្រប

សម្រួលការវាយប្រហាររបស់ខ្លួនជាមួយនឹងក្រុមដែលវៀតណាមបានរៀបចំពីមុន ។ ការវាយប្រហារទាំងនេះត្រូវបានធ្វើឡើងនៅក្នុងអង្គការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាដោយកម្មាភិបាលឈានមុខដែលជាភ្នាក់ងារត្រូវបានវៀតណាមដាក់ឲ្យជ្រៀតចូលមកក្នុងបក្ស ។

នៅក្នុងឆ្នាំ១៩៦៥ បក្សកុម្មុយនិស្តកម្ពុជាបានបញ្ជូនគណៈប្រតិភូមួយក្រុមទៅបរទេស ។ នេះជាគណៈប្រតិភូដំបូងដែលបានទៅធ្វើទស្សនកិច្ចនៅក្រៅប្រទេស ។ គណៈប្រតិភូនេះដឹកនាំដោយសមមិត្តលេខា ប៉ុល ពត ។ ដំណើរទស្សនកិច្ចនេះត្រូវបានធ្វើឡើងដោយថ្មើរជើងពីមូលដ្ឋានបដិវត្តន៍នៅកម្ពុជាឆ្ពោះទៅក្រុងហាណូយ ។ គណៈប្រតិភូបក្សកុម្មុយនិស្តវៀតណាមត្រូវបានដឹកនាំដោយ ឡឺ ដួន ។ កិច្ចពិភាក្សាបានបន្តអស់រយៈពេលយ៉ាងយូរពីព្រោះវៀតណាមបានបន្តអូសបន្លាយការពិភាក្សាទាំងនេះដោយសំដៅទាញមាគ៌ានយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាឲ្យដើរខុសផ្លូវ ។ តាមពិតបក្សកុម្មុយនិស្តកម្ពុជាមានមាគ៌ានយោបាយរបស់ខ្លួនមួយដោយសារមាគ៌ានេះ ចលនាបដិវត្តន៍របស់កម្ពុជាបានបោះជំហានយ៉ាងវែង ។ បញ្ហានេះបានធ្វើឲ្យវៀតណាមមានការព្រួយបារម្ភពីព្រោះថា ប្រសិនបើបដិវត្តន៍កម្ពុជាបន្តទៅទៀតនោះនឹងប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការជាមួយវណ្ណៈដឹកនាំនៅក្នុងក្រុងភ្នំពេញ ។ អ្វីដែលធ្ងន់ធ្ងរជាងនេះទៅទៀតនោះគឺប្រសិនបើបដិវត្តន៍កម្ពុជាបានបង្កើតនិងពង្រឹងខ្លួនដោយរក្សាឯករាជ្យពេញលេញ វៀតណាមនឹងមិនអាចគ្រប់គ្រងត្រួតត្រាទឹកដីកម្ពុជាបានទេ ។ នោះគឺជាហេតុផលដែលវៀតណាមត្រូវតែទាញមាគ៌ាបដិវត្តន៍កម្ពុជាឲ្យខុសផ្លូវ ។

ដោយមានគោលដៅនេះនៅក្នុងទស្សនៈរបស់ខ្លួន វៀតណាមបានប្រមូលគ្រប់ចំណុចដែលជាគំនិតរបស់ខ្លួនសុទ្ធសាធដាក់បញ្ចូលទៅក្នុងឯករាជ្យមួយសម្រាប់ខាងកម្ពុជា ។ ឡឺ ដួន បានចំណាយពេលយ៉ាងយូរដើម្បីធ្វើពង្រាងឯកសារនេះ ។ ឡឺ ដួន បានពិនិត្យនិងកែតម្រូវឯកសារនេះជាច្រើនលើកច្រើនសា ។

ការិយាល័យនយោបាយរបស់បក្សវៀតណាមបានត្រួតពិនិត្យនិងកែតម្រូវឯកសារនេះបន្ថែមទៀត ។ ឯកសារដែលសរសេរជាភាសាវៀតណាមនេះពុំបាននិយាយអំពីការតស៊ូវណ្ណៈនិងការតស៊ូប្រឆាំងចក្រពត្តិអាមេរិកឡើយ ។ នៅក្នុងឯកសារនេះសរសេរថា វៀតណាមសម្រេចបាននូវជោគជ័យរួចវៀតណាមនឹងមករំដោះកម្ពុជា ។

នៅក្នុងឯកសារនេះ វៀតណាមបានអនុវត្តការក្រោកឡើងតស៊ូប្រឆាំងនឹងទស្សនៈបដិវត្ត និងគោលជំហរបក្សកុម្មុយនិស្តកម្ពុជាដើម្បីឲ្យបក្សកុម្មុយនិស្តកម្ពុជាបោះបង់ចោលនូវការតស៊ូបដិវត្ត ហើយរង់ចាំរហូតដល់វៀតណាមសម្រេចបាននូវជោគជ័យរបស់ខ្លួនដែលនឹងនាំមកនូវជ័យជម្នះដល់កម្ពុជាជាស្វ័យប្រវត្តិ ។

នៅក្នុងកិច្ចពិភាក្សានេះ វៀតណាមដឹងយ៉ាងច្បាស់ថាបក្សកុម្មុយនិស្តកម្ពុជាបានគោរពតាមគោលជំហរឯករាជ្យនិងអធិបតេយ្យភាពយ៉ាងម៉ឺងម៉ាត់ ។ នោះប្រហែលជាមូលហេតុដែលវៀតណាមបានផ្តោតការវាយប្រហារប្រឆាំងនឹងគោលជំហរនេះ ។ ឡឺ ដួន បានបញ្ជាក់ថា ពិភពលោកពុំអាចអនុវត្តគោលជំហរឯករាជ្យនិងអធិបតេយ្យភាពបានទេ ។ មនុស្សម្នាក់ៗត្រូវពឹងពាក់អ្នកដទៃ ។ នេះជាការពិតចំពោះវៀតណាម ។ ចំពោះប្រទេសទាំងបី វៀតណាម ឡាវ និងកម្ពុជា ត្រូវតែគាំទ្រគ្នាទៅវិញទៅមក ។

ការតស៊ូអំពីបញ្ហាមាគ៌ានយោបាយមានភាពស្មុគស្មាញណាស់ ។ ក៏ប៉ុន្តែជានិច្ចកាលខាងកម្ពុជាមានភាពអំណត់ប្រុងប្រយ័ត្នជាប់ជានិច្ច ហើយពុំបានធ្វើអ្វីទាំងអស់ដែលអាចបណ្តាលឲ្យវៀតណាមមានការអាក់អន់ចិត្តឡើយ ។ បន្ទាប់ពីការចាកចេញរបស់សមមិត្តលេខា ប៉ុល ពត មកកម្ពុជាវិញ វៀតណាមបានដឹងថាបក្សកុម្មុយនិស្តកម្ពុជានឹងបន្តអនុវត្តមាគ៌ារបស់ខ្លួនដែលត្រូវធ្វើការតស៊ូប្រដាប់អាវុធគួបផ្សំជាមួយនឹងការតស៊ូនយោបាយ ។

បន្ទាប់មក វៀតណាមបានរឹតបន្តឹងសកម្មភាពរបស់ខ្លួនប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជានៅតាមមូលដ្ឋានបដិវត្តន៍ភាគបូព៌ានិងនិរតី ។ វៀតណាមបានអនុវត្តសកម្មភាពសំដៅបង្កើតការភ័ន្តច្រឡំនិងការបែកបាក់នៅក្នុងជួរបដិវត្តន៍កម្ពុជា ។

វៀតណាមបានប្រើផែប្រែងធ្វើសកម្មភាពដោយខ្លួនឯង មិនតែប៉ុណ្ណោះវៀតណាមបានចាត់តាំងសមាសភាពខ្មែរដែលខ្លួនបានរៀបចំអស់ជាយូរណាស់មកហើយនោះឲ្យជ្រៀតចូលទៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា ។ នៅឯបរទេស វៀតណាមបានអនុវត្តសកម្មភាពបំបែកបំបាក់តាមរូបភាពជាច្រើន ។ វៀតណាមបានបែកចាយទ្រឹស្តីម៉ាក្ស-ឡេនីនថា «ពួកឆ្វេងនិយម ជំងឺកុម្មុយនិស្តដ៏ក្មេងខ្ចី» ។



នៅខែកុម្ភៈឆ្នាំ១៩៦៧ ការក្រោកឡើងតស៊ូប្រដាប់អាវុធបានផ្ទុះឡើងនៅសំឡូត ខេត្តបាត់ដំបង ។ វៀតណាមភ័យស្ញន់ស្ញោ ហើយវាយប្រហារកាន់តែខ្លាំងក្លាថែមទៀតប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជា ។ នៅពេលក្រោយមកបន្តិចមានភាពស្ងប់មួយរយៈ វៀតណាមក៏ធូរស្បើយបន្តិចទៅវិញ ។ ក៏ប៉ុន្តែក្នុងឆ្នាំ១៩៦៨ នៅពេលដែលចលនាតស៊ូប្រដាប់អាវុធមួយបានកើតឡើងនៅក្នុងប្រទេសកម្ពុជា វៀតណាមក្រោកឡើងប្រឆាំងម្តងទៀត ។

នៅក្នុងការតស៊ូប្រដាប់អាវុធចាប់តាំងពីឆ្នាំ១៩៦៨ មកដល់ដើមឆ្នាំ១៩៧០ វៀតណាមពុំបានជួយបដិវត្តន៍កម្ពុជាទាល់តែសោះ ទោះបីជាអង្គការដឹកនាំរបស់វៀតណាមបានបោះទីតាំងនៅគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជាក៏ដោយ ។ មូលហេតុ គឺថាមាគ៌ាទាំងពីរ មួយមាគ៌ារបស់បក្សកុម្មុយនិស្តកម្ពុជានិងមួយទៀតមាគ៌ារបស់បក្សវៀតណាម មានគោលការណ៍ផ្ទុយគ្នា បានប្រយុទ្ធប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជា ។ ម្យ៉ាងវិញទៀតវៀតណាមត្រូវប្រាស្រ័យក្នុងន័យបំពេញចិត្តវណ្ណៈកាន់អំណាចនៅកម្ពុជាដើម្បីទទួលបានការជួយគាំទ្រ ។

បក្សកុម្មុយនិស្តកម្ពុជាពុំបានសួរអ្វីទាំងអស់អំពីវៀតណាម វៀតណាមក៏នៅស្ងៀម ហើយចៀសវាងពុំអនុវត្តសកម្មភាពនានាប្រឆាំងនឹងបដិវត្តន៍និងប្រជាជនកម្ពុជា ។ ក៏ប៉ុន្តែវៀតណាមបានញុះញង់ជាសម្ងាត់ចំពោះកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាដើម្បីប្រឆាំងនឹងបក្សរបស់ខ្លួន ហើយបន្តបង្កើតបណ្តាញសម្ងាត់នានា ។ មាគ៌ានយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាពិតជាត្រឹមត្រូវ ។ ប្រសិនបើបក្សពុំបានដឹកនាំចលនាតស៊ូប្រដាប់អាវុធទេ បដិវត្តន៍កម្ពុជាប្រហែលជាត្រូវបានថ្កោលទោសឲ្យបាត់ពីលោកនេះ គ្រាន់តែយូរនិងឆាប់តែប៉ុណ្ណោះ ។

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigpond.com.kh

# យុត្តិធម៌ដែលត្រូវបានពន្យារពេលនៅកម្ពុជា

នៅក្នុងខែមេសាកាលពី២៥ឆ្នាំមុន ទាហានខ្មែរក្រហមបានចូលមកទីក្រុងភ្នំពេញដែលជារាជធានីនៃប្រទេសកម្ពុជា ។ ពេលនោះរបបប្រល័យពូជសាសន៍មួយក៏បានកើតឡើង ហើយដែលបានសម្លាប់បង្អត់អាហារបណ្តាលឲ្យមានប្រជាជនកម្ពុជាស្លាប់ចំនួន១លាន៧សែននាក់មុនពេលដែលរបបនេះត្រូវបានផ្តួលរំលំដោយកងទ័ពក្រុងហាណូយក្នុងឆ្នាំ១៩៧៩ ។ ម្ភៃឆ្នាំក្រោយមក ប៉ុល ពត ដែលជាពេជ្ឈឃាតដ៏សាហាវបំផុតនៅក្នុងសតវត្សរ៍ទី២០ បានគេចខ្លួនពីសំណាញ់យុត្តិធម៌ ។ នៅក្នុងឆ្នាំកន្លងទៅនេះ ប៉ុល ពត បានស្លាប់នៅក្នុងដំណេករបស់ខ្លួន ។ ប្រទេសចិន សហរដ្ឋអាមេរិកនិងសហគមន៍ប្រជាជាតិអាស៊ីភាគអាគ្នេយ៍ហៅកាត់ថាអាស៊ាន រួមមានប្រទេសថៃនៅក្នុងនោះដែរសុទ្ធតែធ្លាប់បានគាំទ្រខ្មែរក្រហមតាមវិធីជាច្រើនយ៉ាងដែលខ្លួនអាចធ្វើទៅបាន ។ ប្រទេសមហាអំណាចបានប្រឆាំងជំទាស់រាល់ការប៉ុនប៉ងនាំយកខ្មែរក្រហមមកកាត់ទោស ។ នៅក្នុងពិភពលោកយើងនេះគ្មានឃើញប្រទេសណាមួយធ្វើសំណុំរឿងប្តឹងនឹងពួកខ្មែរក្រហមនៅក្នុងតុលាការពិភពលោកឡើយ ។ ខ្មែរក្រហមក៏ចេះតែបន្តអង្គុយលើអាសនៈកម្ពុជានៅឯអង្គការសហប្រជាជាតិតំណាងឲ្យជនរងគ្រោះរបស់ខ្លួនអស់រយៈពេល១៥ឆ្នាំទោះបីជាខ្លួនត្រូវបានដឹងឮជាចំហថាមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មយ៉ាងណាក៏ដោយ ។ មិនតែប៉ុណ្ណោះទៀតសោត ជំនួយរបស់អន្តរជាតិក៏បានហូរចូលទៅក្នុងហិបប្រាក់របស់ខ្មែរក្រហមធ្វើឲ្យក្រុមនេះបន្តសង្គ្រាមដើម្បីកាន់កាប់អំណាចសាជាថ្មី ។


ប៉ុល ពត

រដ្ឋាភិបាលជាច្រើនមិនមានកំហុសតែម្នាក់ឯងទេ ។ នៅក្នុងទសវត្សរ៍ឆ្នាំ៨០ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិផ្សេងៗដែលគួរឲ្យគោរពបានទាត់ចោលនូវរាល់សេចក្តីអញ្ជើញជាច្រើនរាប់មិនអស់ក្នុងការបញ្ជូនគណៈប្រតិភូអង្គចៅក្រមមកប្រទេសកម្ពុជា ដើម្បីធ្វើការស៊ើបអង្កេតលើរឿងក្តីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនិងផ្តើមបង្កើតវិធានការច្បាប់ជាផ្លូវការ ។ សមាគមអ្នកច្បាប់របស់សហរដ្ឋអាមេរិក សមាគមច្បាប់អាស៊ី និងបេសកកម្មអង្គចៅក្រមអន្តរជាតិ សុទ្ធតែជំទាស់នូវសំណើនេះទាំងអស់ ។ មានតែសាខាបេសកកម្មអន្តរជាតិនៃអង្គចៅក្រមរបស់ប្រទេសអូស្ត្រាលីតែមួយគត់ដែលសម្តែងនូវឆន្ទៈរបស់ខ្លួននាចុងទសវត្សរ៍ឆ្នាំ៨០ ។ គ្រប់ប្រព័ន្ធឃោសនាដែលមានអំណាចខ្លាំងក្លារបស់អាមេរិកបានធ្វើយុទ្ធនាការដើម្បីបន្ទុចបង្អាក់នូវរាល់ការព្យាយាមចងក្រងឯកសារទាក់ទងនឹងឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ ក៏ប៉ុន្តែតាមសំណើរបស់កម្ពុជាធ្វើឡើងនៅឆ្នាំ១៩៩៧ អង្គការសហប្រជាជាតិបានបង្កើតក្រុមជំនាញការដើម្បីធ្វើការស៊ើបអង្កេតដែលដឹកនាំដោយអតីតឧត្តមសេនីយ៍ជនជាតិអូស្ត្រាលី

ឈ្មោះលោក នីនាន ស៊ីហ្វិន ។ របាយការណ៍ឆ្នាំ១៩៩៩របស់អង្គការសហប្រជាជាតិគឺនិយាយអំពីតុលាការអន្តរជាតិសម្រាប់ជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមស្តីពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាម ។ បច្ចុប្បន្ននេះកិច្ចចរចាកំពុងតែដំណើរការជាមួយនឹងរដ្ឋាភិបាលកម្ពុជាដែលបានចាប់ខ្លួននិងទទួលយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់ឲ្យចូលមកក្នុងសង្គមវិញ ។

ហេតុអ្វីក៏ចំណាយពេលយូរម្ល៉េះ? ចាប់តាំងពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៤ មានការប្រឆាំងយ៉ាងខ្លាំងទៅនឹងរាល់ចំណាត់វិធានការច្បាប់ប្រឆាំងនឹងខ្មែរក្រហម ។ ទើបតែមកដល់ឆ្នាំ១៩៩៤នោះទេ ដែលមានការផ្លាស់ប្តូរសំខាន់ ។

## ក្នុងរវាងឆ្នាំ១៩៧៩-១៩៩៤

នៅពេលដែលកងទ័ពវៀតណាមបណ្តេញពួកខ្មែរក្រហមចេញពីអំណាចក្នុងឆ្នាំ១៩៧៩ ប្រទេសភាគច្រើននៅលើពិភពលោកបានតម្រង់ជួរគ្នាប្រឆាំងនឹងសង្គ្រាមត្រជាក់ ។ ដោយសារអន្តរាគមន៍របស់ខ្លួន ទីក្រុងហាណូយត្រូវបានមើលឃើញថាជាអ្នកបង្ក«បញ្ហាកម្ពុជា»ជាជាងអ្នកបញ្ចប់អំពើប្រល័យពូជសាសន៍ ។ ដោយមានការឧបត្ថម្ភគាំទ្រពីសំណាក់ប្រទេសអូស្ត្រាលីក៏ដូចជាសហរដ្ឋអាមេរិកនិងប្រទេសចិន ខ្មែរក្រហមក៏បន្តលទ្ធភាពរបស់ខ្លួនក្នុងការកាន់កាប់អាសនៈរបស់ខ្លួននៅឯអង្គការសហប្រជាជាតិ ។ មានតែប្រទេសលោកខាងលិចមួយគត់ដែលប្រឆាំងជាទាស់ប៉ុន្តែមិនបោះឆ្នោតប្រឆាំងនឹងបញ្ហានេះនោះគឺប្រទេសបារាំង ។

ចាប់តាំងពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨២ ខ្មែរក្រហមនៅតែបន្តកាន់កាប់អាសនៈកម្ពុជាតែម្នាក់ឯងដដែលដោយប្រើផ្លាក«កម្ពុជាប្រជាធិបតេយ្យ» ។ ពេលនោះមានបក្សមិនមែនកុម្មុយនិស្តចំនួនពីរបានចូលរួមបង្កើតជារដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលមិនប្រាកដថាជារដ្ឋាភិបាលចម្រុះប្រជាធិបតេយ្យនិងក៏មិនមែននៅក្នុងប្រទេសកម្ពុជាដែរ ។ ដូច្នេះទង់ជាតិខ្មែរក្រហមបានបក់រវិចៗនៅទីក្រុងញូវយ៉ក (ទីតាំងរបស់អង្គការសហប្រជាជាតិ) រហូតដល់ឆ្នាំ១៩៩២ ។

មានកត្តាជាច្រើនដែលនាំដល់ការរួចទោសរបស់ខ្មែរក្រហមក្រោយពីឆ្នាំ១៩៧៩៖

## ប្រទេសថៃ

ប្រទេសថៃបានផ្តល់ការគាំទ្រយ៉ាងសំខាន់ដល់ខ្មែរក្រហមទាំងជម្រកនៅតាមព្រំដែននិងជំនួយការទូតសម្ងាត់ (សូមអានសៀវភៅរបស់បណ្ឌិត ដួងជុង វុងសាវ៉ាឌីសាប មានចំណងជើងថា«សម្ព័ន្ធរបស់ថៃចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា»ផលិតដោយកម្មវិធីសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៃសកលវិទ្យាល័យយែល ឆ្នាំ១៩៩៩) ។ នៅក្នុងឆ្នាំ១៩៨៥រដ្ឋមន្ត្រីការបរទេសថៃបានពិពណ៌នាអំពីអនុរបស់ ប៉ុល ពត ឈ្មោះ សុន សេន ថាជា«មនុស្សល្អណាស់» ។ នៅឆ្នាំ១៩៩១ ឧត្តមសេនីយ៍ សុជីដា ក្រប៉ាយ៉ុន ដែលឡើងកាន់អំណាចនៅប្រទេសថៃតាមរយៈរដ្ឋប្រហារបាននិយាយជាមួយព្រឹទ្ធសភារបស់រដ្ឋអាមេរិកថា ខ្លួនគាត់ក៏គិតថា ប៉ុល ពត ជា«មនុស្សល្អ»ដែរ ។ នាយករដ្ឋមន្ត្រីថៃ អាណាន់ ប៉ាន់យ៉ាធុនបានប្រាប់ទៅមនុស្សជំនិតរបស់ ប៉ុល ពត ឈ្មោះ ខៀវ សំផន ថា «កាលពី១៦ឆ្នាំ មុនរូបខ្ញុំផ្ទាល់ក៏ត្រូវបានចោទប្រកាន់ថាជាជនកុម្មុយនិស្តដែរ ។ ឥឡូវគេយកខ្ញុំធ្វើជានាយករដ្ឋមន្ត្រី។ នៅក្នុងសង្គមណាក៏ដោយតែងតែមានក្រុមក្បាលរឹងនិងក្បាលទន់ ហើយសង្គមក៏ចេះតែប្រែប្រួលប្រែតាមពេលវេលាដែរ» ។

ក្រោយពីជួបជាមួយនឹង ប៉ុល ពត នៅឆ្នាំ១៩៩១ សុចិន្តា បាននិយាយសម្រួលចំពោះមុខប្រព័ន្ធឃោសនាថា ប៉ុល ពត គ្មានបំណងនឹងវិលត្រឡប់មកកាន់អំណាចជាថ្មីម្តងទៀតទេ ពេលនេះវាសមល្មមនឹង«ធ្វើល្អ» ចំពោះគាត់ហើយ ។

## ប្រព័ន្ធឃោសនា

នៅដើមទសវត្សរ៍ឆ្នាំ៩០ មានប្រព័ន្ធឃោសនាខ្លះនៅតាមបណ្តោយព្រំដែនថៃត្រូវបានភ្នាក់ងាររដ្ឋរការរបស់លោកខាងលិចជំរុញឲ្យនិយាយថា ខ្វារខិនខ្មែរក្រហមបានផ្លាស់ប្តូរពណ៌ស្បែករបស់ខ្លួនហើយ ។ ទីមួយខ្មែរក្រហមបានក្លាយខ្លួនជាបរិស្ថានវិទូ ។ មានអ្នករាយការណ៍ម្នាក់បាននិយាយកាលពីឆ្នាំ១៩៩១ថា «ប្រភពស៊ើបការសម្ងាត់លោកខាងលិចតាមព្រំដែនកម្ពុជា-ថៃនិយាយថា ថ្មីៗនេះ ប៉ុល ពត បានដាក់ចេញទិសដៅមួយអំពាវនាវកុំឲ្យប្រជាជនកម្ពុជាប្រមាញ់សត្វខុសច្បាប់និង

សម្លាប់សត្វ ទោះយកទៅធ្វើអ្វីក៏ដោយ» ។ មេបញ្ជាការយោធារបស់ ប៉ុល ពត ឈ្មោះ តាម៉ុក ត្រូវបានប្រភពស៊ើបការណ៍សម្ងាត់ផ្សេងៗរបស់លោកខាងលិចចាត់ទុកថាមានការអនុវត្ត«ដាច់ខាតចំពោះបញ្ហាបរិស្ថានវិទ្យានិងការការពារពូជសត្វដែលកំពុងតែទទួលរងគ្រោះថ្នាក់ផុតពូជ» ។

និយាយអំពីមេបញ្ជាការសមរភូមិមុខក្នុងឆ្នាំ១៩៨៧ ប៉ុល ពត បានបញ្ជាក់ថា «ម៉ុក ជាមនុស្សល្អបំផុតក្នុងចំណោមមេបញ្ជាការទាំងអស់ ។ ទោះបី ម៉ុក ឃោរឃៅក៏ពិតមែន តែអំពើល្អតែងតែឈ្នះអំពើអាក្រក់» ។ មេបញ្ជាការថ្នាក់ក្រោមបាននិយាយថា តាម៉ុក «ឃោរឃៅ តែមានហេតុផល» ។ ម៉ុក ត្រូវបានដកស្រង់សម្តីថា «ខ្ញុំដឹងថាប្រជាជននៅក្នុងស្រុកខ្មែរខ្លាចខ្ញុំ» ។ ពាក្យសម្តីនេះមិនត្រូវបានយកទៅរាយការណ៍នៅក្នុងសារពត៌មានឡើយ ។ អ្នកវិភាគសភាពការណ៍លោកខាងលិចម្នាក់នាទីក្រុងបាងកកបានពិពណ៌នាថា «ប្រជាជនស៊ីវិលគោរពខ្មែរក្រហមជាងក្រុមបីផ្សេងទៀត» ។ និយាយពីកិច្ចព្រមព្រៀងក្រុងប៉ារីស ឆ្នាំ១៩៩១ ទស្សនាវដ្តីចុងបូព៌ាបានរាយការណ៍ថា «អ្នកការទូតនិយាយថា ខ្មែរក្រហមមិនគួរចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែលខ្លួនមិនពេញចិត្តនឹងធ្វើតាមនោះឡើយ» ។ ទ័ពខ្មែរក្រហមបានវាយប្រហារយ៉ាងរហ័សទៅលើភូមិចំនួន២៥ នៅក្នុងខេត្តកំពង់ធំធ្វើឲ្យមនុស្សចំនួនមួយម៉ឺននាក់ចាកចេញពីផ្ទះសម្បែង ។ ក្នុងខណៈដែលអ្នកការទូតមួយចំនួនហៅព្រឹត្តិការណ៍នេះថាជា«ការរំលោភយ៉ាងបំពានទៅលើបទឈប់បាញ់គ្នានោះ»មានមជ្ឈដ្ឋានមួយចំនួនធ្វើការវែកញែកថា «ខ្មែរក្រហមវាយប្រហារក្តៅៗយ៉ាងដូច្នេះ គឺដើម្បីបង្អាក់ការពង្រាយកងថែរក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិនៅតំបន់នោះ» ។

ថ្មីៗនេះទៀតមានអ្នកសារពត៌មានមួយចំនួនមានការយឺតយ៉ាវក្នុងការរាយការណ៍អំពីរបកគំហើញរបស់ជំនាញការច្បាប់ដែលថាខ្មែរក្រហមមានរឿងក្តីប្រល័យពូជសាសន៍មួយដែលត្រូវស្រាយបំភ្លឺ ។ សរសេរនៅក្នុងញូវយ៉កយ័រ នាខែសីហា ឆ្នាំ១៩៩៨ ហ៊ីលីព ហ្គូរេវិច បានអះអាងថា «ប៉ុន្តែរបបមរណៈដែលខ្មែរក្រហមបានដឹកនាំនៅក្នុងប្រទេសកម្ពុជាមិនត្រូវទៅនឹងនិយមន័យច្បាប់ស្តីអំពីពាក្យថាប្រល័យពូជសាសន៍មួយរយភាគរយឡើយ(ទង្វើដែលធ្វើឡើងដោយមានចេតនាកម្ទេចទាំងស្រុងឬក៏ជាផ្នែកនៃជាតិសាសន៍ ជនជាតិ ជាតិពន្ធុឬក្រុមសាសនា) ។ ទោះបីជាជនជាតិភាគតិចខ្លះត្រូវបានបោសសម្អាតដោយសារការធ្វើទុក្ខបុកម្នេញនៅក្នុងរបប ប៉ុល ពត យ៉ាងណាក៏ដោយ ឧក្រិដ្ឋកម្មទាំងមូលត្រូវមានការសម្លាប់ជនជាតិខ្មែរដែលមានលក្ខណៈជាប្រព័ន្ធប្រព្រឹត្តឡើងដោយរដ្ឋខ្មែរ...និយាយដូច្នេះមិនមានន័យថាអំពើប្រល័យពូជសាសន៍សម្រាលដល់បទល្មើសឡើយ ។ តាមការពិតការសិក្សាស្រាវជ្រាវលើករណីនេះបានសន្និដ្ឋានផ្សេងដូចខាងក្រោម÷ «សំណេរដែលមានស្រាប់បង្ហាញឲ្យបានកាន់តែជ្រៅទៅទៀតពីករណីដែលមិនទាន់បានស្រាវជ្រាវអំពីខ្មែរក្រហមដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងក្រុមជនជាតិចាម វៀតណាម ចិន និងថៃ ក៏ដូចជាព្រះសង្ឃ» ។ បង្កើតគំនិតផ្នែកច្បាប់មួយ «ឧក្រិដ្ឋកម្មទាំងមូល» មិនសម្រាលទម្ងន់បទល្មើសឡើយ ។ អំពើប្រល័យពូជសាសន៍គឺជាអំពើធ្ងន់ធ្ងរបំផុតដែលតែងតែត្រូវបានហៅជាទូទៅថា«ឧក្រិដ្ឋកម្មធ្ងន់ធ្ងរប្រឆាំងនឹងមនុស្សជាតិ» ដោយសារតែមានភស្តុតាងបញ្ជាក់ពីចេតនា ហើយជនរងគ្រោះក្រោមអំពើប្រល័យពូជសាសន៍នេះមានដំណោះស្រាយផ្លូវច្បាប់ណាមួយ ។ របបខ្មែរក្រហមបានប្រព្រឹត្តបទល្មើស៥ចំណុចដូចដែលបានបង្ហាញតាមរយៈរបាយការណ៍របស់ក្រុមជំនាញការរបស់អង្គការសហប្រជាជាតិកាលពីឆ្នាំ១៩៩៩ ។

## នយោបាយចិននិងសហរដ្ឋអាមេរិក

«ខ្ញុំមិនយល់ថាហេតុអ្វីបានជាមានអ្នកខ្លះចង់កម្ចាត់ ប៉ុល ពត» ។ «ជាការពិតណាស់ថាគាត់បានប្រព្រឹត្តកំហុសនៅក្នុងអតីតកាល តែឥឡូវនេះ ប៉ុល ពត កំពុងតែដឹកនាំប្រយុទ្ធប្រឆាំងនឹងពួកឈ្លានពានវៀតណាម» ។ នេះជាសម្តីរបស់លោក តេង ស៊ាវពីង ដែលបាននិយាយកាលពីឆ្នាំ១៩៨៤ ។ យោងតាមភ្នាក់ងារសម្ងាត់របស់សហរដ្ឋអាមេរិកបានឲ្យដឹងថាប្រទេសចិនបានផ្តល់ឲ្យកម្លាំងទ័ពខ្មែរក្រហមនូវអាវុធយុទ្ធភណ្ឌដែលគិតជាទឹកប្រាក់មានចំនួនដល់១០០លានដុល្លារសហរដ្ឋអាមេរិកក្នុង




យុទ្ធនាការជញ្ជូនអាវុធយ៉ាងច្រើនសន្ធឹកសន្ធាប់កាលពីពាក់កណ្តាលឆ្នាំ១៩៩០ បានរំលោភទៅលើកិច្ចសន្យាកាត់ផ្តាច់ការផ្តល់អាវុធទៅឲ្យខ្មែរក្រហមដែលជាថ្នូរនឹងការដកកងទ័ពវៀតណាមចេញពីកម្ពុជាកាលពីខែកញ្ញា ឆ្នាំ១៩៨៩ ។

អស់រយៈកាលជាងមួយទសវត្សរ៍ក្រោយមក ជំនួយឧបត្ថម្ភគាំទ្រជាផ្លូវការរបស់បស្ចិមប្រទេសចំពោះ តេង ស៊ាវពីង ដែលជាប្រធានាធិបតីនៃប្រទេសចិន មានចំនួនច្រើនលើសលប់ ហើយធ្លាក់ទៅដល់មនុស្សក្រោមអាណាព្យាបាលកិច្ចរបស់ចិនឈ្មោះ ប៉ុល ពត ។ អតីតទីប្រឹក្សាផ្នែកសន្តិសុខជាតិរបស់សហរដ្ឋអាមេរិក លោក ប៊ីនីវ ប្រេហ្សីនស្គី បានរំឭកថា កាលពីឆ្នាំ១៩៧៩ «ខ្ញុំបានជំរុញឲ្យប្រទេសចិនគាំទ្រ ប៉ុល ពត ។ ប៉ុល ពត គឺជាមនុស្សគួរឲ្យស្អប់ខ្ពើម ។ យើងនឹងមិនឧបត្ថម្ភដល់ ប៉ុល ពត ទេ ប៉ុន្តែប្រទេសចិនអាចធ្វើដូច្នេះ» ។ យោងតាមសម្តីរបស់ ប្រេហ្សីនស្គី បានឲ្យដឹងថា សហរដ្ឋអាមេរិកបាន«ញាក់ភ្នែកជាសញ្ញាយល់ព្រមពាក់កណ្តាលសាធារណៈ» ចំពោះជំនួយរបស់ចិននិងថៃទៅឲ្យខ្មែរក្រហម ។ ទន្ទឹមពេលគ្នានេះដែរ ជំនួយរបស់អន្តរជាតិចំពោះខ្មែរក្រហមតាមព្រំដែនថៃត្រូវបានជួយជំរុញដោយមន្ត្រីសហរដ្ឋអាមេរិក ។

នៅក្នុងទសវត្សរ៍ឆ្នាំ៨០ រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក លោក ចច ហ្សាត់ បានប្រឆាំងនឹងកិច្ចប្រឹងប្រែងទាំងឡាយក្នុងការស៊ើបអង្កេត ឬធ្វើការចោទប្រកាន់ខ្មែរក្រហមពីបទប្រល័យពូជសាសន៍ឬខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ហ្សាត់ ពិពណ៌នាកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី ប៊ីល ហេដិន ក្នុងការពិភាក្សាដេញដោលស្តីអំពីបញ្ហាកម្ពុជាថាជា«ការភ្លីភ្លើ» ហើយក្នុងឆ្នាំ១៩៨៦ គាត់បានបដិសេធមិនគាំទ្រដល់សំណើសុំឲ្យមានតុលាការអន្តរជាតិដែលស្នើឡើងដោយលោក ហេ ដិន។ នៅក្នុងឆ្នាំ១៩៨៥ ហ្សាត់ បានមកធ្វើទស្សនកិច្ចនៅប្រទេសថៃ ហើយបានព្រមានមិនឲ្យមានកិច្ចចរចាសន្តិភាពជាមួយប្រទេសវៀតណាមដោយត្រូវបានឮលួចលៀងថាបានប្រាប់ប្រទេសអាស៊ានឲ្យ“ប្រុងប្រយ័ត្នក្នុងការធ្វើសំណើរូបមន្តសន្តិភាពសម្រាប់ប្រទេសកម្ពុជាពីព្រោះនៅថ្ងៃណាមួយវៀតណាមនឹងទទួលយកនូវសំណើទាំងនោះមិនខាន” ។

រដ្ឋការលោក ប៊ូស ក៏បានប្រឆាំងជំទាស់នឹងប្រទេសថៃ ជាពិសេសក្រោយពីវត្តមានរបស់នាយករដ្ឋមន្ត្រីថៃដែលត្រូវបានជ្រើសតាំងតាមលទ្ធិប្រជាធិបតេយ្យកាលពីឆ្នាំ១៩៨៨ ។ នយោបាយថ្មីរបស់ថៃដែលប្រែក្លាយឥណ្ឌូចិនឲ្យទៅជាទីផ្សារជាជាងសមរភូមិក្តៅនិងភ្ជាប់ជាទំនាក់ទំនងជាមួយនឹងវៀតណាមនិងកម្ពុជាត្រូវបានមើលឃើញថាជាជំហរបរាជ័យរបស់ប្រទេសចិននិងសហរដ្ឋអាមេរិក ។ **(នៅមានត)**

**វ៉ែន ឃៀនិន**

## ពាក្យស្លោកខ្មែរក្រហម

**◆គោរពអង្គការវិន័យរបស់សម្ព័ន្ធយុវកកដោយគ្មានលក្ខខណ្ឌ និងដោយភ្ជាក់រឭកខ្ពស់។**

*(ដកស្រង់ចេញពីសៀវភៅលេខ២៦ៈ កណហ)*

**◆ការពារជំងឺជាការសំខាន់។**

*(ដកស្រង់ចេញពីសៀវភៅលេខ១៨៨ៈ កណហ)*




# ភាពរួចទោសដែលគ្រប់គ្រងដោយអំណាច: ករណី អៀង សារី

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងទៅកាន់ទីភ្នាក់ងារសារពត៌មានក្យូដូថា មិនគួរនាំអតីតឧបនាយករដ្ឋមន្ត្រីខ្មែរក្រហមទទួលបន្ទុកកិច្ចការបរទេសគឺ អៀង សារី ទៅកាត់ទោសអំពីបទចោទប្រកាន់ថាបានប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥-៧៩ឡើយ ។

សម្តេចនាយករដ្ឋមន្ត្រីកម្ពុជាបាននិយាយទៀតថា អៀង សារី បានរួមចំណែកយ៉ាងធំធេងក្នុងការបង្រួបបង្រួមជាតិដោយដឹកនាំអតីតកងកម្លាំងខ្មែរក្រហមប្រមាណ៧០ភាគរយឲ្យចូលមកក្នុងភាគីខាងរដ្ឋាភិបាលដែលនាំដល់ការលុបបំបាត់ទាំងស្រុងនូវអង្គការចាត់តាំងផ្នែកយោធាខ្មែរក្រហម ។

សម្តេចនាយករដ្ឋមន្ត្រីបានបន្ថែមទៀតថា អៀង សារី បានបង្ហាញពីចេតនាល្អ ដោយធ្វើឲ្យខ្មែរក្រហមទម្លាក់អាវុធ ហើយថា ព្រះមហាក្សត្របានឡាយព្រះហស្តលេខានិងលើកលែងទោសដល់ អៀង សារី ដែលជាមនុស្សម្នាក់បានដឹកនាំពួកខុទ្ទាមឲ្យចុះចូលធ្វើការផ្តាច់ខ្លួន ។ ការនិយាយបែបនេះ គឺយោងទៅតាមសេចក្តីលើកលែងទោសក្នុងខែកញ្ញា ឆ្នាំ១៩៩៦ដល់ អៀង សារី ដែលប្រទានឲ្យដោយព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ និងដោយមានការស្នើសុំពីសហនាយករដ្ឋមន្ត្រីទាំងពីរនៃរាជរដ្ឋាភិបាលកម្ពុជា ។

អៀង សារី និងមេដឹកនាំខ្មែរក្រហមឯទៀតត្រូវបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខម្តងរួចមក ហើយនៅឆ្នាំ១៩៧៩ ដោយតុលាការមួយដែលរៀបចំឡើងនៅក្នុងអំឡុងពេលដែលប្រទេសកម្ពុជាត្រូវបានត្រួតត្រាដោយកងទ័ពវៀតណាម ។ តុលាការនោះបានធ្វើការជាមួយចៅក្រមមួយចំនួនដែលមកពីប្រទេសគុយបានិងមកពីបណ្តាប្រទេសដទៃទៀតដែលមានប្រព័ន្ធ

តុលាការមួយដែលមិនឯករាជ្យទាល់តែសោះ ។ អ្វីដែលធ្ងន់ធ្ងរជាងនេះទៀតនោះគឺថាផ្នែកខ្លះនៃទម្រង់ច្បាប់ស្ថិតនៅក្រោមការគ្រប់គ្រងដោយគណបក្សកាន់អំណាចនៅក្នុងរដ្ឋនោះតែម្តង ។

សេចក្តីថ្លែងជាបន្តបន្ទាប់របស់សម្តេចនាយករដ្ឋមន្ត្រីដែលថា អៀង សារី គួរតែត្រូវបាននាំខ្លួនយកទៅកាត់ទោស និងប្រតិកម្មរបស់សម្តេចនាយករដ្ឋមន្ត្រីដដែលថា "មិនគួរមានការកាត់ទោសពីរលើកទៅលើបទឧក្រិដ្ឋកម្មដដែលៗ" បាននាំរូបខ្ញុំឲ្យមានជំនឿថានឹងមិនមានឯករាជ្យទាល់តែសោះនៅក្នុងដំណើរការកាត់ទោសក្រុមមេដឹកនាំខ្មែរក្រហមឲ្យទទួលខុសត្រូវលើការសម្លាប់រង្គាលដែលបានកើតឡើងនៅកម្ពុជារវាងឆ្នាំ ១៩៧៥-៧៩ ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចំណាយពេលវេលារាប់ឆ្នាំដើម្បីប្រមែប្រមូលរាល់ភ័ស្តុតាងសម្រាប់តុលាការចុងក្រោយមួយដើម្បីកាត់ទោសខ្មែរក្រហមបាននិយាយថា "យើងមានពត៌មានគ្រប់គ្រាន់ជូនដល់ព្រះរាជអាជ្ញាក្នុងការបង្កើតជារឿងក្តីប្រឆាំងនឹង អៀង សារី" ។

នៅទ្វីបអឺរ៉ុប ស្ត្រីមេម៉ាយដែលមានប្តីជាអតីតអ្នកការទូតកម្ពុជាត្រូវបានហៅឲ្យត្រឡប់ចូលស្រុកវិញនៅខែធ្នូ ឆ្នាំ ១៩៧៥ តាមរយៈសារទូរលេខមួយច្បាប់ដែលចុះហត្ថលេខាដោយ អៀង សារី ផ្ទាល់ដៃ បានចោទប្រកាន់ អៀង សារី ពីបទបានធ្វើឲ្យបាត់បង់អាយុជីវិតប្តីនិងកូនៗរបស់គាត់ ។ ស្ទើរតែគ្រប់ករណីទាំងអស់ទាំងឯកអគ្គរដ្ឋទូត ទាំងអ្នកការទូតដែលមកពីកន្លែងផ្សេងៗពីគ្នា សុទ្ធតែត្រូវបានបញ្ជូនឲ្យទៅធ្វើការអប់រំកសាងខ្លួនបន្ទាប់ពីបានមកដល់ភ្នំពេញ ។ ជាការពិតណាស់ថា"អប់រំកសាងខ្លួន" គឺជាពាក្យរបស់ខ្មែរក្រហមប្រើសម្រាប់កុំឲ្យអាក្រក់ស្តាប់ពេកក្នុងការជំនួសពាក្យ"សម្លាប់" ។

មានមតិជាច្រើនដែលបានចោទសួរខ្ញុំថា ហេតុអ្វីក៏ព្រះមហាក្សត្រទ្រង់យល់ព្រមនឹងសំណើដែលធ្វើឡើងដោយសម្តេចក្រុមព្រះនរោត្តម រណប្ញទ្ធិ ជានាយករដ្ឋមន្ត្រីទី១ រួមជាមួយសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រទានការលើកលែងទោសដល់ អៀង សារី ដែលជាជនល្បីអសោចខាងសម្លាប់មនុស្សបែបនេះទៅវិញ ។

ជាដំបូងយើងគួរតែនិយាយថាតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ព្រះមហាក្សត្រទ្រង់មានព្រះរាជអំណាចក្នុងការប្រទានការលើកលែងទោសដោយឆន្ទៈរបស់ព្រះអង្គបន្ទាប់ពីបានទទួលរួចហើយនូវសំណើសុំរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ។

ខ្ញុំសូមរំឭកឡើងវិញនូវព្រឹត្តិការណ៍ជុំវិញការលើកលែងទោសដល់ អៀង សារី កាលពីពេលកន្លងទៅក្នុងខែកញ្ញា ឆ្នាំ១៩៩៦÷

១) នៅថ្ងៃសៅរ៍ ទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ សហនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចក្រុមព្រះនរោត្តម រណប្ញទ្ធិ និងសម្តេច ហ៊ុន សែន បានធ្វើសំណើមួយសុំចូលគាល់ព្រះមហាក្សត្រនៅឯដំណាក់របស់ព្រះអង្គដែលនៅទីនោះសហនាយករដ្ឋមន្ត្រីទាំងពីរបានដាក់ថ្វាយព្រះមហាក្សត្រនូវពង្រាងព្រះរាជក្រឹត្យដែលរៀបចំហើយជាស្រេចអំពីការលើកលែងទោសដល់ អៀង សារី ។ ព្រះមហាក្សត្រទ្រង់ក៏ឡាយព្រះហស្ត-លេខាទៅ ក៏ប៉ុន្តែបានប្រទានព្រះរាជយោបល់ដល់សហនាយករដ្ឋមន្ត្រីទាំងពីរថាគួរតែត្រូវឲ្យមានការទទួលបានការគាំទ្រនូវសម្លេងពីរភាគបីពីសភាជាតិដែលជាតំណាងរបស់ប្រជារាស្ត្រកម្ពុជាទាំងមូលមុននឹងចេញព្រះរាជក្រឹត្យជាសាធារណៈនិងដាក់ឲ្យអនុវត្ត ។

២) ដោយសារតែសហនាយករដ្ឋមន្ត្រីទាំងពីររូបប្រឆាំងនឹងការពិភាក្សាវែកញែកនៅក្នុងសភាជាតិលើបញ្ហានេះទើបព្រះមហាក្សត្ររំឭកហើយរំឭកទៀតមុននឹងភៀវរបស់ព្រះអង្គចាកចេញទៅថា ព្រះរាជក្រឹត្យនេះគួរតែត្រូវមានការគាំទ្រជាលាយលក្ខណ៍អក្សរចំនួនពីរភាគបីពីសភាជាតិ ។ ពេលនោះព្រះអង្គបន្ថែមថា លិខិតនីមួយៗដែលចេញដោយសមាជិកសភាគ្រាន់តែផ្ញើថ្វាយទៅព្រះអង្គគឺជាការគ្រប់គ្រាន់ទៅហើយ ។ សហនាយករដ្ឋមន្ត្រីទាំងពីររូបបានធានានៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រជាថ្មីវការថាអាចទទួលយកបានយ៉ាងហោចណាស់ក៏ហត្ថលេខាចំនួន៨០ដែរពីសមាជិកសភា ក្នុងការយល់ព្រមទៅលើការលើកលែងទោសដែលទាំងអស់នេះដែលជាការបំពេញបានទៅនឹងលក្ខខណ្ឌរបស់ព្រះមហាក្សត្រពីខាងដើម ។

៣) ដើម្បីសម្តែងពីបំណងល្អរបស់ខ្លួន សម្តេចនាយករដ្ឋមន្ត្រី

បានសន្យានៅចំពោះព្រះភក្ត្រព្រះអង្គនិងព្រះរាជបល្ល័ង្កថា សម្តេចនឹងសហការយ៉ាងជិតស្និទ្ធជាមួយសម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ ក្នុងការដឹកនាំប្រទេស ហើយថាបញ្ហាខ្វែងគំនិតគ្នាទាំងអម្បាលម៉ាននឹងត្រូវបញ្ចប់តែត្រឹមនេះ ។ ព្រះមហាក្សត្រសព្វព្រះរាជហឫទ័យណាស់ចំពោះការសន្យានេះដោយមានបន្ទូលថា ប្រសិនបើសហនាយករដ្ឋមន្ត្រីទាំងពីរនៅមានការខ្វែងគំនិតគ្នាដូចក្នុងករណីចាប់តាំងពីខែមីនា ឆ្នាំ១៩៩៦ ការចំណេញបានត្រឹមតែទៅលើសត្រូវរបស់កម្ពុជាតែប៉ុណ្ណឹង ។

៤) នៅក្នុងល្ងាចថ្ងៃដដែលក្នុងពិធីគម្រប់ខួបអភិសេករបស់ព្រះករុណា សម្តេចក្រុមព្រះនរោត្តម រណប្ញទ្ធិ បានមានព្រះបន្ទូលប្រាប់ឯកអគ្គរដ្ឋទូតប្រទេសអាស៊ានដែលចូលរួមពិធីនោះអំពីការឡាយព្រហស្តលេខារបស់ព្រះមហាក្សត្រទៅលើព្រះរាជក្រឹត្យដែលនាំដល់ការធ្វើខុសនឹងសន្យាធ្វើឡើងចំពោះរាជានិងធ្វើឲ្យការលើកលែងទោសមានភាពជាសាធារណៈ ។




៥) រាជក្រឹត្យលើកលែងទោសដែលឡាយព្រះហស្តលេខាដោយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ បានផ្តល់ អៀង សារី រួចចាកផុតពីការកាត់ទោសប្រហារជីវិតដែលសម្រេចឡើងដោយតុលាការអន្តរជាតិក្នុងឆ្នាំ១៩៧៩ និងទទួលបានសិទ្ធិរួចផុតពីការចោទប្រកាន់ក្រោមច្បាប់ដាក់ខ្មែរក្រហមនៅក្រៅច្បាប់ឆ្នាំ១៩៩៤ទៀតផង ។ ក៏ប៉ុន្តែការរួចផុតខាងលើរបស់ អៀង សារី មិនមានន័យថា ទៅថ្ងៃមុខទៀត អៀង សារី មិនអាចត្រូវចោទប្រកាន់ដើម្បីកាត់ទោសពីបទឧក្រិដ្ឋកម្មសង្គ្រាមឬបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ ។ ជីវិតប្រជាជនកម្ពុជារាប់ពាន់នាក់បានស្លាប់នៅក្រោមតួនាទីរបស់ អៀង សារី កាលក្នុងជំនាន់ខ្លួនកាន់អំណាច ។

ជាច្រើនឆ្នាំមកហើយចាប់តាំងពីមានការលើកលែងទោស អៀង សារី បានអះអាងថា ខ្លួនគាត់ជាមនុស្សគ្មានទោសពៃរ៍អ្វីទាំងអស់នៅក្នុងបទឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់លើរូបគាត់ ។ អៀង សារី អះអាងដោយទទូចថា ស្ទើរតែរាល់សេចក្តីសម្រេចចិត្តទាំងអស់គឺត្រូវធ្វើឡើងដោយអ្វីដែលហៅថា "ក្រុមមនុស្សបួននាក់" ដែលរួមមាន ប៉ុល ពត (ស្លាប់) នួន ជា (រស់នៅប៉ៃលិន) ជាបងធំទី២ពិតៗ សុន សេន និងប្រពន្ធរបស់ សុន សេន ឈ្មោះ យុន យ៉ាត (អ្នកទាំងពីរនេះត្រូវបានធ្វើឃាតក្នុងខែមិថុនា ឆ្នាំ១៩៩៧) ។

អៀង សារី បានអះអាងទៀតថា ក្រោយពេលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងក្នុងខែមេសា ឆ្នាំ១៩៧៥ ការដែលថាមិនមានការប្រជុំគណៈរដ្ឋមន្ត្រីណាមួយនោះមិនមែនជាការពិតទេពីព្រោះកំណត់ហេតុនៃការប្រជុំគណៈរដ្ឋមន្ត្រីភាគច្រើនមានស្រាប់ ហើយ អៀង សារី ខ្លួនឯងបានចូលរួមការប្រជុំគណៈរដ្ឋមន្ត្រីទាំងនោះទៀតផង ។

នៅក្នុងសៀវភៅទិនានុប្បវត្តិរបស់ព្រះករុណាអំពីសម័យកាលនោះដែលខ្ញុំទើបតែបានបកប្រែចប់ ហើយដែលនឹងត្រូវបោះពុម្ពផ្សាយនៅឯទីក្រុងបាងកកមុនដំណាច់ឆ្នាំនេះ ព្រះករុណាបានមានព្រះរាជបន្ទូលប្រាប់ថា ព្រះករុណាត្រូវបានរៀបចំឲ្យចូលរួមប្រជុំជាមួយ ប៉ុល ពត នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ នៅឯសាលប្រជុំរដ្ឋាភិបាល ដែលនៅទីនោះមានការទូលថ្វាយដំណឹងដល់ព្រះករុណាអំពីការឈ្លានពានរបស់វៀតណាមមក

លើប្រទេសកម្ពុជានិងស្នើសុំឲ្យព្រះករុណាជួយជជែកនៅឯក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក ដើម្បីការពារប្រយោជន៍ជាតិនិងប្រជារាស្ត្ររបស់ព្រះករុណា ។ ព្រះករុណាក៏បានយល់ព្រមតាមសំណើនោះ ។

ប៉ុល ពត បានទូលថ្វាយព្រះករុណាថាក្រុម ញាតិវង្សានុវង្សរបស់ព្រះករុណាទាំងអស់នឹងអាចចាកចេញពីប្រទេសនៅល្ងាចថ្ងៃដដែលនោះតាមយន្តហោះពិសេសរបស់ចិន ក៏ប៉ុន្តែ អៀង សារី បានចូលជ្រៀតជ្រែកដោយនិយាយថា មានតែព្រះមហាក្សត្រតែមួយអង្គឯងនិងអគ្គមហេសីតែប៉ុណ្ណោះដែលអាចចាកចេញបាន ចំណែកញាតិវង្សានុវង្សទាំងប៉ុន្មានគួរតែបន្តនៅភ្នំពេញដដែលចុះ ។ អៀង សារី ចង់ទុកញាតិវង្សានុវង្សរបស់ព្រះករុណានៅក្នុងប្រទេសដើម្បីឲ្យមានការធានាដោយច្បាស់ថាព្រះមហាក្សត្រទ្រង់នឹងមិនមានបន្ទូលឬធ្វើអ្វីដែលនាំឲ្យមានការខូចប្រយោជន៍ដល់របបរបស់ខ្លួនទេ ។ ផ្ទុយទៅវិញ ប៉ុល ពត ជម្នះលើ អៀង សារី ហើយគ្រួសាររបស់ព្រះករុណាបានយាងចាកចេញទៅក្រៅនៅល្ងាចថ្ងៃនោះតែម្តង ។

នៅក្នុងសន្និសីទសារពត៌មានកាលថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៩៦ អៀង សារី បានឆ្លើយតបទៅនឹងសំណួររបស់អ្នកការសែតបរទេសថា "ខ្លួនគាត់ពុំមានវិប្បដិសារីឡើយដោយសារតែក្នុងតួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់អត់មានបានធ្វើអីសោះទាក់ទងនឹងបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" ។ ប្រហែលជាបន្ទាប់ក្រោយមកទៀត អៀង សារី ប្រាកដជានិយាយដូច ណាស៊ីនៅឯតុលាការ នូរិមប៊ឹក ហើយថា រូបគាត់ធ្វើតាមតែបញ្ជាតែប៉ុណ្ណោះ ។




ខ្ញុំសូមផ្តល់ជាយោបល់ថា សម្តេចនាយករដ្ឋមន្ត្រីព្រមទាំងរដ្ឋាភិបាលកម្ពុជាមិនគួរណាយកខ្លួនធ្វើជារបងនៅក្រោមផ្លាក "បង្រួបបង្រួមជាតិ" ដើម្បីការពារជនធ្លាប់សម្លាប់មនុស្សដែលឥឡូវនេះកំពុងមានជីវភាពរស់នៅយ៉ាងសុខស្រួលនៅប៉ៃលិននិងនៅភ្នំពេញក្នុងខណៈដែលជនរងគ្រោះជាច្រើននាក់បង្ខំចិត្តរស់នៅកៀកកិតជាមួយនឹងអ្នកដែលបានប្រព្រឹត្តអំពើរំលោភបំពានមកលើខ្លួន ។ អ្នកនយោបាយណាម្នាក់ដែលធ្វើរបៀបនេះនឹងមិនអាចទទួលបាននូវទំនុកចិត្តឲ្យដឹកនាំជាតិរបស់ខ្លួនឆ្ពោះទៅរកអនាគតមួយដែលមានសន្តិភាពនិងប្រជាធិបតេយ្យឡើយ ។ ដូចជាអ្នកទាំងឡាយដែលប្រៀបប្រដូចការអនុវត្តច្បាប់ព្រហ្មទណ្ឌទៅនឹងការសងសឹកអ៊ីចឹង គឺបង្ហាញថា អ្នកទាំងនោះមិនគោរពច្បាប់ឬមិនគោរពសិទ្ធិមនុស្ស ។

ប្រសិនបើរដ្ឋាភិបាលបែបនេះបោះបង់ចោលមិនរវីរវល់ការទទួលខុសត្រូវរបស់ខ្លួនក្នុងការដាក់ទណ្ឌកម្មទៅលើការរំលោភសិទ្ធិមនុស្សដូចដែលរាជរដ្ឋាភិបាលកម្ពុជាហាក់ដូចជាកំពុងធ្វើនេះ សហគមន៍អន្តរជាតិប្រាកដជាឈានជើងចូលមកដោះស្រាយមិនខាន ។

ខ្ញុំយល់ឃើញថា បញ្ហានេះគឺជារឿងមួយដ៏សែនស្មុគស្មាញពិបាកដោះស្រាយ ក៏ប៉ុន្តែខ្ញុំសូមស្នើយោបល់ថា សម្តេចនាយករដ្ឋមន្ត្រីនឹងទទួលបាននូវការគោរពកោតសរសើរពីប្រជាពលរដ្ឋនិងពីសហគមន៍អន្តរជាតិ ប្រសិនបើសម្តេចផ្តល់ចម្លើយដ៏ត្រឹមត្រូវដល់ប្រជាពលរដ្ឋរបស់សម្តេចដែលស្រេកឃ្លានចង់បានយុត្តិធម៌និងប្រសិនបើសម្តេចឈប់ព្យាយាមការពារជនដែលមិនគួរឲ្យការពារតទៅទៀត ។

**ហ្វូលីយ៉ូ ហេលវ្រេស**

# ជនជាតិវៀតណាមស្វែងរកសាច់ញាតិដែលបាន បាត់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

សមាជិកគ្រួសារវៀតណាមចំនួន១៤៨នាក់ត្រូវបានអះអាងថាបានបាត់ខ្លួននៅក្នុងប្រទេសកម្ពុជា នេះបើយោងតាមញត្តិចំនួន៣០ច្បាប់ផ្ញើឡើងនៅប្រទេសវៀតណាម ហើយដែលផ្ញើមកពីសាច់ញាតិរបស់ជនរងគ្រោះទាំងនោះកាលពីឆ្នាំ១៩៧៦ ។ ញត្តិទាំងអស់ដែលមានចុះកាលបរិច្ឆេទពីខែមិថុនាដល់ខែតុលា ឆ្នាំ១៩៧៦ សរសេរដោយដៃនិងខ្លះវាយអង្គុលីលេខជាភាសាវៀតណាម ។ នៅក្នុងញត្តិមានដាក់អាសយដ្ឋានរបស់អ្នកប្តឹងនៅ ប្រទេសវៀតណាមនិងញាតិរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ។ ក្នុងចំណោមអ្នកផ្ញើញត្តិទាំង៣០ច្បាប់មាន១១នាក់រស់នៅទីក្រុងហូជីមិញ ១០នាក់រស់នៅខេត្តដុងថាប់ ២នាក់រស់នៅអាំងជាំង ១នាក់រស់នៅហូយ៉ាង ១នាក់រស់នៅត័ងមីង រីឯអ្នកក្រៅពីនេះមិនបានបញ្ជាក់ពីអាសយដ្ឋានពិតប្រាកដឡើយ ។ ក្នុងចំណោមសាច់ញាតិទាំង១៤៨នាក់ដែលបាត់ខ្លួន មាន៥១នាក់រស់នៅទីក្រុងភ្នំពេញ ៣៣នាក់រស់នៅខេត្តកំពង់ឆ្នាំង ១១នាក់រស់នៅខេត្តកណ្តាល ១០នាក់រស់នៅខេត្តសៀមរាប ៧នាក់រស់នៅខេត្តតាកែវ ៦នាក់រស់នៅខេត្តកំពង់ចាម ៤នាក់រស់នៅខេត្តបាត់ដំបង ១នាក់រស់នៅខេត្តកំពង់ស្ពឺ សល់ពីនោះមិនបានបញ្ជាក់អាសយដ្ឋានច្បាស់លាស់ពិតប្រាកដ ។


ង៉ូ ធីស្រី


ង៉ូ ធីពៅ

ក្នុងចំណោមញត្តិទាំង៣០ច្បាប់ មានញត្តិចំនួន២ច្បាប់មានភ្ជាប់ជាមួយរូបថតអ្នកដែលបាត់ខ្លួន ។ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៧៦ ង៉ូ ធីទៀន បានសរសេរសំបុត្រស៊ើបសួរពីពត៌មានទាក់ទងនឹងជោគវាសនារបស់ប្តីនិងកូនស្រីគាត់ដែលបានបាត់ខ្លួននៅក្នុងប្រទេសកម្ពុជា ។

ង៉ូ ធី ទៀន កាលនោះមានអាយុ៤៣ឆ្នាំព្រមទាំងកូនប្រុស៣នាក់បានវិលត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញនិងបានរស់នៅផ្ទះលេខ៥៣៩ វិថី ២០ផ្លូវចូលហុងដោ ទីក្រុងហូជីមិញ ។ ប្តីរបស់ ធីទៀន ឈ្មោះចុក ប៉ាក មានកូនស្រីឈ្មោះ ង៉ូ ធី ស្រី និង ង៉ូ ធី ពៅ ដែលរស់នៅ ក្នុងភូមិដូនទូត ឃុំញាននៀ៉ន ស្រុកត្រាំកក់ ខេត្តតាកែវ ។ តាមរយៈសំបុត្រនេះ ធី ទៀន សុំឲ្យប្តីព្រមទាំងកូនស្រីទាំងពីរនាក់វិលត្រឡប់មករស់នៅជួបជុំគ្រួសារនៅប្រទេសវៀតណាមវិញ ។

**សឹម សុរិយ៉ា**

# យាយ «ជី»

កាលពីជំនាន់ខ្មែរក្រហម អ៊ឹស្រី ឆាយ រិន ត្រូវបានទ័ពខ្មែរក្រហមជម្លៀសទៅដាក់ឲ្យរស់នៅកណ្តាលព្រៃល្បាក់មួយកន្លែងហៅថាពោធិពេញ ដែលស្ថិតក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។ តំបន់នេះគឺជាតំបន់មួយនៅដាច់ស្រយាលពីថ្នល់ជាតិ ពោលគឺមិនដែលឃើញមានរថយន្តណាទៅដល់ទេ ។ ប្រសិនដើរពីថ្នល់ជាតិទៅតាមផ្លូវលំត្រូវប្រើពេលអស់យ៉ាងតិចក៏កន្លះថ្ងៃដែរ ។ ការរស់នៅៗទីនោះ អ៊ឹស្រីត្រូវបានខ្មែរក្រហមចាត់ឲ្យធ្វើជីខ្មោចមនុស្សនិងជីលាមកមនុស្សដែលក្នុងនោះសមាជិកក្រុមជីរបស់អ៊ឹស្រីមានចំនួន៤០នាក់ ។ អ៊ឹស្រីតែងតែត្រូវបានអ្នកភូមិហៅថា«**យាយជី**»ព្រោះគាត់ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាប្រធានក្រុមជី ។ យាយជីបានធ្វើការក្នុងស្ថានភាពនេះយ៉ាងលំបាកណាស់ដោយបានខិតខំតស៊ូរស់ធ្មេចភ្នែកបិទច្រមុះធ្វើកិច្ចការដ៏ខ្ពើមរអើមបំផុតដើម្បីធ្វើយ៉ាងណាឲ្យក្រុមគ្រួសាររបស់គាត់អាចគេចផុតពីការសម្លាប់ពីសំណាក់ខ្មែរក្រហម ។


ឆាយ រិន

ពេលទៅដល់ទីនោះភ្លាម យាយជីបានបន់ស្រន់ដល់ព្រះឲ្យជួយថែរក្សាគ្រួសាររបស់គាត់ទាំងសម្រក់ទឹកភ្នែកព្រោះតែនឹកអាណិតខ្លួនខ្លាំងពេក ។ ទ័ពខ្មែរក្រហមក្មេងៗមានអាយុប្រមាណជាង១០ឆ្នាំដែលមានស្ពាយកាំភ្លើងនៅនឹងស្មាផងនោះបាននិយាយថា «ម៉ែឯងយំធ្វើអី គេយកម៉ែឯងមកឲ្យរស់ហើយតើ គេមិនទុកម៉ែឯងឲ្យស៊ីថ្មនៅភ្នំពេញទេ» ហើយយាយជីបានតបវិញថា «កូនអ្ហា៎ សុទ្ធតែដើមល្ពាក់ តើយកម៉ែមកឲ្យស៊ីស្អី ស៊ីស្លឹកឈើហ្នឹងអ្វី?» ភ្លាមនោះទ័ពខ្មែរក្រហមម្នាក់បានយកកាំភ្លើងភ្ជង់កគាត់ដោយគំរាមថា «ម៉ែឯងឃោរឃៅណាស់ ហ៊ានប្រឆាំងនឹងអង្គការផង» ។ យាយជីបានអង្វរទ័ពខ្មែរក្រហមនោះវិញថា «ម៉ែអត់ហ៊ានប្រឆាំងនឹងអង្គការទេកូន» ។ ព្រោះតែការអង្វរករយ៉ាងដូច្នេះទើបគាត់មិនត្រូវបានពួកខ្មែរក្រហមសម្លាប់ក្នុងគ្រានោះ ។

យាយជីបានបញ្ជាក់ថា «រស់នៅពោធិពេញបាន១ឆ្នាំ ស្រាប់តែទឹកជន់លិចពេញដីទាំងអស់ ។ ពេលដែលមានទឹកជំនន់ជន់លិចពួកខ្មែរក្រហមបានជម្លៀសប្រជាជនឲ្យទៅនៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។ «ការរស់នៅទីនោះលំបាកវេទនាខ្លាំងណាស់ ដូចជាការហូបចុកគឺបបរមួយខ្ទះដាក់អង្ករតែបួនកំប៉ុងទេ ហើយហាន់ត្រកួនដាក់ទាំងឫសៗ ។ ប្រជាជនចេះតែស្លាប់ជាបន្តបន្ទាប់ ខ្លះស្លាប់ដោយជំងឺហើម ខ្លះស្លាប់ដោយអត់អីហូប ខ្លះឃ្លានពេកបេះស្លឹកឈើហូបក៏ពុលស្លាប់ទៅ ហើយប្រជាជនភាគច្រើនស្លាប់ដោយត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល ។ កន្លែងដែលខ្មែរក្រហមយកប្រជាជនទៅសម្លាប់គឺស្ថិតនៅពោធិពេញ ។»

តាមការបញ្ជាក់របស់ យាយជី បានឲ្យដឹងទៀតថា នៅស្រុកភ្នំស្រុកមានការដ្ឋានមួយដែលពួកខ្មែរក្រហមបង្ខំឲ្យប្រជាជនធ្វើជីខ្មោចមនុស្សនិងជីលាមកមនុស្ស ។ គាត់ត្រូវបានពួកខ្មែរក្រហមចាត់ឲ្យធ្វើជី ពោលគឺដើរគាស់ខ្មោចមនុស្សយកមកធ្វើជី ។ ទាក់ទងនឹងការធ្វើជីនេះយាយជីបានរៀបរាប់ថា ពេលចេញទៅធ្វើជីម្តងៗក្រុមជីរបស់គាត់បានដើរគាស់ខ្មោចមនុស្សបកស្បែកនិងប្រឡេះសាច់ចេញយកតែឆ្អឹងមកដុតធ្វើជីប៉ុណ្ណោះ ។ រៀងរាល់ថ្ងៃពួកខ្មែរក្រហមបានឲ្យគាត់ដើរគាស់ខ្មោចមនុស្សនិងកើបលាមកមនុស្សយកមកធ្វើជី ។

យាយជីបានត្អូញត្អែរពីការលំបាករបស់គាត់ថា«មុនដំបូងពិបាកណាស់ ខ្មោចធុំក្លិនឃ្នើសៗ ប៉ុន្តែដល់យូរទៅអត់ស្អុយទេហើយ ពេលគាស់ខ្មោចភ្លាមអត់កកាយទេព្រោះស្អុយពេក ។ ទោះជាខ្ពើមរអើមយ៉ាងណាក៏មិនហ៊ានប្រកែកដែរ ព្រោះពួកខ្មែរក្រហមនៅចាំត្រួតពិនិត្យមើល បើមិនធ្វើមិនបានទេ ។ ការធ្វើជីរបៀបនេះត្រូវធ្វើរាល់ថ្ងៃអស់រយៈពេលជាង១ឆ្នាំ ។ ពេលចេញទៅធ្វើជីម្តងៗមានខ្មែរក្រហមបួននាក់ស្ពាយកាំភ្លើងដើរទៅតាមជាមួយដែរ ។

យាយជីបានបញ្ជាក់បន្ថែមថា «គ្រាដំបូងពេលដែលខ្ញុំចូលមកធ្វើជីខ្មោច ខ្ញុំបានឃើញមនុស្សស្លាប់អណោចអធ័មខ្លាំងណាស់ ។ សាកសពមានតាំងពីព្រះសង្ឃដែលត្រូវបានពួកខ្មែរក្រហមចងកភ្ជាប់គ្នាពីរ-បីអង្គសម្លាប់ដាក់ក្នុងរណ្តៅ ។ មនុស្ស

ត្រូវបានសម្លាប់គរជើងលើគ្នារកអ្វីពិពណ៌នាមិនបានឡើយ ។ ការសម្លាប់នេះធ្វើឡើងនៅឆ្នាំ១៩៧៧ គឺសម្លាប់ខ្លាំងមែនទែន អ្នកដែលចេញពីនិរតីទៅត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ទាំងអស់ ។ អ្នកភូមិក៏ត្រូវសម្លាប់ដែរ គឺសម្លាប់ដាក់ក្នុងរណ្តៅធំៗ ជាងរណ្តៅនៅជើងឯកទៅទៀត ។ បើកាលណាមានបញ្ហាសតិអារម្មណ៍អ្វីមួយត្រូវតែយកទៅសម្លាប់មិនទុកទេ» ។

យាយជីបានបញ្ជាក់ទៀតថា «បើអ្នកណាសកម្មហៅភ្លាមរត់ទៅភ្លាមដូចខ្ញុំ អ្នកហ្នឹងរស់ហើយ ។ ស្ទូក៏ខ្ញុំធ្វើដែរ មានពេលខ្លះពួកក្រហមបានហៅខ្ញុំទៅកោសខ្យល់ឲ្យវា ខ្ញុំមិនហ៊ានប្រកែកទេ ធ្វើម៉េចឲ្យតែបានរស់» ។ «នៅក្នុងឆ្នាំ១៩៧៨ ព្រឹត្តិការណ៍ដែលសំខាន់គឺមានការសម្លាប់មនុស្សយ៉ាងខ្លាំងក្លាមែនទែនទាំងអ្នកថ្មី ទាំងអ្នកចាស់ ។ គ្រួសារដែលនៅសេសសល់មានតិចតួចណាស់ ។ ជាក់ស្តែងដូចគ្រួសារអ្នកធ្វើជីមានចំនួន៤០នាក់ ក្នុងនោះអ្នកដែលនៅរស់មានចំនួនមិនដល់ពាក់កណ្តាលផងនៅពេលដែលត្រឡប់មកវិញ ។ អ្នកទាំងនោះសុទ្ធតែមានជំងឺហើម ព្រោះពួកខ្មែរក្រហមមិនបានផ្តល់ឲ្យរបបហូបចុកគ្រប់គ្រាន់ឡើយ ហើយគ្រួសាររបស់ខ្ញុំគឺពួកខ្មែរក្រហមចង់យកទៅសម្លាប់ជាងគេ ពីព្រោះពួកវាយល់ថាជាអ្នកចេះដឹង ដោយសារមានតែអ្នកដែលស្អប់ខ្ញុំបានរាយការណ៍ថាខ្ញុំធ្លាប់ធ្វើការឲ្យអាមេរិកកាំង» ។ ការពិត យាយជី គ្រាន់តែជាបរិស័ទម្នាក់នៃគ្រិស្តសាសនាប៉ុណ្ណោះ ។

យាយជីមានការឈឺចាប់បំផុតនៅពេលឃើញបងប្អូនដែលនៅជិតខ្លួនត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ចោល ព្រោះខ្មែរក្រហមបានយកលេសថា«អង្គការត្រូវការឲ្យទៅរៀនសូត្រ» ។ កូនក្មួយរបស់យាយជីត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលអស់ចំនួន២៦នាក់ ហើយបងរបស់គាត់ប៉ុន្មាននាក់ទៀតក៏ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅជុំវិញដើមកកោះមួយធំនៅពោធិពេញមុនពេលចេញទៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។ យាយជីបានមានប្រសាសន៍ថា «កាលណានឹកឃើញខ្លាំងមែនទែន គឺទឹកភ្នែក ឆ្អែតចិត្តណាស់» ។

បងស្រី ធូនី ដែលត្រូវជាកូនស្រីបង្កើតរបស់យាយជីក៏ជាជនរងគ្រោះម្នាក់ដែរ ។ កម្មាភិបាលខ្មែរក្រហមបានចាប់គាត់យកទៅសម្លាប់តាមបញ្ជារបស់ឈ្មោះ ឈិន ជាប្រធានសហករណ៍ដែលល្បីថាកាចសាហាវខ្លាំងណាស់ ។ ខ្មែរក្រហមបានវាយបងស្រី ធូនី សន្លប់បាត់ស្មារតីនៅមាត់រណ្តៅ ពេលនោះខ្មែរក្រហមស្មានតែគាត់ស្លាប់បាត់ទៅហើយព្រោះមានមនុស្សច្រើននាក់ទៀតដែលត្រូវសម្លាប់ក្នុងពេលជាមួយគ្នានោះ ។ ប៉ុន្តែការពិតគាត់មិនទាន់ស្លាប់ទេ ហើយមានជីវិតរស់រានរហូតដល់សព្វថ្ងៃនេះ ។ បងស្រី ធូនី មាននៅសល់ស្លាកស្នាមឈឺចាប់ពីរកន្លែងគឺមួយកន្លែងនៅក្រោមចង្កាខាងស្តាំនិងមួយកន្លែងទៀតនៅត្រង់ប្រអប់ជើងស្តាំ ។ ពេលដែលបង្ហាញស្លាកស្នាមទាំងនេះ បងស្រី ធូនី និយាយទាំងអួលដើមកថា «អូ...ស្លាកស្នាមប្រវត្តិមួយពាន់...ឈឺចាប់ណាស់...គឺថាបើនិយាយពីរឿង១០០១យប់ យើងនិយាយចប់ តែបើរឿងប្រវត្តិអាពតដែលយើងស្ថិតនៅក្នុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ យើងនិយាយអត់ចេះចប់ទេ ហើយជារឿងដែលយើងនិយាយទៅនឹកឃើញជានិច្ច...ទឹកភ្នែក...អ្ហឺ...វេទនាណាស់» ។

ពួកខ្មែរក្រហមយកបងស្រី ធូនី ទៅសម្លាប់ដោយបានចោទគាត់ថាជាកា.ហ្សេ.បេ(ភ្នាក់ងារស៊ើបការណ៍របស់សូវៀត) ព្រោះក្នុងពេលធ្វើពលកម្មគាត់បានតវ៉ាក្នុងន័យទូលាយដោយរបៀបនិយាយលេងបន្ទំមែន ប៉ុន្តែមិននិយាយនៅក្នុងអង្គប្រជុំទេ ។ ជាក់ស្តែងគាត់បាននិយាយថា «ប្រើម្ជីង១ងាប់ហើយ បបររាវកក្តួក ឲ្យកាប់ដីក្នុងម្នាក់៥ម៉ែត្រគូប តើទៅរួចទេ!?» គ្រាន់តែគាត់និយាយប៉ុណ្ណឹងខ្មែរក្រហមបានសួរភ្លាមថា «ម៉េច! មិត្តឯងជំទាស់នឹងអង្គការ? ស្គាល់អង្គការទេ?» គាត់ឆ្លើយដោយត្រង់វិញថា «ខ្ញុំឥតស្គាល់ទេអង្គការព្រោះមិនដឹងរូបរាងយ៉ាងម៉េច ខ្ញុំឃើញតែមិត្តស្លៀកខ្មៅពាក់មួកកន្ទឹបនិងបង់កក្រមាហ្នឹង ខ្ញុំមិនដឹងថាអង្គការមួយណាទេ» ។ បន្ទាប់មកខ្មែរក្រហមបាននិយាយទៀតថា«នេះសុទ្ធតែជាពួកអាបញ្ញវន្តលាក់ខ្លួន» ប៉ុន្តែបងស្រី ធូនី បានប្រាប់ទៅវិញថា «ខ្ញុំមិនស្គាល់ទេពាក្យបញ្ញវន្ត» ខ្មែរក្រហមសួរបញ្ជាក់ទៀតថា «មិត្តឯងនៅភ្នំពេញមែនទេ?» គាត់ឆ្លើយដោយកុហកថា «ខ្ញុំមិនមែនអ្នកនៅភ្នំពេញទេ ខ្ញុំនៅកៀនស្វាយ ខ្ញុំជាអ្នកលក់ដូរតាមចិញ្ចើមថ្នល់» ។ ក្រោយមកទៀតខ្មែរក្រហមបានគំរាមបងស្រីថា «ត្រូវតែយកទៅយកទៅកម្ទេចចោល» ។

បងស្រីតបវិញដោយឆ្លល់ថា “កម្មុចយ៉ាងម៉េច ក្រែងអង្គការថា បណ្តុះបណ្តាលមនុស្សឲ្យធ្វើពលកម្មដើម្បីមានការផាររធ្វើ ម៉េចក៏អីចឹង?” ហើយខ្មែរក្រហមបានតបថា “មិត្តឯងជំទាស់នឹងអង្គការ” ។ ខ្មែរក្រហមគ្រាន់និយាយប៉ុណ្ណឹង តែមិនបានធ្វើអ្វីមកលើគាត់ទេនាពេលនោះ ។ លុះមកដល់ម៉ោង១២យប់ក្នុងថ្ងៃដដែល នោះពួកខ្មែរក្រហមបាននាំយកគាត់ចេញពីជំរំប្រមូលផ្តុំយកទៅសម្លាប់ ។ ពួកខ្មែរក្រហមបានចាប់ចងបិទមុខនិងចងដៃ



ធូនី

របស់គាត់ទាំងពីរទៅក្រោយ ហើយបណ្តើរយកទៅសម្លាប់ ។ ពេលនោះ គាត់មិនដឹងថាពួកខ្មែរក្រហមយកគាត់ទៅកន្លែងណាទេ ព្រោះគាត់ត្រូវពួកខ្មែរក្រហមចងមុខជិតមើលអ្វីពុំឃើញឡើយ ។ មួយស្របក់ក្រោយមក បងស្រីត្រូវបានខ្មែរក្រហមវាយសន្លប់បាត់ស្មារតីទៅ ។

ក្រោយពីដឹងខ្លួនពីសន្លប់វិញបងស្រីប្រវេប្រវាស្រាយចំណងមុខនិងដៃចេញ ។ បន្ទាប់មកបងស្រីបានសម្រេចចិត្តរត់ចេញពីជំរំប្រមូលផ្តុំនេះដោយភ័យខ្លាចខ្មែរក្រហមស្គាល់មុខចាប់យកទៅសម្លាប់ម្តងទៀត ។ ពេលដែលគាត់ចេញទៅមានតែសំពត់ខ្មៅអាវខ្មៅនិងក្រមាក្រហមមួយជាប់ខ្លួនប៉ុណ្ណោះ ។ ពេលនោះហើយដែលគាត់ត្រូវបែកពីម្តាយទៅនៅកងចល័តក្នុងភូមិមួយនៃតំបន់ផ្សេង គឺនៅខាងស្ពានស្រែង ដែលស្ថិតនៅក្នុងទឹកដីស្រុកក្រឡាញ់ ខេត្តសៀមរាប ។

បងស្រី ធូនី បានបញ្ជាក់ថា ប្រជាជនដែលជម្លៀសទៅពីភ្នំពេញត្រូវបានសម្លាប់ចោលស្ទើរតែទាំងអស់ ព្រោះមនុស្សដែលជម្លៀសទៅរាប់សែននាក់ ពេលដែលត្រឡប់មកវិញនៅសល់ប្រមាណជាងមួយម៉ឺននាក់ទេ ។ នៅគោករំចេក ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ពួកខ្មែរក្រហមច្រើនយកមនុស្សទៅសម្លាប់ចោលនៅវាលស្រែ ព្រោះនៅទីនោះសម្បូរដោយវាលស្រែធំៗ ។ ចំណែកនៅប៉ោយត្រាចក៏ពួកខ្មែរក្រហមយកប្រជាជនទៅសម្លាប់ចោលរគាត់រគាយដែរគ្មានកប់ទេ ជាពិសេសនៅពេលជិតបែកឆ្នាំ ១៩៧៩ ។ ខ្មែរក្រហមបានកៀរយកអ្នកភ្នំពេញទៅបាញ់សម្លាប់ចោលជាបន្ទាន់ ។ បងស្រី ធូនី ធ្លាប់បានឃើញខ្មោចគរដូចភ្នំ ។ បងស្រីប្រាប់ថា គាត់មានការតក់ស្លុតខ្លាំងណាស់ពេលបានឃើញទិដ្ឋភាពបែបនោះ ។

យាយជី បានបញ្ជាក់ជាចុងក្រោយទៀតថា “ពេលបែកឆ្នាំ ១៩៧៩ នៅក្នុងទូទាំងសហករណ៍ អ្នកដែលនៅសល់ពីស្លាប់មានចំនួនតិចតួចណាស់ ។ យាយជីយល់ឃើញថា “ប្រសិនណាខ្មែរក្រហមកុំធ្វើបាប ហើយផ្គត់ផ្គង់ប្រជាជនគ្រប់សព្វទាំងអស់ វាជាការល្អបំផុត ។ កាលពីជំនាន់នោះបើអង្គការកុំលោតផ្លោះខ្លាំងពេក បើឲ្យតែមានហូបចុកគ្រប់គ្រាន់ ទោះជាធ្វើការរបៀបនេះក៏ប្រជាជនអត់មានស្លាប់ដែរ កុំឲ្យតែយកទៅសម្លាប់ចោល” ។

**ឌួង សុភារិទ្ធ**

## ពាក្យស្លោកខ្មែរក្រហម

**◆កិច្ចការអ្វីដែលសត្រូវប្រឆាំងយើងត្រូវតែគាំទ្រ បើសត្រូវគាំទ្រយើងត្រូវតែប្រឆាំង។**

**◆បដិវត្តន៍ជាសង្គ្រាមប្រជាជន មានតែការបំផុសប្រជាជនទេទើបអាចធ្វើសង្គ្រាមបាន។**

*(ដកស្រង់ចេញពីសៀវភៅសមមិត្តញុក)*



# ១៧ មេសា ជាដើមទំព័រសករាជនៃការនិរាសព្រាត់ប្រាស

ថ្ងៃទី១៧ ខែមេសា ត្រូវបានមតិជាច្រើនយល់ខុសៗគ្នាដោយយោលទៅតាមនិន្នាការរបស់ខ្លួន ។ មតិខ្លះយល់ថាថ្ងៃនោះគឺជាថ្ងៃបរាជ័យរបស់រដ្ឋាភិបាលលោកសេនាប្រមុខ លន់ ណុល ដែលគាំទ្រដោយសហរដ្ឋអាមេរិក មតិខ្លះទៀតយល់ថា ជាថ្ងៃបញ្ចប់នូវអំពើពុករលួយនៃរបបនេះ ។ រីឯពួកខ្មែរក្រហមដែលខិតខំបង្កប់ខ្លួនធ្វើសកម្មភាពបញ្ចុះបញ្ចូលប្រជាជនកសាងកម្លាំងក្នុងរបបសាធារណរដ្ឋអស់រយៈពេលជាច្រើនឆ្នាំមកនោះយល់ថាជាជោគជ័យដ៏ធំធេងជាប្រវត្តិសាស្ត្ររបស់ខ្លួន ។ ផ្ទុយទៅវិញប្រជាជនខ្មែរមួយចំនួនបែរជាមានការស្រពេចស្រពិលក្នុងចិត្តមិនដឹងប្រាកដថាថ្ងៃទី១៧ ខែមេសា ជាថ្ងៃអ្វីឡើយក្នុងខណៈដែលប្រទេសកម្ពុជាត្រូវបានរំដោះភ្លាម ។ មានប្រជាជនខ្លះរួមទាំងឪពុករបស់ខ្ញុំផងបានហោកញ្ច្រៀវស្រែកជយឃោសតាមពួកខ្មែររំដោះដែលត្រូវបានស្គាល់ជាទូទៅថាជា"ខ្មែរក្រហម" ។ ប៉ុន្តែចំពោះខ្ញុំយល់ថាថ្ងៃទី១៧ ខែមេសា ជាដើមទំព័រនៃការនិរាសព្រាត់ប្រាសរបស់គ្រួសារប្រជាជនខ្មែររួមទាំងគ្រួសាររបស់ខ្ញុំ ។

គ្រួសាររបស់ខ្ញុំមានដើមកំណើតនៅភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ប៉ុន្តែចាប់ពីពេលដែលមានការទម្លាក់គ្រាប់បែកពីសំណាក់រដ្ឋាភិបាលរបស់លោកសេនាប្រមុខ លន់ ណុល នាឆ្នាំ១៩៧០ គ្រួសាររបស់ខ្ញុំក៏បង្ខំចិត្តភៀសខ្លួនចូលមកក្រុងភ្នំពេញ ដោយប្រកបមុខរបរបន្តិចបន្តួចនៅផ្សារដើមថ្កូវដើម្បីចិញ្ចឹមជីវិត ។ ការរស់នៅប្រកបដោយការភ័យខ្លាចចំពោះការទម្លាក់គ្រាប់បែកចេះតែបន្តទៅអស់រយៈប្រហែលប្រាំឆ្នាំ ពោលគឺពីឆ្នាំ១៩៧០-៧៥ ។

នៅខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ៦ខែគត់នៅក្នុងផ្ទៃម្តាយ ។ ខ្ញុំមានការសោកស្តាយណាស់ដោយមិនបានដឹងនិងឃើញសកម្មភាពពិតៗដែលកើតឡើងនៅក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅពេលដែលខ្ញុំដឹងក្តីភ្លាមក៏ខ្ញុំបានព្យាយាមជជីកសួរម្តាយខ្ញុំអំពីរឿងរ៉ាវសោកនាដកម្ម ការនិរាសព្រាត់ប្រាស និងការឈឺចាប់រាប់មិនអស់របស់ប្រជាជនកម្ពុជានិយាយជារួម និងនិយាយដោយឡែកគឺរឿងរ៉ាវរបស់គ្រួសារខ្ញុំផ្ទាល់តែម្តង ។ ម្តាយខ្ញុំបានព្យាយាមរ៉ាយរ៉ាប់ឡើងវិញនូវរឿងរ៉ាវទាំងអម្បាលម៉ានដែលកើតឡើងចំពោះគ្រួសាររបស់ខ្ញុំ ។ គាត់បាននិយាយថា នៅថ្ងៃទី

 

១៧ ខែមេសា គាត់មានផ្ទៃពោះ៦ខែ ។ ទារកនៅក្នុងផ្ទៃរបស់គាត់គឺរូបខ្ញុំ ។ នៅថ្ងៃទី១៧ ខែមេសា ដែលជាថ្ងៃវាយសន្ទាប់យ៉ាងខ្លាំងក្លារវាងកងទ័ពរដ្ឋាភិបាល លន់ ណុល និងពួកខ្មែរក្រហម ។ ឪពុកក្មេករបស់ម្តាយខ្ញុំដែលត្រូវជាជីតាខ្ញុំក៏សុខចិត្តធ្វើដំណើរទាំងប្រថុយប្រថានកាត់គ្រោះថ្នាក់រាប់រយជំពូកដើម្បីមកយកម្តាយខ្ញុំទៅនៅផ្ទះរបស់គាត់ព្រោះគាត់យល់ថានៅទីនោះមានសុវត្ថិភាពជាងព្រោះជាផ្ទះថ្មដែលអាចបន្ថយនូវគ្រោះថ្នាក់នៃគ្រាប់កាំភ្លើង ។ ពេលឆ្លងមកដល់ផ្លូវពេទ្យរុស្ស៊ីភ្លាម ម្តាយខ្ញុំបានឃើញមនុស្សជាច្រើនក្នុងឯកសណ្ឋានខ្មៅដើររាយប៉ាយពាសពេញថ្នល់ ។ ពេលនោះម្តាយខ្ញុំមិនដឹងថាក្រុមអាវខ្មៅនោះជានណាឡើយ ។

នៅថ្ងៃដដែលនោះ ពេលមកដល់ផ្ទះជីតារបស់ខ្ញុំនៅទល់មុខអាងទឹកនៃពហុកីឡដ្ឋានជាតិអូឡាំពិក ការផ្ទុះអាវុធដ៏ធំមួយបានកើតឡើង ។ ពេលនោះម្តាយខ្ញុំបានឃើញឧទ្ធម្ភាគចក្រជាច្រើនគ្រឿងហោះឡើងចុះនៅលើបរិវេណពហុកីឡដ្ឋានជាតិអូឡាំពិក ។ សំឡេងគ្រាប់កាំភ្លើងតូចធំឆ្លើយឆ្លងគ្នាឥតដាច់ ។ ប្រមាណពីរម៉ោងក្រោយមក ពួកទាហានពាក់អាវខ្មៅដែលត្រូវបានស្គាល់ជាទូទៅថាជាពួកខ្មែរក្រហមនោះបានចូលមកដល់ក្នុងផ្ទះរបស់ជីតាខ្ញុំ ។ ទ័ពខ្មែរក្រហមបានគំរាមឲ្យមនុស្សក្នុងផ្ទះទាំងអស់ចេញពីផ្ទះបើមិនដូច្នោះទេពួកវានឹងបាញ់សម្លាប់ចោល ។ ដោយការតក់ស្លុតនិងភ័យខ្លាចពួកខ្មែរក្រហមបាញ់សម្លាប់ចោលទាំងពូជ ក្រុមគ្រួសារខ្ញុំក៏បង្ខំចិត្តចាកចេញពីផ្ទះដោយយកខោអាវតែមួយកំប្លេជាប់នឹងខ្លួន ព្រោះពួកខ្មែរក្រហមប្រាប់ថានឹងឲ្យមកផ្ទះសម្បែងវិញក្នុងរយៈពេលពីរ-បីថ្ងៃខាងមុខ ។

នៅពេលដើរតាមផ្លូវ១៨មីនា(បច្ចុប្បន្នផ្លូវប៉ាស្ទ័រ) ម្តាយខ្ញុំបានឃើញមនុស្សម្នាដើរណែនតាន់តាប់មិនដឹងនរណាជានរណាឡើយ ។ អ្នកខ្លះមានម៉ូតូត្រូវពួកពាក់ខោអាវខ្មៅភ្ជង់សម្លុតយកដោយនិយាយថាពួកខ្លួនយកទៅធ្វើការងារ ។ ការធ្វើដំណើរក៏ចេះតែបន្ត ទិដ្ឋភាពខ្លោចផ្សាក៏ចេះកើតឡើងរាប់មិនអស់នៅតាមផ្លូវ ដូចជាអ្នកខ្លះសម្រាលកូនដោយគ្មានឆ្មបបង្កើតហើយក្រោយពីកើតហើយក៏បន្តដំណើរទាំងត្រដាបត្រដួសទាំងគ្មានកម្លាំងកំហែង ។ ប្រាំពីរម៉ោងក្រោយមក ពេលគឺនៅវេលាម៉ោង១០យប់ ម្តាយរបស់ខ្ញុំក៏បានទៅដល់ស្រុកកោះធំ ។ ពេលទៅដល់ភូមប្រជាជន ជម្លៀសទាំងអស់រៀបចំដាំបាយហូបនៅតាមសំយាបផ្ទះរបស់អ្នកស្រុក ។

ក្រោយមកពួកខ្មែរក្រហមបានរៀបចំបញ្ជីបែងចែកប្រជាជនហើយដេញដោលសួរពីប្រវត្តិរូបរបស់ប្រជាជនម្នាក់ៗរហូតទល់ភ្លឺដើម្បីងាយស្រួលក្នុងការបែងចែកតាមតំបន់ផ្សេងៗដែលបានគ្រោងទុកជាស្រេចហើយនោះ ។ ពេលនោះហើយដែលក្រុមគ្រួសាររបស់ម្តាយខ្ញុំក៏ដូចជាប្រជាជនរាប់សិបម៉ឺននាក់ដែលត្រូវជម្លៀសចេញពីទីក្រុង ត្រូវនិរាសព្រាត់ប្រាសមិនដឹងជាប្រពន្ធប្តី ឪពុកម្តាយ កូនចៅញាតិសន្តាន ត្រូវចាត់តាំងឲ្យទៅនៅទីណាឡើយ ។ ពួកខ្មែរក្រហមបានចាត់តាំងមនុស្សទៅតាមនិន្នាការផ្សេងៗគ្នា ដូចជាសិស្ស និស្សិត ទាហាន មន្ត្រីរដ្ឋការស៊ីវិល ប៉ូលិស ។ល ។

ក្រោយពីធ្វើការបែងចែកហើយ ឪពុកនិងម្តាយខ្ញុំដែលមានខ្ញុំនៅក្នុងផ្ទៃប្រាំមួយខែផងនោះត្រូវបានពួកខ្មែរក្រហមចាត់តាំងឲ្យទៅនៅក្នុងភូមិឈើខ្មៅ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល ។ នៅកោះធំបានបីខែម្តាយខ្ញុំក៏ប្រសូត្រខ្ញុំ ។ ក្រោយពីប្រសូត្របានមួយខែ ពួកខ្មែរក្រហមក៏ជម្លៀសគ្រួសារខ្ញុំទៅកន្លែងផ្សេងទៀត ដោយប្រាប់ថានៅកន្លែងនេះគ្មានបាយសម្រាប់ប្រជាជនហូបគ្រប់គ្រាន់ឡើយ ។ ឪពុកខ្ញុំមានជំងឺមិនអាចធ្វើអ្វីកើត ដូច្នេះបន្ទុកដ៏ធ្ងន់ធ្ងរទាំងប៉ុន្មានក៏ធ្លាក់មកលើម្តាយខ្ញុំទាំងស្រុង ។ ម្តាយខ្ញុំបង្ខំចិត្តរៀបចំឥវ៉ាន់កំប៉ិកកំប៉ុកមួយចំនួនក្នុងអំរែកម្ខាង ហើយម្ខាងទៀតដាក់រូបខ្ញុំ ។ ម្តាយខ្ញុំនិយាយទាំងអស់សំណើចថា “មុខកូនឯងត្រូវកម្តៅថ្ងៃស្វោកហើយរបកស្បែកអស់រលីង ។ ម្តាយរែកកូនក្នុងចម្ងាយផ្លូវរាប់សិបគីឡូហើយចំណាយពេលបីយប់បីថ្ងៃទើបដល់ទីដៅដែលពួកខ្មែរក្រហមចាត់តាំង ។ សាច់ញាតិរបស់យើងទាំងប៉ុន្មានបានបែកខ្ញែកគ្នាអស់ ។ ពេលធ្វើដំណើរដល់ខេត្តព្រះវិហារ ដោយឃើញនូវសភាពត្រដាបត្រដួសរបស់ម្តាយនិងកូនឯង មានកម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ ស៊ូ បានណែនាំម្តាយឲ្យដាក់ឈ្មោះឲ្យកូនឯងថា “ស៊ូ” គឺឈ្មោះដូចគាត់ព្រោះគាត់យល់ថាមនុស្សឈ្មោះនេះមិនងាយស្លាប់ទេ” ។

 

រាល់ពេលដែលនិយាយដល់ថ្ងៃទី១៧ ខែមេសា ខ្ញុំតែងតែនឹកដល់ថ្ងៃដែលគ្រួសារខ្ញុំព្រាត់ប្រាសគ្នា ។ ខ្ញុំមិនដែលជួបមុខជីដូន ជីតា ម្តាយមីង ឪពុកមារបស់ខ្ញុំឡើយ ។ បើគ្មានថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏គ្រួសាររបស់ខ្ញុំមិនបាត់បង់សមាជិកច្រើនយ៉ាងនេះដែរ ។ បើរាប់គ្រួសៗទាំងជីដូនជីតា ឪពុកមា ម្តាយមីងខាងឪពុក និងខាងម្តាយ គឺសរុបទាំងអស់ត្រូវពួកខ្មែរក្រហមសម្លាប់អស់ប្រហែល៥០នាក់ ពោលគឺសម្លាប់ទាំងគ្រួសារៗដោយចោទគាត់ថាជានាយទុន ។

សំណួរមួយចំនួនតែងតែដក់ក្នុងអារម្មណ៍ខ្ញុំជានិច្ចថា «ហេតុអ្វីបានជាពួកខ្មែរក្រហមយកជីដូនជីតា ម្តាយមីង ឪពុកមា និងញាតិសន្តានរបស់ខ្ញុំទៅសម្លាប់? តើគាត់មានកំហុសអ្វី? ហើយនរណាជាអ្នកដើមគំនិតប្រព្រឹត្តនូវអំពើអមនុស្សធម៌ទាំងនេះ?» ។ សំណួរទាំងនេះតែងតែជំរុញឲ្យខ្ញុំធ្វើអ្វីមួយដើម្បីលាតត្រដាងនូវការពិតដែលគ្មាននរណាម្នាក់ដឹងប្រាកដឡើយ ។

នៅក្នុងឆ្នាំ១៩៩៧ ជាឆ្នាំដែលខ្ញុំកំពុងសិក្សានៅមហាវិទ្យាល័យ ខ្ញុំក៏បានស្ម័គ្រចិត្តចូលបម្រើការងារជាអ្នកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាស្ថាប័នមួយឯករាជ្យ ជាអង្គការក្រៅរដ្ឋាភិបាលនិងជាថ្នាលបណ្តុះបណ្តាលកូនខ្មែរពិតៗ ហើយបុគ្គលិកនិងអ្នកដឹកនាំគឺសុទ្ធតែជាជនជាតិខ្មែរទាំងអស់ ។ ពេលបានចូលធ្វើការនៅមជ្ឈមណ្ឌលឯកសារភ្លាម ខ្ញុំបានប្រទះនូវឃ្លាមួយដែលរត់នៅលើកញ្ចក់កុំព្យូទ័រសរសេរជាភាសាអង់គ្លេសថា "**Searching for the truth**" មានន័យថា "***ស្វែងរកការពិត***" ។ ពេលនោះខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថា ក្តីប្រាថ្នាចង់ដឹងការពិតរបស់ខ្ញុំដែលមានជិត២០ឆ្នាំមកហើយនោះនឹងបានសម្រេចជាពុំខាន ។ ប៉ុន្តែការពិតមិនទាន់ត្រូវបានរកឃើញនៅឡើយទេ លុះត្រាតែតុលាការដែលមានបទដ្ឋានអន្តរជាតិមួយត្រូវបានបង្កើត ។ ដូច្នេះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាដើមទំព័រសករាជនៃការនិរាសព្រាត់ប្រាសរបស់ប្រជាជនកម្ពុជារួមទាំងគ្រួសាររបស់ខ្ញុំផងនោះនៅតែជារឿងអាថ៌កំបាំង ។

តុលាការមួយដែលមានបទដ្ឋានអន្តរជាតិគួរតែត្រូវបានបង្កើតឡើងឲ្យបានឆាប់តាមតែអាចធ្វើទៅបានដើម្បីឆ្លើយតបនឹងសំណួរយ៉ាងផងៗនិងសាមញ្ញរបស់ប្រជាជនកម្ពុជារួមទាំងសំណួររបស់ខ្ញុំផង ។ ពីព្រោះមានតែតុលាការឯករាជ្យមួយទេដែលអាចធ្វើឲ្យអារម្មណ៍ជនរងគ្រោះកម្ពុជាដែលនៅរស់រានមានជីវិតបានស្ងប់ចិត្ត ហើយថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ ក៏លែងជាចម្ងល់របស់សាធារណមតិជាតិនិងអន្តរជាតិទូទៅទៀតដែរ ។

**សួ ប៊ុនស៊ុ**



សកម្មភាពប្រជាជនដែលត្រូវជម្លៀសចេញ

# គោរពជូន

## *លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*

តាងនាមមន្ត្រីរាជការនៃអាជ្ញាធរមូលដ្ឋានក្នុងសាសាស្រុកពួក ខេត្តសៀមរាប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងធំធេងបំផុតចំពោះលោក ឆាំង យុ ដែលបានផ្តល់ឲ្យសាលាស្រុកយើងខ្ញុំនូវទស្សនាវដ្តី«ស្វែងរកការពិត»ជារៀងរាល់លេខតរៀងមក ។ ខ្លឹមសារដែលមាននៅក្នុងទស្សនាវដ្តីបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវមហាសោកនាដកម្មយ៉ាងឃោរឃៅព្រៃផ្សៃយង់ឃ្នងបំផុតដែលបនប្រល័យពូជសាសន៍ ប៉ុល ពត បានប្រព្រឹត្តមកលើប្រជាជនកម្ពុជាយើងក្នុងរយៈកាល៣ឆ្នាំ ៨ខែ និង២០ថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងនាមយើងខ្ញុំក៏ដូចជាមន្ត្រីរាជការនិងអាជ្ញាធរមូលដ្ឋានទាំងអស់ក្នុងស្រុកពួកដែលសុទ្ធតែបានឆ្លងកាត់នូវសម័យមហាឧក្រិដ្ឋកម្មរបស់បន ប៉ុល ពត ហើយមានភ័ព្វសំណាងបានរស់រានមានជីវិតដល់សព្វថ្ងៃនេះ យើងខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះទឹកចិត្តព្យាយាមតស៊ូខិតខំរបស់លោកនាយកនិងសហការីដែលបានចងក្រងឡើងវិញនូវឯកសារដ៏មានតម្លៃនេះសម្រាប់ជាប្រយោជន៍ដល់សង្គមនិងប្រជាជនកម្ពុជាយើង បានស្វែងយល់និងសិក្សាស្រាវជ្រាវតទៅមុខទៀត ។

យោបល់របស់យើងខ្ញុំដើម្បីស៊ីជម្រៅឲ្យដល់មូលដ្ឋានគ្រប់គ្រងដោយអង្គការខ្មែរក្រហម គួរលោកនាយកអធ្យាស្រ័យមេត្តាស្រាវជ្រាវបន្ថែមទៀតនូវរបៀបរបបដឹកនាំផ្ទាល់ពីថ្នាក់មូលដ្ឋានតាំងពីថ្នាក់ក្រុម សហករណ៍ គណៈភូមិ គណៈឃុំ គណៈស្រុក គណៈតំបន់ ភូមិភាគ ស្តីពីរចនាសម្ព័ន្ធរបៀបគ្រប់គ្រងដឹកនាំក្នុងរបប ប៉ុល ពត ព្រោះវាមានលក្ខណៈពីរយ៉ាងៈ

ទី១) ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មូលដ្ឋានមួយចំនួន ភូមិ ឃុំ ស្រុក ក្រៅពីរបបសាធារណរដ្ឋកាន់កាប់សុទ្ធសឹងតែជារបបខ្មែរក្រហមកាន់កាប់ទាំងស្រុង ហៅថាតំបន់រំដោះ រូបភាពឆ្នាំ១៩៧០ជារូបភាពរណសិរ្សរួបរួមជាតិ ក្រោយមកនៅក្នុងឆ្នាំ១៩៧៣ តំបន់មួយចំនួនក្លាយទៅជាសហករណ៍ (ធ្វើរួមហូបរួម) ហើយចាប់ផ្តើមប្រែក្លាយទៅជាការដឹកនាំតាមរបៀបកុម្មុយនិស្តទៅវិញ ។

ទី២) ចាប់ពីឆ្នាំ១៩៧៥រហូតមកដល់ឆ្នាំ១៩៧៩ តើការដឹកនាំរបស់ខ្មែរក្រហមប្រែក្លាយទៅជាយ៉ាងណា? នេះជាប្រវត្តិសាស្ត្រមួយទាក់ទងផ្ទាល់ទៅនឹងសមត្ថកិច្ចដឹកនាំរបស់ពួកខ្មែរក្រហម ហើយជាឥទ្ធិពលបង្ហាញមនុស្សលោកយល់កាន់តែច្បាស់នូវមហាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ខ្លួនឯង ។ នេះជាចំណុចពិសេសដែលខ្ញុំសូមឲ្យលោកនាយកមេត្តាសិក្សាស្រាវជ្រាវដល់មូលដ្ឋានរួមទាំងមានសាក្សីពិតបំភ្លឺផង និងដើម្បីផ្សព្វផ្សាយក្នុងទំព័រទស្សនាវដ្តី«ស្វែងរកការពិត» ជួយឲ្យមតិជាតិនិងអន្តរជាតិយល់កាន់តែច្បាស់ពិសេសសិស្សានុសិស្សដែលកើតក្នុងឆ្នាំ១៩៧៥ដល់១៩៧៩មកទល់បច្ចុប្បន្ន ខ្លះគ្នាក៏មិនទាន់ដឹងច្បាស់ជាក់ស្តែងនៅឡើយដោយព្រគេនិយាយតៗគ្នា បញ្ហានេះខ្ញុំយល់ថាលោកនាយកមិនប្រកាន់ខឹងនឹងខ្ញុំទេ ទោះបីយើងមានការខ្វះខាតមិនបានគ្រប់សព្វក៏ដោយប្ក៏កន្លងមកលោកបានធ្វើការផ្សព្វផ្សាយរួចក៏ដោយ ។

សូមអរគុណចំពោះទឹកចិត្តរបស់លោកនាយកដែលបានផ្ញើលិខិតមកយើងខ្ញុំចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០០ ។

ជាទីបញ្ចប់យើងសង្ឃឹមថាលោកនាយកនឹងបន្តការផ្តល់នូវទស្សនាវដ្តី«ស្វែងរកការពិត»នេះមកសាលាស្រុកពួកយើងខ្ញុំនូវលេខក្រោយៗបន្តទៀតជាមិនខាន ។ សូមប្រសិទ្ធិពរជូនលោកនាយកនិងសហការីទាំងអស់សូមជួបប្រទះតែនឹងភ័ព្វសំណាងល្អ ព្រមទាំងសម្រេចបានជោគជ័យក្នុងភារកិច្ចរបស់ខ្លួនជារៀងរហូត ។ សូមលោកទទួលនូវមនោសញ្ចេតនារាប់អានដ៏កក់ក្តៅអំពីយើងខ្ញុំ ។

សាលាស្រុកពួក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០

**អភិបាលស្រុកពួក**

**ធេស ច័ន្ទគីរី**

កំណាព្យខ្មែរក្រហម

# យើងខ្ញុំដឹងគុណអង្គការបដិវត្តន៍

កត់ត្រាចងក្រងខាងឯកសារ

កញ្ញា សើ សាយ្យាណា

(បទពាក្យ៧)

យើងកុលបុត្រកុលធីតា    រស់ក្នុងអន្ធាងងឹតស្អុប
ព្រះសូរភ្លឺងងឹតជាងយប់    គឺរស់ក្នុងភពគ្មានរស្មី ។
គឺរស់ក្នុងសង្គមពុករលួយ    គេគ្មានព្រួយពីដែនដី
ទោះជាស្មោកគ្រោកយ៉ាងណាក្តី    ក៏ជនអប្រិយគ្មានខ្វាយខ្វល់ ។
ទើបតែពេលនេះបានអង្គការ    បដិវត្តន៍កម្ពុជាធ្វើឲ្យយល់
ដំណើរជីវិតសុភមង្គល    ព្រួយរកកន្ល់របបចាស់ ។
ដោយបានអង្គការអ្នកដឹកនាំ    បង្វិលចិត្តខ្ញុំឲ្យស្គាល់ច្បាស់

សង្គមមួយថ្មីថ្លៃល្អល្អះ    ឲ្យយល់បានច្បាស់នូវមាគ៌ា ។
សង្គមថ្មីនេះជាពន្លឺ    កែវភ្នែកយើងភ្លឺហើយមុតថ្លា
សង្គមនេះហើយជាប្រាថ្នា    យើងខ្ញុំរាល់គ្នាដែលចង់បាន ។
អស់ឱអង្គការអ្នកមានគុណ    ធ្ងន់នេះសែនធ្ងន់ប្រៀបពុំបាន
ទោះជាជីវីគ្រប់ៗប្រាណ    ក៏ប្រៀបពុំបានគុណអ្នកឡើយ ។
យើងកុលបុត្រកុលធីតា    គ្រប់ៗអាត្មាគ្មានកន្តើយ
មានតែជីវិតយើងនេះហើយ    តស៊ូមិនធ្លោយលុះអវសាន ។



**ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល**


មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 11, November 2000
Funded by the Royal Ministry of Foreign Affairs,Oslo, Norway, Section for the Human Rights and Humanitarian Assistance; the Canada Funds, Canadian Embassy,Phnom Penh; and the Swedish International Development Cooperation Agency (Sida), Embassy of Sweden, Phnom Penh; Supported by the Royal Netherlands Government, *The Hague,* (The Netherlands).